# សិល្បៈតម្បាញសូត្រខ្មែរ



រៀបរៀងដោយ នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌
នាយកដ្ឋានសិល្បៈសូនរូប និង សិល្បៈសិប្បកម្ម

សៀវភៅ

# សិល្បៈតម្បាញសូត្រខ្មែរ

រក្សាសិទ្ធិ ឆ្នាំ ២០១៧

# មាតិកា

ទំព័រ


សេចក្តីផ្តើម.......................................................................................................................១

ក. អំពីសិល្បវិធីក្នុងការធ្វើសូត្រតម្បាញ.....................................................................២

១. ការចិញ្ចឹមនាងសំរាប់យកសូត្រ.............................................................................២

២. ការបែងចែកប្រព័ន្ធផលិតតាមសង្វាក់ផ្នែកចិញ្ចឹមនាង...................................................២

៣. ការវិវត្តន៍នៃដង្កូវនាង...........................................................................................៣

៤. អំពីឧបករណ៍ និងសម្ភារៈផលិត................................................................................៤

៤.១. វិធីបង្កាត់យកពងដង្កូវនាង.................................................................................៤

៤.២. វិធីនាងធ្វើសំបុក..............................................................................................៩

៤.៣. វិធីស្រាវសូត្រខ្មែរ............................................................................................១០

៤.៤. វិធីធ្វើក្បុង......................................................................................................១៣

៤.៥. វិធីប្រមោកសូត្រ...............................................................................................១៤

៤.៦. វិធីធ្វើល័ក្ខខ្មែរ................................................................................................១៦

៤.៧. វិធីចងល័ក្ខ ឬបន្ទំល័ក្ខ.....................................................................................១៩

៤.៨. វិធីជ្រលក់ល័ក្ខចិន...........................................................................................១៩

៤.៩. វិធីរៀបចំតម្បាញសូត្រខ្មែរ................................................................................១៩

៤.១០. វិធីរវៃសូត្រអន្ទង............................................................................................២០

៤.១១. វិធីជ្រលក់គៀត................................................................................................២២

៤.១២. វិធីវៃសូត្រដាក់ត្រល់.........................................................................................២៤

៤.១៣. វិធីខាសូត្រអន្ទង.............................................................................................២៤

៤.១៤. វិធីខាសូត្រចាក់.........................................................................................................២៤

៤.១៥. វិធីចងគៀតហូល.........................................................................................................២៤

៤.១៦. វិធីធ្វើល័ក្ខជ្រលក់ហូល.........................................................................................................២៥

៤.១៧. វិធីតម្បាញក្រមាខ្មែរ.........................................................................................................២៦

៤.១៨. វិធីចាក់ធ្មេញឈើ.........................................................................................................២៦

៤.១៩. វិធីរើសជរជើង និងផ្កា.........................................................................................................២៦

៤.២០. វិធីធ្វើស្នឹងប៉ាក់ឱន.........................................................................................................២៧

**ខ. ប្រវត្តិ និងបច្ចេកទេសតម្បាញហូល**.........................................................................................................៣០

១. ប្រវត្តិតម្បាញហូល.........................................................................................................៣០

២. ស្ថានភាពត្បាញនាពេលបច្ចុប្បន្ន.........................................................................................................៣០

៣. អំពីកីត្បាញ.........................................................................................................៣៩

៤. ឧបករណ៍បន្ទាប់បន្សំនៅក្នុងកី.........................................................................................................៦០

៤.១. គម្របធ្មេញឈើ.........................................................................................................៦០

៤.២. ធ្មេញឈើ.........................................................................................................៦០

៤.៣. ក្តារមូរ.........................................................................................................៦២

៤.៤. ឈើផ្សំ.........................................................................................................៦៣

៤.៥. ចន្ទាល់.........................................................................................................៦៤

៤.៦. ត្រល់.........................................................................................................៦៤

៤.៧. ខ្នារ.........................................................................................................៦៦

៤.៨. បន្ទូលតង្កៀ.........................................................................................................៦៦

៤.៩. បន្ទូលតង្កៀផ្កា.........................................................................................................៦៧

៤.១០. ឈ្នាន់..........................................................................................................................៦៨
៤.១១. រ៉ត.............................................................................................................................៦៨
៤.១២. ដាមកំណើត.................................................................................................................៧១
៤.១៣. ត្រដោកក្តារ................................................................................................................៧២
៤.១៤. រា.................................................................................................................................៧៤
៤.១៥. ឈើរឹត.........................................................................................................................៧៤
៥. ឧបករណ៍បន្ទាប់បន្សំនៅខាងក្រៅកី.........................................................................................៧៥
៥.១. រហាត់............................................................................................................................៧៥
៥.២. រងើ្វង.............................................................................................................................៧៧
៥.៣. ឡូត...............................................................................................................................៧៨
៥.៤. កូនអន្ទង.........................................................................................................................៨០
៥.៥. បំពង់..............................................................................................................................៨៤
៥.៦. ប្រែង..............................................................................................................................៨៤
៦. ក្បាច់លម្អ............................................................................................................................៨៥
៧. ការចងគៀត.........................................................................................................................៩៧
៨. ការជ្រលក់ពណ៌.....................................................................................................................១០១
៩. បច្ចេកទេសត្បាញ...................................................................................................................១០៥
១០. ប្រភេទហូល និងការប្រើប្រាស់..................................................................................................១០៩
**គ. ទំនាក់ទំនងរវាងសិប្បករ**..........................................................................................................១១៦
១. ប្រព័ន្ធតម្បាញក្នុងភូមិ............................................................................................................១១៦
១.១. ទំនាក់ទំនងនៅក្នុងគ្រួសារ.......................................................................................................១១៦

១.២. ទំនាក់ទំនងពីគ្រួសារមួយទៅគ្រួសារមួយ......១១៧
១.៣. ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ......១១៨
ឃ. ការផ្ទេរចំនេះដឹងតម្បាញដល់ក្មេងជំនាន់ក្រោយ......១២២
១. ផ្នត់គំនិតអ្នកតម្បាញពេលបច្ចុប្បន្ន......១២២
២. គំនិតក្មេងជំនាន់ក្រោយលើការតម្បាញ......១២៤
រូបភាពផលិតផលសូត្រ......១៤៥
តារាងស្ថិតិសិប្បកម្មតម្បាញសូត្រតាមបណ្ដាលខេត្តមួយចំនួន......១៤៦
សូមថ្លែងអំណរគុណ......១៥២
ឯកសារពិគ្រោះ......១៥៣

# សេចក្ដីផ្ដើម

ក្នុងប្រវត្តិសាស្ត្រខ្មែរយើងមានអារ្យធម៌ដ៏ខ្ពង់ខ្ពស់ដោយផ្អែកលើវប្បធម៌សិល្បៈ ប្រពៃណី សាសនា នយោបាយ សេដ្ឋកិច្ចសង្គម និង វិជ្ជាទូទៅ ។

សិល្បៈតម្បាញសូត្រនេះបានចាប់កើតឡើងយូរលង់ណាស់មកហើយ តាមរយៈជនជាតិក្លឹង្គចូលមកស្រុកខ្មែរ។ ដំបូងពួកគេនាំចូលមកនូវវប្បធម៌ប្លែកៗមានជំនឿសាសនាឧបករណ៍ប្រើប្រាស់ជាច្រើនមុខទៀតមកក្នុងទឹកដីខ្មែរយើង ក្នុងការផ្សារភ្ជាប់នូវប្រពៃណី និងសោភ័ណ្ឌភាពទំនើប មានការតុបតែងលំអរកាយ គ្រឿងអលង្កា និងសម្លៀកបំពាក់ល្អៗជាច្រើន ធ្វើអំពីសូត្រគ្រប់ពណ៌។ តាំងពីពេលនោះមកការកកើតនូវសិល្បៈមាននៅតាមភូមិស្រុកនានា ទូទាំងប្រទេសខ្មែរទាំងមូល។ ការរក្សានូវប្រពៃណីបច្ចេកទេសតម្បាញនេះបានគង់វង្សតាមរយៈពូជពង្សញាតិសណ្ដាន តកូនតចៅមកទល់សព្វថ្ងៃនេះ ទោះបីជាមានការហូរចូលនូវប្រភេទក្រណាត់ប្លែកៗពីបរទេសមកយ៉ាងណាក៏ដោយ ក៏ប្រជារាស្ត្រខ្មែរនៅតែឲ្យតម្លៃដ៏ខ្ពស់ ទៅលើក្រណាត់សូត្ររបស់ខ្លួនជាប់ជានិច្ច។ សព្វថ្ងៃសិល្បៈតម្បាញមានការថយចុះនូវបរិមាណផលិតផលរបស់ខ្លួន ដោយខ្វះការយកចិត្តទុកដាក់ផលិតវត្ថុធាតុដើម គឺការចិញ្ចឹមដង្កូវនាងសម្រាប់យកសូត្រ ការដាំដើមមន និងអ្នកចិញ្ចឹមនាងយកសូត្រកាន់តែតិចទៅតិចៗ រហូតទាល់តែនាំសូត្រមកពីប្រទេសក្រៅចូលមកវិញ ចំណែកសិប្បកម្មតម្បាញ ក៏មានតិចតួចតាមភូមិស្រុកដែលរក្សាបាននូវប្រពៃណីទំនៀមទំលាប់នេះប៉ុណ្ណោះ។

ជាច្រើនទសវត្សរ៍ណាស់មកហើយ ការវិវត្តរីកចំរើនលើវិស័យតម្បាញនេះធ្វើឲ្យកូនខ្មែរចងចាំនូវខ្នាតជាគោលសំខាន់ របស់ខ្លួនពិតប្រាកដក្នុងការច្នៃប្រឌិតរស់រវើក អាចបំរើសេចក្ដីត្រូវការរបស់ប្រជារាស្ត្រខ្មែរ និងធ្វើការផ្សព្វផ្សាយជាទូទៅក្នុងពិភពលោក ឲ្យគេស្គាល់ពីអារ្យធម៌ដ៏ខ្ពង់ខ្ពស់របស់ជាតិមួយដែលមានវប្បធម៌ប្រពៃណីដ៏រុងរឿងផង ការរក្សាកេរ្តិ៍មរតករបស់តម្បាញខ្មែរបានធ្វើចេញជាសំពត់ជាច្រើនប្រភេទ មានរូបភាព ប្លែកៗ ជាផ្កា ក្រឡាពស់ រូបសត្វ រូបក្បាច់បូរាណតាមប្រាសាទដោយបង្កើតនូវភាពរស់រវើកមានសោភ័ណ្ឌភាពដ៏ស្រស់ប្រិមប្រិយ។

សំលៀកបំពាក់ខ្មែរ ដែលធ្វើអំពីសូត្រមាន៖

សំពត់ហូល ផាមួង ចរបាប់ អន្លូញ យៀន សារ៉ុង ក្រមា។ល។

ក. អំពីសិល្បវិធីក្នុងការធ្វើសូត្រតម្បាញ

១. ការចិញ្ចឹមនាងសំរាប់យកសូត្រ

កូននាងគឺគេឲ្យឈ្មោះទៅលើសត្វដង្កូវម្យ៉ាង ដែលមានសម្បុរពណ៌បៃតងខ្ចី រូបរាងវាដូចជាដង្កូវដូងមានក្បាលតូច និងពាក់កណ្តាលខ្លួនទៅក្រោយរីកធំមូល មានជើងតូចល្អិតរៀវយើតៗ វាជាសត្វមួយស្អាតជាងដង្កូវដូងដ៏ទៃ ហើយពុំបង្កលក្ខណៈបំផ្លាញផ្សេងៗទៅលើផលដំណាំដាំដុះអ្វីឡើយ។

តាមទំនៀមទំលាប់ខ្មែរដែលរក្សាតៗ គ្នាគេច្រើនចិញ្ចឹមកូននាងនៅតាមផ្ទះរៀងៗខ្លួន និងតាមរោងធំមួយទៀតសំរាប់ដាក់សំបុកកូននាង។ នៅក្នុងផ្ទះ និងបរិវេណដីជុំវិញ គឺត្រូវបោសសំអាតជានិច្ច ជាពិសេស គឺការពារសត្វល្អិតផ្សេងៗ កុំឲ្យចូលមកខាំកូននាងបាន។ សត្វរុយជាសត្រូវធំបំផុតរបស់កូននាង។

អ្នកដែលចិញ្ចឹមកូននាងបាន ត្រូវមានលក្ខណៈសម្បត្តិល្អប្រពៃចិត្តអំណត់ព្យាយាម រក្សាដំណមគ្រប់បែបយ៉ាងមានដូចតទៅ ៖

១. មនុស្សមានក្លិនល្អ
២. តមជក់បារី
៣. តមអ្នកមានរដូវ
៤. តមនិយាយអាក្រក់ (ភ្ញាត់មាត់ ឬពាក្យអាសអាស)
៥. តមអ្នកមានគ្រួសារស្លាប់

អ្នកចិញ្ចឹមកូននាងភាគច្រើនៗតែនារីហើយច្រើនតែមានវ័យពាក់កណ្តាលមនុស្សឡើងទៅ ។

២. ការបែងចែកប្រព័ន្ធផលិតតាមសង្វាក់ផ្នែកចិញ្ចឹមនាង:

១. ផ្នែកដាំដើមមន និង បេះស្លឹកមន
២. ផ្នែកភ្ញាស់កូននាង និង បង្កាត់យកពូជ
៣. ផ្នែកចិញ្ចឹម និង ថែរក្សាកូននាងដាក់សំបុក
៤. ផ្នែកស្រាវសូត្រ

## ៣. ការវិវត្តន៍នៃដង្កូវនាង



## ៤. អំពីឧបករណ៍ និងសម្ភារៈផលិត

ចំពោះការផលិតអាចរីកចំរើន និង ទទួលទិន្នផលខ្ពស់បាន គឺអាស្រ័យលើឧបករណ៍ និង សម្ភារៈគ្រប់គ្រាន់ដូចជា៖ គ្រាង ចង្អេរ កញ្ជើរ ល្អី កន្តាំង ធុង ក្រណាត់ស ស្បៃ មុង ផ្តាំង ចាន ដញ្ជីង រហាត់រវៃ ។ល។

ជាតំបូងគេធ្វើគ្រោងឈើជាថ្នាក់ៗ សំរាប់ដាក់គ្រាងធំៗ ដែលមានកូននាងនៅក្នុងនោះ ដើម្បីងាយរៀបចំ ដាក់ចិញ្ចឹមតាមថ្ងៃខែរបស់វា។ ក្នុងការថែទាំកូននាងឲ្យបានល្អ គេយកចានទ្រ គ្រោងឈើនោះដាក់ទឹក ដើម្បីការពារសត្វល្អិតផ្សេងៗ រួចគេដាក់មុង ឬ រុំក្រណាត់ស្បៃគ្របពីលើ កុំឲ្យសត្វមុស ឬសត្វរុយទិចកូននាងបាន ចំពោះកូននាងដែលនៅតូចគេប្រយ័ត្នជាទីបំផុតក្នុង ការថែទាំ និងដាក់ចំណី គឺគេយកស្លឹកមនមកហាន់ឲ្យល្អិត ដាក់រោយពាសពេញ ដើម្បីឲ្យកូន នាងតោងស៊ីជាអាហារ។

ចំណីកូននាងគឺស្លឹកមន ដែលមានពណ៌បៃតងស្រស់ ដើមមនគេអាចដាំយកស្លឹកបាន ក្នុងរយៈពេល១ឆ្នាំ បើគេចិញ្ចឹមកូននាងច្រើនគេត្រូវដាំដើមមនឲ្យបានច្រើន ព្រោះវាជាចំណីតែ មួយរបស់សត្វនាង។ នៅរដូវក្តៅការចិញ្ចឹមកូននាងពុំសូវបានផលទេ ព្រោះកូននាងចាញ់ធាតុ ក្តៅ ពុំអាចរីកធំធាត់ល្អ ជាពិសេសគឺស្លឹកមនច្រើនតែមានស្លឹកចាស់ៗ។ ផលវិបាកក្នុងការចិញ្ចឹម កូននាង គឺត្រូវផ្តល់ចំណីអាហារឲ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

### ៤.១. វិធីបង្កាត់យកពងដង្កូវនាង

នៅពេលដង្កូវនាងធ្វើសំបុកគ្រប់កំណត់ថ្ងៃហើយ គេរើសយកសំបុកនាងល្អៗ យកមក ចិញ្ចឹមទុកនៅក្នុងកន្ទ្រែងមួយ ថែទាំឲ្យបានល្អស្អាត គ្រប់កំណត់ពេលមួយសប្តាហ៍ទើបបានដង្កូវ ក្នុងសំបុកកើតចេញជាមេអំបៅ ពេលនោះគេរើសញីឈ្មោល ដាក់មួយគូៗ ដើម្បីបង្កាត់ពូជរួច យកស្បៃគ្របឲ្យជិតទុករយៈពេល ពីរ ឬ បីម៉ោង ទើបចាប់មេអំបៅញីឈ្មោលនោះ ដាក់ដោយ ឡែកពីគ្នា។ ចំណែកមេអំបៅញី គេយកទៅដាក់ឲ្យពងលើក្រណាត់សមួយក្នុងចង្អេរ ឬគ្រាង រួច គេយកវានកន្ទោងគ្របពីលើ។ លុះបានមួយយប់ទើបវាពង ពងរួចគេយកមេអំបៅញី ទៅបង្កាត់ ម្តងទៀត ដោយធ្វើដូចជាលើកទី១។ មេអំបៅញីឈ្មោលអាចបង្កាត់គ្នាបានតែពីរដងទេ។ ក្នុង

ពេលបង្កាត់បានពងហើយ គេគ្របក្រណាត់ទុកលើគ្រាងចំនួន ៥ថ្ងៃ ទើបពងពណ៌សនោះ ទៅជាពណ៌ខ្មៅបន្តិចម្តងៗ កំណត់រយៈពេល ៥ថ្ងៃ គេសន្មត់ពងវាទុំ តែត្រូវថែម ពីថ្ងៃទៀត ទើបពងនោះញាស់ចេញជាកូនដង្កូវតូចៗ ពេលនោះគេចាប់ហាន់ស្លឹកមនតូចៗ រោយឲ្យស្មើផដាក់ឲ្យវាស៊ី ហើយគ្របឲ្យបានត្រឹមត្រូវល្អយកទៅទុកឲ្យបានរយៈពេល ៧ថ្ងៃទៀត រយៈពេលនេះគេបានសន្មត់ថាកូននាងដេក។ ពេលនាងដេក គេត្រូវតមពាក្យសំដីមិននិយាយអាក្រក់ មិនអោយដេរ គឺអ្វីដែលពុំគប្បីឲ្យដល់កូននាង ព្រោះពេលវាដេកនោះគេហៅថា "នាងសក" ការសករបស់កូននាងមានចំនួន ៤លើក ក្នុង ១លើកៗ គេត្រូវឲ្យចំណីម្តងនៅលើកទី១ គេរើសកូននាងបំបែកទៅលើគ្រាងមួយថ្មីដាក់ឲ្យទូលាយបន្តិចដើម្បីរាយឲ្យរីកធំធាត់។ នៅលើកទី២ គេចាប់រើសកូននាងធំៗ ដាក់ដោយឡែក និងតូចៗដាក់ដោយឡែក គេធ្វើរបៀបនេះគំរប់ ៤ដង រហូតដល់កូននាងទុំ (គឺកូននាងធំពេញលក្ខណៈដែលអាចធ្វើសំបុកបាន)សូមបញ្ជាក់ថាការឲ្យចំណីម្តងៗគេត្រូវរើសកូនមិនល្អចោលចេញ ទុកសំរាំងតែកូននាងណាដែលល្អធំធាត់ ។



រូបភាពការធ្វើសំបុកសំរាប់ដង្កូវនាង



រូបភាពលោក ទ្រឹម សុភា អ្នកជំនាញចិញ្ចឹមដង្កូវនាងនៅកោះឧកញ៉ាតី



រូបភាពការបន្តពូជរបស់មេអំបៅ



រូបភាពមេអំបៅពងបានមួយសប្តាហ៍



រូបភាពពងមេអំបៅបានបីថ្ងៃ



រូបភាពដង្កូវនាងនៅតូច

## ៤.២. វិធីនាងធ្វើសំបុក

ពេលនាងធ្វើសំបុក គេហៅថានាងលេងខ្លួន ឬបង្អួតពង គឺគេសប្បាយរីករាយនៅពេលគេពេញលក្ខណៈចេះធ្វើសំបុក សំបុកសំរាប់ដាក់កូននាង គឺគេយកមែកសង្កែងាប់ ចងជាបាច់តាមចំនួនដែលត្រូវការ គេហៅថា "ឃ្នាប" ដោយមានចងខ្សែព្យួរជាជួរ តាមរបៀបត្រឹមត្រូវរួចគេចាប់កូននាងដាក់ឲ្យតោងលើឃ្នាបនោះទាល់តែអស់។

នៅពេលកូននាងចាប់ធ្វើចលនា បញ្ចេញសរសៃសូត្រមកព័ទ្ធសំបុក ការធ្វើសំបុកត្រូវប្រើរយៈពេល ៤៨ម៉ោង គឺចំណាយពេល ២ថ្ងៃ រួចគេបេះសំបុកនាងពីឃ្នាប យកទៅដាក់លើគ្រាងសំដិលឲ្យបាន ២ថ្ងៃ ទើបគេយកទៅស្រាវ។



ទ្រុងសំរាប់ចិញ្ចឹមដង្កូវនាងការពារសត្វល្អិតផ្សេងៗ

### ៤.៣. វិធីស្រាវសូត្រខ្មែរ

ក្នុងការងារបច្ចេកទេសធ្វើសូត្រតាមជម្មតាមានរហាត់និង ឆ្នាំងដាំទឹក រួចគេកាត់មែកឈើធ្វើជាជើងរទេះដាក់លើមាត់ឆ្នាំងដាំឲ្យពុះ។ មុននិងស្ងោរសំបុកនាងគេត្រូវបេះយកដឹកឌឿចេញសិនដើម្បីឲ្យងាយក្នុងការស្រាវសូត្រ គេយកតម្បៀតទៅកូរឲ្យសូត្រធាប់បែកជាសរសៃហើយគេចាប់កៀបយកសរសៃដើមមកពាក់លើជើងរទេះ។ គេស្រាវរវៃមួយសារហើយគេស្រង់សំបុកនោះមកទុកនឹងកញ្ច្រែងមួយដោយឡែក គេធ្វើរបៀបនេះទាល់តែអស់ រួចគេចាក់ទឹកចាស់ចោល គេដាំទឹកជាថ្មីមួយសារទៀតឲ្យពុះល្អ ទើបយកសំបុកនាងមកស្ងោរជាលើកទី២ ក្នុងការស្ងោរនោះគេយកសំបុកសូត្រពីរតំបរ បីតំបរ ឬប្រាំមួយតំបរ គឺធ្វើតាមតែគេត្រូវការតិច ឬច្រើនដាក់ក្នុងឆ្នាំងកុងសូត្រ ដើម្បីឲ្យសរសៃសូត្រនោះរីកស្មើល្អ។ លុះស្រាវសូត្រអស់ហើយ ទើបយកទៅលាងទឹកច្រើនដង ដើម្បីឲ្យអស់រំអិល រួចយកទៅហាលឲ្យស្ងួត នៅពេលស្ងួតហើយគេយកទៅថ្លឹងមើលដើម្បីប៉ាន់ទម្ងន់ក្នុងការផលិតមួយលើកៗ តើបានផលប៉ុន្មានសាច់សូត្រ។

នៅចុងក្រោយផលិតផលសំរេចគេចាប់រើសសូត្រ មើលសរសៃតូចដាក់ដោយឡែក និងសរសៃធំដាក់ដោយឡែក ហើយយកទៅរុំដាក់ក្នុងអាក់រវៃ(កុង)មួយសារទៀត រួចគេយកទៅប្រមោក នឹងទឹកក្បុង លាងឲ្យបាន បួន ឬប្រាំដង ទាល់តែជ្រះសូត្រល្អ ទើបយកទៅហាលឲ្យស្ងួតទុកជាការស្រេច។



រូបភាពការស្ងោរសំបុកដង្កូវនាងដើម្បីស្រាវយកសរសៃអំបោះសូត្រ



រូបភាពការស្ងោរសំបុកដង្កូវនាងដើម្បីស្រាវយកសរសៃអំបោះសូត្រ



រូបភាពការស្ងោរសំបុកដង្កូវនាងដើម្បីស្រាវយកសរសៃអំបោះសូត្រ

### ៤.៤. វិធីធ្វើក្បុង

យើងអាចទទួលស្គាល់អំពីរុក្ខជាតិដែលមានផលប្រយោជន៍ដ៏សំខាន់ជាច្រើន ដែលប្រជារាស្ត្រខ្មែរនិយមយកមកធ្វើក្បុង ហើយអាចឲ្យគេយកមកប្រមោកសូត្រសម្រាប់ធ្វើឲ្យសូត្រជ្រះបានល្អមុននឹងយកទៅជ្រលក់ល័ក្ខ។ ហើយរុក្ខជាតិទាំងនោះ ច្រើនតែសំបូរនៅតាមតំបន់ស្រុកភូមិ ដែលគេច្រើនប្រើវាតាមសេចក្តីត្រូវការ តែក្នុងការសិក្សាពេលនេះ យើងសូមលើកយកតែរុក្ខជាតិដែលដុះតាមចំការ និង ជុំវិញផ្ទះ គឺផ្ទីបន្លា និង សំបកចេកទុំ គេយកទៅហាលថ្ងៃឲ្យស្ងួតល្អរួចប្រមូលយកទៅដុតឲ្យទៅជាផេះ ហើយគេយកកញ្ច្រែង ឬស្បៃវែងទទាក់ឲ្យស្អាតទើបយកទៅដាក់ក្នុងកូនពាងដាក់ឲ្យពេញគ្របទុកឲ្យបានយូរថ្ងៃ ទាល់តែវាចេញជាតិរំអិលទើបគេអាចយកមកប្រមោកសូត្របាន។



រូបភាពដើមផ្ទីបន្លា

### ៤.៥. វិធីប្រមោកសូត្រ

នៅពេលទឹកក្បុងអាចប្រើការបានហើយ គេដួសយកទឹកក្បុងដែលរងថ្លាល្អ ដាក់ក្នុងឆ្នាំងធំមួយ ដាំឲ្យពុះទើបយកសូត្រទៅជ្រលក់ឲ្យសព្វ បន្ទាប់មកគេស្រង់យកទៅដាក់ក្នុងឡាំងស៊ីងរៀបវាឲ្យត្រឹមត្រូវល្អ ទើបយកទៅចំហុយចំនួនមួយធូប រួចទើបស្ទាបមើល បើសរសៃសូត្រល្អិតស្មើឡើងរលោងល្អ ទើបយើងដឹងថាសូត្រនោះជ្រះសំបក ហើយគេយកចានដែកធំមួយចាក់ទឹកឲ្យពេញ ស្រង់សូត្រមកត្រាំចំនួន ៥នាទី រួចចាក់ទឹកចោល គេធ្វើដូចនេះទាល់តែគម្រប់ ៥ដង តែពុំអោយច្បូតសូត្រទេ ព្រោះខ្លាចបែកសរសៃសូត្រ រួចគេពួតវាឲ្យស្រស់ទឹកកន្ត្រាក់វាឲ្យស្មើសរសៃ ហើយគេយកឈើពីងពង់ មកដោកតំរៀបហាលថ្ងៃទាល់តែវាស្ងួតល្អ។ នៅចុងបញ្ចប់ការងារ គេយកសូត្រទៅថ្លឹងមើលម្តងទៀត តើទម្ងន់វាខុសពីទម្ងន់ដើមប៉ុន្មាន រួចហើយគេរើសសរសៃតូចដាក់ដោយឡែក ធំដាក់ដោយឡែក។ សរសៃសូត្រទាំងពីរមុខនេះគេយកទៅប្រើការខុសៗគ្នា គឺសូត្រសរសៃតូចដាក់ធ្វើជាថាន (ហៅថាផ្ទៃ) ឯសរសៃធំ យកមកចងធ្វើជាហូល។



ការប្រមោកសរសៃសូត្រ





ការប្រមោកសរសៃសូត្រ

## ៤.៦. វិធីធ្វើល័ក្ខខ្មែរ

ក្នុងការច្នៃប្រឌិតវុក្ខជាតិដែលឲ្យផលប្រយោជន៍ដល់ការផលិតសូត្រឲ្យមានគុណភាពល្អ ពុំចេញពណ៌ ប្រើប្រាស់បានយូរ ពុំខ្ទេចសាច់សំពត់ គឺអាស្រ័យលើការប្រើបច្ចេកទេសបទដ្ឋានត្រឹមត្រូវ។

ការរកឃើញនូវសំបកឈើជាច្រើនប្រភេទ ដែលមានតិចតួច នៅតាមខេត្ត និងតំបន់ខ្លះៗក្នុងប្រទេស គេអាចចំរាញ់ពីសំបកឈើទាំងនោះចេញជាពណ៌ប្លែកៗដូចជា ពណ៌លឿង បៃតង ខៀវ ស្វាយ ចំណែកសំបកឈើដែលគេយកមកធ្វើល័ក្ខស្រម៉ ឬល័ក្ខខ្មែរ ល័ក្ខត្បែង ល័ក្ខព្រហ៊ូត ល័ក្ខគ្រាប់ជំពូ ល័ក្ខឃ្នាស់។ យើងសូមលើកយកវិធីធ្វើល័ក្ខព្រហ៊ូត ដែលមានក្នុងចំណោមល័ក្ខមួយចំនួនដូចរៀបជូនមកស្រាប់ គឺគេស្ងួសយកសំបកព្រហ៊ូតមកចិញ្ច្រាំឲ្យល្អិត ឬយកទៅដាន់នឹងត្បាល់ក្តឿងឲ្យបានម៉ត់ល្អ រួចយកទៅស្ងោរក្នុងឆ្នាំង ឬខ្ទះឲ្យទាល់តែពុះចេញជាតិជ័រ ហើយស្រង់កាកចោល និងយកស្បៃត្រងឲ្យស្អាត ទើបបានជាល័ក្ខល្អ រួចគេច្រកដបទុកជាការស្រេច។



រូបភាពសំបកដើមព្រហ៊ូតកាប់ចិញ្ច្រាំ



រូបភាពសំបកដើមព្រហ៊ូត



រូបភាពល័ក្ខជុំក្រលង់

## ៤.៧. វិធីចងល័ក្ខ ឬបន្ទំល័ក្ខ

របៀបចងល័ក្ខ ឬបន្ទំល័ក្ខនេះគឺជាមុខរបរមួយសំខាន់ដែរ ក្នុងការចិញ្ចឹមល័ក្ខទុកឲ្យបានរស់បន្ត និងងាយក្នុងការយកវាមកចម្រាញ់ ធ្វើពណ៌ថែមទៀត។ ជាដំបូងគេយកក្រម៉ល័ក្ខ ដែលសត្វល្អិតជាមេដាក់ក្នុងសំបក រួចកាត់ស្នឹកឆ្នោតជាដើម ចងភ្ជាប់នឹងឈើរស់ មានដើមសង្កែ ដើមត្រាង ដើមស្ពួលជាដើម ដើម្បីឲ្យមេនោះវារោមមែកឈើ កកើតចេញជាក្រម៉ល័ក្ខតទៅទៀត។ ចំពោះជ័រខៈរឹង កើតអំពីសត្វល្អិតមួយពួកមានសម្បុរក្រហម សំរាប់ប្រើការជ្រលក់សូត្រអំបោះជាដើម គឺល័ក្ខស្រម៉ ចំណែកកាកល័ក្ខ ឬអាចម៍ល័ក្ខ កាករបស់ល័ក្ខស្រម៉ដែលគេស្ងោររំងាស់អស់ជាតិហើយ គឺសំរាប់ប្រើការផ្សារភ្ជាប់អ្វីផ្សេងៗ (ល័ក្ខដុំកន្ទង់ គឺស្រម៉ល័ក្ខដែលដុះព័ទ្ធស្រោមជុំវិញមែកឈើ)។

## ៤.៨. វិធីជ្រលក់ល័ក្ខចិន

ជាដំបូងគេយកឆ្នាំងធំមួយដាំទឹកឲ្យពុះ រួចយកល័ក្ខតាមពណ៌ដែលគេត្រូវការទៅបង់ក្នុងទឹកកូរឲ្យសព្វទាល់តែរលាយគ្រាប់ល័ក្ខអស់ រួចគេដាក់ឆ្នាំងនោះចុះក្រោមវិញ ទុកទឹកនោះឲ្យក្តៅឧណ្ហៗ រួចគេយកសាច់ជូទៅបង់ បន្ទាប់មកទើបយកសូត្រមកជ្រលក់ក្នុងទឹកល័ក្ខ ហើយជ្រលក់ឲ្យសព្វប្រយ័ត្នកុំឲ្យវាធ្ងុក ជ្រលក់រួចហើយពូតវា កន្ត្រាក់ ឬរលាស់ឲ្យស្មើសរសៃសូត្រល្អ ហើយយកទៅស៊កស្នូរពីងពង់ហាលថ្ងៃឲ្យស្ងួតល្អទើបយកទៅប្រើប្រាស់បាន។

## ៤.៩. វិធីរៀបចំតម្បាញសូត្រខ្មែរ

ក្នុងសិល្បៈតម្បាញសូត្រខ្មែរគឺជាសិប្បកម្មមួយដ៏រស់រវើកពុំអាចសាបសូន្យក្នុងទស្សនៈប្រជារាស្ត្រខ្មែរទាំងមូល។ អ្នកទាំងអស់នោះ តែងតែស្គាល់នូវកស្តុតាងប្រពៃណីខ្មែរ និង ទំនៀមទំលាប់របស់ខ្លួនជានិច្ចទាំងអស់នេះជាក្បូនខ្នាតនៃសិប្បកម្មប្រើដោយដៃសុទ្ធសាធរបស់នារីខ្មែរដែលផលិតនូវគ្រឿងសម្លៀកបំពាក់ប្រពៃណីជាតិហើយវាអាចជួយសេដ្ឋកិច្ចគ្រួសារទាំងមូលបានក្នុងការ ធ្វើសិប្បកម្មតម្បាញនេះទៀតផង។ ចំពោះប្រព័ន្ធផលិតកម្មតម្បាញមានភាពយឺតយ៉ាវ ពុំអាចធ្វើបង្ខំតាមចិត្តចង់បានទេ ព្រោះត្រូវអនុវត្តតាមចង្វាក់និមួយៗ មានពេលវេលាកំណត់ត្រឹមត្រូវ ហេតុដូច្នេះយើងសូមបកស្រាយនូវការឆ្វេងកាត់ការងាររលំបាកៗទាំងឡាយជាមុនសិន មុនគេឡើងលើកីតម្បាញ។

### ៤.១០. វិធីរវៃសូត្រអន្ទង

ក្នុងការធ្វើសូត្រអន្ទង ចំពោះឧបករណ៍ចាំបាច់របស់គេគឺ រហាត់រវៃ គឺមានរហាត់តូច ឬ ធំនិង បំពង់ឡូតជាច្រើន (បំពង់ធ្វើអំពី បំពង់ឫស្សី កាត់ជាកង់ៗយ៉ាងស្អាត) បំពង់ឡូតនោះមានប្រវែង ២ ស.ម ទទឹង ០,៥ ស.ម ។

ជាដំបូងគេយកសូត្រដែលគេជ្រលក់ពណ៌រួចហើយមករវៃដាក់ឡូត ហើយបានយកមកកុងបញ្ចូលក្នុងកុង ។ កុងរួចត្រូវយកវាទៅប្រមោក ជ្រលក់ទឹកក្បុងដែលស្ងោរពុះធ្វើឲ្យសព្វល្អរួចស្ទាបមើលបើឃើញសរសៃសូត្រនោះស្អិត ត្រូវស្រង់ដាក់ចានដែកលាងនឹងទឹកត្រជាក់ បីឬបួនដងទាល់តែស្អាតល្អ។



ឧបករណ៍សម្រាប់អន្ទងសូត្រ





រូបភាពរវៃសូត្រអន្ទង៍

## ៤.១១. វិធីជ្រលក់គៀត

ការជ្រលក់គៀតត្រូវយកសូត្រទៅត្រាំនឹងទឹកល័ក្ខពណ៌ តាមចិត្តដែលគេចង់បានរយៈពេល ២៤ម៉ោង ទើបគេយកមកគក់ច្របាច់ឲ្យល័ក្ខពណ៌ចូលសព្វល្អក្នុងសាច់សូត្រ ទើបយកទៅហាលថ្ងៃ (ក្នុងល័ក្ខ ៣គីឡូ ជ្រលក់បានសំពត់២)។

តំណមៈ ហាមមិនអោយស្ត្រីមានផ្ទៃពោះ មកក្បែរកន្លែងជ្រលក់។



រូបភាពការជ្រលក់ពណ៌គៀត



ដុំគៀតត្រៀមជ្រលក់ពណ៌



សរសៃសូត្រដែលជ្រលក់ពណ៌ហើយ

## ៤.១២. វិធីរវៃសូត្រដាក់ត្រល់

ក្នុងការរវៃសូត្រដាក់ត្រល់អ្នករវៃត្រូវចេះលៃលកកំលាំងដៃរវៃដោយថ្នមៗ ពុំអាចបង្ខំតាមចិត្តបានទេ ព្រោះសូត្រមានសរសៃឆ្មារងាយនឹងដាច់ៗ ការមានតំណរលើសរសៃសូត្រច្រើន វាអាចផ្តល់ផលមិនល្អក្នុងការចាក់ធ្មេញកី និងត្បាញ ហើយវាអាចឲ្យយឺតដំណើរក្នុងការងារនោះផងៗ ក្នុងការរវៃសូត្រដាក់ត្រល់ត្រូវធ្វើយ៉ាងណាឲ្យសរសៃសូត្ររាងដូចខ្នងអណ្តើកៗ ចំពោះរហាត់រវៃមានច្រើនធុន គឺរហាត់រវៃ រហាត់ត្រល់ និងរហាត់ខា ។

## ៤.១៣. វិធីខាសូត្រអន្ទង

យើងខារសូត្រពីអាក់ បញ្ចូលក្នុងបំពង់ រួចត្រូវរាប់មុខតឲ្យបានជាផ្លូន (ធ្មេញឈើត្រូវរាប់តាមសូត្រ) ចំពោះឈើ ៣០ ត្រូវរាប់ដាក់មុន ៣០ ដៃរក្នុងមួយផ្លូនមានធ្មេញ ១០ដំបរ មាន ៤ ធ្មេញ គេរៀបចំតាមក្បួនខ្នាតត្រឹមត្រូវហើយទើបគេយកទៅអន្ទងចាក់ធ្មេញឈើ ។

## ៤.១៤. វិធីខាសូត្រចាក់

សិល្បៈរវៃអំបោះនេះ ជាបច្ចេកទេសថ្នាក់ទី១ មានសមត្ថភាពទាបជាងគេ ហើយជាការងារសំរាប់មនុស្សចាស់កំលាំងខ្សោយៗ ជាដំបូងគេយកសូត្រដែលធ្វើរួចមកខាដាក់ខ្នារតូចៗ មានបណ្តោយ ១០ស.ម (ទំហំ ១ស.ម) ហៅថាខ្នាសិកត្រល់បបុស ខ្នារនោះគេដាក់ត្រល់វែងដែលមានប្រវែង ២០,៥ស.ម (ធ្វើពីឫស្សីបិទមូលដូចចង្កឹះ) រួចទើបយកមកសិកត្រល់ទុកត្បាញ (ធ្វើពីឫស្សីពក) ។

## ៤.១៥. វិធីចងគៀតហូល

គេអាចទទួលស្គាល់នូវវប្បធម៌ ដ៏ខ្ពង់ខ្ពស់របស់ជនជាតិខ្មែរយើងតាមរយៈឧបករណ៍ តុបតែងគ្រប់បែបយ៉ាង ជាពិសេសគឺសំលៀកបំពាក់ដែលធ្វើពីសូត្រមានសំពត់ហូលដែលមានក្បាច់ជាក្រឡាស្រកាពស់ (ពស់ថ្លាន់) មានក្បាច់ផ្កាចាន់ ស្ទឹកទេស និងមានបញ្ចុះគោមរូបសត្វផ្សេងៗ យ៉ាងល្អប្រណិត រំលេចទៅដោយពណ៌ក្រហម លឿងក្ទីរទ្វាល មើលពីចំងាយគួរឲ្យគយគន់ៗ នៅលើផ្ទៃដែលមានបញ្ចុះពណ៌នៃក្បាច់ដ៏ប្លែកៗនេះមានអត្ថន័យខ្ពស់ចំពោះសូត្រនាគ តំណាងឲ្យសូត្ររស់នៅក្នុងទឹក និងលើដី តំណាងភេទស្រី និងភេទប្រុស ហើយជាតំណាងនៃដូនតាទាំងមូលៗ

សត្វពស់មិនស្លាប់ មិនសាបសូន្យ ជាដូនជាតា វង្សត្រកូលខ្មែរ ឲ្យនូវភាពរុងរឿងជាមេបា ជានិរន្តរ៍ (ពូជខ្មែរមិនដែលសូន្យ ភាពអមតៈ)។

យើងសូមយកវិធីចងគៀតហូលមកបកស្រាយដោយសង្ខេប ដើម្បីជូនជាគំនិតខ្លះៗ ដល់អ្នកមាននិស្ស័យ និងចំណូលចិត្តក្នុងប្រព័ន្ធសិល្បៈបែបនេះ។ ទេពកោសល្យក្នុងការច្នៃប្រឌិតអាស្រ័យលើសិល្បករមានបទពិសោធន៍ ចេះស្គាល់ពណ៌ និងក្បាច់ក្បូរច្បាស់លាស់មានការរហ័សរហួនក្នុងការចងគៀតឲ្យបានល្អ ហើយធ្វើយ៉ាងណាកុំឲ្យខុសក្បួនតម្រាផងដែរ។ ចំពោះការតម្លើងរូបភាពត្រូវប្រើពេលវេលា ពី ៥ ទៅ ១០ថ្ងៃ តាមគោមធំ ឬតូច ញឹក ឬរង្វើល។

ជាដំបូងយើងយកសូត្រមកព័ទ្ធនឹងស្នឹង ដែលមានបណ្ដោយ ១,២ម និងកំពស់ដងស្នឹង ៦០ស.ម ចងជាខ្នារ (១ ខ្នារមាន ៤៨សរសៃ) មានច្រើន ឬតិច តាមគោមតូច ឬធំ។ ចំពោះគោមតូចមាន ១៨ខ្នារ ចំណែកគោមធំមាន ២៥ខ្នារ រួចគេចងច្នៃជាផ្ការអ្វីក៏បានតាមការស្រឡាញ់ (ផ្កាក្បាច់មានច្រើនមុខ)។ ចំពោះខ្សែសំរាប់ចងគៀតគឺគេយកស្រទបចេកជ្វាមកហាលថ្ងៃឲ្យទន់ រួចឆ្កូតជាសរសៃតូចៗល្មម លាងទឹកឲ្យស្អាតយកទៅហាលថ្ងៃឲ្យស្ងួត រួចចងជាបាច់ទុកជាការស្រេច ។ គេយកស្រវាចេកដែលធ្វើរួចមកចងរុំសរសៃសូត្រតាមក្បាច់ផ្កា ដែលគេស្រឡាញ់ ចងរុំហើយជ្រលក់ល័ក្ខពណ៌រួចយកទៅហាលឲ្យស្ងួត កាត់ចំណងចេញ។ គេធ្វើរបៀបនេះ ជាច្រើនលើក ច្រើនសារ ហើយប្រើពណ៌ជាច្រើនតាមសេចក្ដីត្រូវការរបស់គេ បន្ទាប់មកគេខាដាក់ខ្នារទុកយកមកត្បាញ ដោយតម្រឹមគ្នាឲ្យស្មើសរសៃសូត្រល្អ។

## ៤.១៦. វិធីធ្វើល័ក្ខជ្រលក់ហូល

យើងត្រូវទទួលស្គាល់នូវរបៀបរបប ប្រពៃណីចាស់ទុំយើងដែលបាន ប្រៀនប្រដៅឲ្យកូនចៅចងចាំទុកជាកេរ្ដិ៍ដំណែលតរៀងមក នូវសិល្បវិធីធ្វើល័ក្ខជ្រលក់ហូលនេះត្រូវមានរូបមន្តត្រឹមត្រូវ ច្បាស់លាស់ទើបការផលិតមានគុណភាពល្អ។

ជាដំបូងគេយកសំបកក្រម៉ មកបុករួចយកទៅត្រាំទឹកឲ្យបាន ២ ឬ៣ យប់ដើម្បីឲ្យទន់សំបកល្អ។ បន្ទាប់មកគេស្រង់យកស្រម៉នោះមកដាក់ក្នុងត្បាល់យកអង្រែក្រលុកឲ្យទន់ រួចដួសទឹកក្ដៅដែលដាំពុះចាក់ក្នុងនោះ ដើម្បីឲ្យវាចេញជ័រល័ក្ខ រួចដួសយកទៅទុក។ គេធ្វើដូច្នេះជាច្រើនដងទាល់តែគ្រប់ចំណុះ។ ចំណែកកាករបស់វា (អាចម៍ល័ក្ខ)គេយកមកទុកគ្រាន់នឹងភ្ជួរកាំបិត។ វិធីយកល័ក្ខពណ៌ទៅជ្រលក់ហូល គឺគេថ្លឹងល័ក្ខចំនួន ១គីឡូ និង សាច់ជូរ ០,៨គីឡូតែបើ

សិនជាជ្រលក់ចូលមិនសព្វល្អទេ គេត្រូវយកស្លឹកអំពិលមកស្ងោរយកទឹក រួចជ្រលក់ឲ្យសព្វទើបពណ៌ឡើងស្រស់ថែមទៀត។

## ៤.១៧. វិធីតម្បាញក្រមាខ្មែរ

សិល្បៈខ្មែរប្រភេទនេះមានលក្ខណៈរស់រវើកក្នុងចំណោមសិល្បៈខ្មែរទាំងអស់ដែលប្រជារាស្ត្រយើងច្រើននិយមយកមកធ្វើអាជីវកម្មប្រចាំគ្រួសារ ហើយមានបច្ចេកទេសងាយស្រួលក្នុងការយកមកអនុវត្តផង។ ហេតុដែលសិល្បៈធ្វើក្រមា នេះមានការរីកចំរើនខ្លាំងជាងគេ គឺមកពីប្រជារាស្ត្រខ្មែរមានទម្លាប់មួយ ដែលយកក្រមាមកប្រើប្រាស់ផ្ទាល់ខ្លួនប្រចាំថ្ងៃ។ ក្រមាខ្មែរយើងមានលក្ខណៈច្រើនយ៉ាង មានគុណភាពខុសគ្នា គឺត្បាញអំពីសូត្រ និងអំពីអំបោះធៅ។

## ៤.១៨. វិធីចាក់ធ្មេញឈើ

គេយកសូត្រដែលអន្ទង់រួច មកមូរដាក់ក្តារបន្ទះមួយប្រវែងមួយម៉ែត្រកន្លះ (ហៅថាដាម) រួចយកមកចាក់ធ្មេញឈើដាក់ឲ្យបានល្អ ទើបយកជាងចេកមកកាត់ប្រវែងពីរចង្អាមខ្ចីល្មម និងប្រដោលវាមកសិកចុងដាមទាំងសងខាងដើម្បីការពារកុំឲ្យវារបូត និងនាំឲ្យព័ន្ធដាមពិបាកធ្វើការផង។ បន្ទាប់មកគេយកឧបករណ៍មួយឈ្មោះកណ្តូប ដែលមានមុខស្រួចធ្វើអំពីស្នែង មានទំពក់តូចស្តើងយកមកចាក់ចូលធ្មេញឈើ និងថ្កក់សូត្រមកដាក់ក្នុងកន្ទុយដង្កូវ។ នៅពេលដែលគេចាក់រួចទើបគេយកមកចង និងផ្សុះលើកដាក់កី។ ការត្បាញហូលមានតែដង្កូវកំណើតឥតមានផ្កាទេ។

ចំពោះធ្មេញឈើសំរាប់ចាក់មានធ្មេញ ៤០ ចាក់បានតែ ១០ម ទេ។ ចំណែកធ្មេញឈើធ្វើសារុងសូត្រវិញ មាន ១,១០ម ត្រូវប្រើធ្មេញចំនួន ៥០។

ចំពោះការថ្កូរដង្កូវផ្កា គឺគេយកដង្កូវមកថ្កូរជាមួយបន្ទូលដង្កូវដែលមានប្រវែង ១,១០ម ឬ ១,២០ម។ ចំណែកការរើសផ្កាក្បាច់មកថ្កូរ គឺគេរើសជាផ្កាសិន ទើបបានគេថ្កូរជាក្រោយ ការថ្កូរនេះ គេថ្កូរដូចដង្កូវកំណើតដែរ គឺគេរើសជាតំបរ មាន ៤សរសៃ ក្នុង ២ធ្មេញ រួចទើបរើសមកថ្កូរ។ រើសថ្កូររួចហើយបានគេថ្កូរត្បាញ។

## ៤.១៩. វិធីរើសជរជើង និងផ្កា

ការរៀបចំការងារលើកនេះ គេរាប់ជាការសំខាន់បំផុត ហើយត្រូវមានការប្រុងប្រយ័ត្ន និងពិនិត្យសារចុះសារឡើង ជាច្រើនដងក្នុងការបញ្ចុះក្បាច់។ ជាដំបូងគេយកធ្មេញឈើ ដាមតូច

សំប៉ែតដែលគេរាប់ធ្វើផ្កាត្រឹមត្រូវច្បាស់លាស់ហើយ ទើបយកដង្ករមកថ្ករ និង គួបកន្ទុយដង្ករ ឯកន្ទុយដង្ករថ្ករ និងជរជើងនេះច្រើនជាងថ្ករកំណើតទៅទៀត។

ចំពោះកស្តុតាងទាំងឡាយដែលពិភពលោកបានទទួលស្គាល់ក្នុងប្រវត្តិសាស្ត្រគឺតាមរយៈសិល្បៈដែលបញ្ជាក់ពីចរិតជាខ្មែរ កើតចេញពីប្រជារាស្ត្រខ្មែរពិតៗ នៅស្រុកស្រែចំការគេនិយមប្រើប្រាស់ក្រមាដាក់តាមខ្លួនជានិច្ច និងប្រើក្នុងពិធីបុណ្យទាននានា។ ដូច្នេះក្រមាជារបស់ចាំបាច់បំផុតរបស់ខ្មែរយើងគ្រប់ៗគ្នា។

ជាដំបូងគេយកអំបោះនៅទៅគក់នឹងទឹកឲ្យសព្វល្អរួចយកទៅត្រាំទឹកឲ្យបានពីរយប់ទើបស្រង់យកមកពូតទឹកឲ្យស្រស់ បន្ទាប់មកគេដាំទឹកល័ក្ខឲ្យពុះដាក់សាច់ដូវចូលកូរឲ្យសព្វ រួចយកអំបោះនោះមកជ្រលក់ដូចជ្រលក់សូត្រអញ្ចឹង ហើយស្រង់ពូតទឹកឲ្យស្រស់។ លើកទីពីរត្រូវដាំទឹកល័ក្ខម្តងទៀតលាយកុំឲ្យខាប់ពេក ឬរាវពេកទើបយកអំបោះមកជ្រលក់ឲ្យស្មើពណ៌កុំឲ្យធ្លុកដោយត្រាំរំងាស់ចំនួន ៥នាទី ត្រូវលើកបង្វិលម្តងប្រយ័ត្នកុំឲ្យខ្វាចអំបោះ បន្ទាប់មកយកទៅជ្រលក់ទឹកម្សៅពូតឲ្យស្រស់ទឹក កន្ត្រាក់ឲ្យស្មើសរសៃល្អរួចដាក់ក្នុងឡាំងស៊ីងចំហុយ ដោយដាក់ទឹកល្មមកុំឲ្យដោល ប្រសិនបើដោលឡើងច្រើនលើកអាចធ្វើឲ្យអំបោះខូចបាន។

ពេលចំហុយអំបោះត្រូវប្រើរយៈពេលមួយធូប ទើបស្រង់យកមកកន្ត្រាក់ហាលថ្ងៃ ឲ្យស្ងួតល្អ ទើបមកខាដាក់បំពង់អន្ទងធ្មេញឈើក្រមារួចជាស្រេច។ ធ្មេញឈើអន្ទងមានចំនួន ២០គត់មិនប្រើដូចធ្មេញឈើហូលទេ។

## ៤.២០. វិធីធ្វើស្នឹងប៉ាក់ឌិន

សិល្បៈប៉ាក់ឌិននេះជាជំនាញមួយខ្ពស់ និងមានតម្លៃជាងគេក្នុងចំណោមការងារស្រាលរបស់នារីខ្មែរ តែពុំសូវមានអ្នកនិយមធ្វើ និងចេះច្រើនដូចជាសិល្បៈដទៃទេ។ សិល្បៈប្រភេទនេះនៅរក្សាទ្រង់ទ្រាយបានមកដល់សព្វថ្ងៃនេះ គឺមកពីសិល្បៈល្ខោនខ្មែរ ដែលគេនិយមប្រើលើសំលៀកបំពាក់ និងគ្រឿងតុបតែងលំអរកាយសំរាប់ អាពាហ៍ពិពាហ៍ ដែលជាប្រពៃណីខ្មែរយើង។ ចំពោះឧបករណ៍សម្ភារផលិត គឺច្រើនទិញមកពីប្រទេសក្រៅដែលមានគុណភាពល្អ អាចរក្សាទុកបានយូរ និងមានតម្លៃខ្ពស់ទៀតផង។ សម្ភារទាំងនោះ មានក្រណាត់សំពត់កាំម្ទីគ្រប់ពណ៌ ឌិនមូល (ភ្នែកមាន់) ឌិនសែសយ តូចធំ អង្កាំគ្រប់ពណ៌។ល។ គេនិយមប្រើ ពណ៌លឿង (ពណ៌មាស) រំលេចលើផ្ទៃពណ៌ចាស់ ដើម្បីបញ្ចេញពន្លឺទាក់ទាញភ្នែកគួរឲ្យគយគន់ គេច្រើនយក

ក្បាច់ស្លឹកទេស (ភ្ញីទេស) ផ្កាចាន់ ផ្កាក្រចាប់។ល។ មកលម្អតាមចិត្តស្រឡាញ់។ រាល់ការដេរប៉ាក់ឱន គេផលិតមានរយៈពេលតិច ឬច្រើនអាស្រ័យតាមការស្រឡាញ់និយមប្រើក្បាច់ រង្វើល ឬញ្ញឹក តែមានភាពរស់រវើក។ សិល្បៈផ្នែកដេរប៉ាក់នេះមានលក្ខណៈបច្ចេកទេសពីរយ៉ាងគឺ សិល្បៈដេរប៉ាក់អំពីអំបោះ (អំបោះត្រង់ពណ៌) និងសិល្បៈដេរប៉ាក់អំពីឱន។ ចំពោះសិល្បៈដេរប៉ាក់ នារីខ្មែរច្រើននិយមយកមកប្រើប្រាស់ច្រើនជាងគេ ហើយអាចយកមុខរបរនេះទៅជួយក្នុងជីវភាពគ្រួសារបានទៀតផង។ សិល្បៈដេរប៉ាក់មានឥទ្ធិពលខ្ពស់ជ្រួតជ្រាបទៅលើសង្គមខ្មែរទាំងមូល ជាពិសេសនារីខ្មែរដែលជាគំរូមួយដ៏ល្អមកលើសង្គមគ្រួសារមានចរិយាសម្បត្តិ គុណធម៌ និងសីលធម៌ ដែលឆ្លុះបញ្ចាំងតាមរូបភាពសិល្បៈនៃការដេប៉ាក់នេះឯង។ ក្នុងភាពរស់រវើកទាំងឡាយ ជាសុភមង្គល និងខន្តីដែលជាស្ត្រី (មេផ្ទះ) ត្រូវរក្សាកេរដំណែលនេះឲ្យបានគង់វង្សជារៀងរហូត។

សិល្បៈប៉ាក់ឱនខ្មែរ គឺមានឧបករណ៍ពីឈើស្នឹងមួយមានកំពស់៣០ស.ម បណ្ដោយ ១ម ទទឹង ០,៥ម តូចល្មមគេអាចអង្គុយព័ទ្ធជុំវិញប៉ាក់បាន។ គេយកក្រណាត់មួយផ្ទាំងមកដេរជើងសងខាង ស៊កនឹងឈើប៉ុនកូនដៃ យកទៅចងនឹងឈើស្នឹងរឹតឲ្យតឹងល្អ រួចចាប់ផ្ដើមផ្ដាមក្រឡាក្បាច់តាមចិត្តដែលចង់បាន។

បន្ទាប់មកទើបចាប់ប៉ាក់ដាក់ក្បាច់ក្បូរ តាមគំនូរផ្ដាមនៅលើនោះ។ គ្រឿងប៉ាក់ឱនមានច្រើនយ៉ាងដូចជា ប៉ាក់គ្រឿងស្បៃ ផាហ៊ុម (ល្ខោន) ប៉ាក់ខ្នើយ វាំងននៗល។

ចំពោះផលិតផលសិល្បៈ ដែលធ្វើអំពីសូត្រខ្មែរមាន៖ សារុងសូត្រ ក្រមាសូត្រ ហូល ផាមួង អន្ទូញ ឃៀន ឯក្បាច់ដែលគេដាក់ទៅលើផ្ទៃសំពត់នោះមាន៖ បន្តក់ជរជើង ផ្កាយព្រឹក ផ្កាម្ទេស ផ្កាសន្ទាន់ មេអំបៅ ផ្កាទទឹម ថ្នក់ល្ខោន ថ្នក់នាគ គោមពេជ្រ ផ្កាប្រាក់ ក្រឡាកញ្ចក់ ផ្កាឃៀន ចរបាប់ ខ្នង់ ផ្កាចាន់ ផ្កាក្រចាប់ ផ្កាថុល ផ្កាម្ទិះ ផ្កាគ។ល។

អំពីព្រៃចរបាប់៖ មានត្រូករ ៨, ៩, ១០, ១២, ១៥, ១៧, ២០ និង២៥ (ធ្វើសូត្រពណ៌ស ឬលឿងក៏បាន)។

អំពីផាមួង ៖ មានត្រូករ ២ ឬ៣។

អំពីអន្ទូញ ៖ ស្រង់លឿង លឿងប្រទះ ម៉ត់ឡាំ។

ការធ្វើអត្ថាធិប្បាយនូវមុខវិជ្ជាបច្ចេកទេសសិល្បៈតម្បាញនេះ យើងមិនអាចសរសេរ និងវិភាគអោយបានល្អិតល្អន់ទាំងអស់នោះបានទេ ដោយមានចំណុចបច្ចេកទេសមួយចំនួនពុំអាចរៀបរាប់បានឡើយ។ យើងបានស្រាវជ្រាវជាអត្ថបទតូចមួយនេះតាមលោកអ្នកចាស់ទុំ ដែលចេះចាំតពូជពង្សរបស់គាត់មកហើយនឹងមានមូលដ្ឋានសិប្បកម្មត្រឹមត្រូវ ដូចជានៅស្រុក ភ្នំស្រុក ខេត្តបន្ទាយមានជ័យ (អតីតខេត្តបាត់ដំបង) ខេត្តតាកែវ ខេត្តកណ្តាល (កោះដាច់ ព្រែកថោង ព្រែកចង្រ្កាន)។ល។

នៅបណ្តាតំបន់មួយចំនួនបានរក្សានូវប្រពៃណីរបស់ខ្លួនបានល្អ ដោយការពឹងផ្អែកនឹងការទំនាក់ទំនងគ្នាពីមួយទៅមួយ ហេតុដូច្នេះហើយបានជាផលិតផលគុណភាពល្អ មានឈ្មោះល្បី ដែលយើងអាចយកមកធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយឡើង។ ក្នុងទស្សនៈសិល្បករ គឺចង់បង្ហាញឲ្យជំនាញតម្បាញនេះ មានការទទួលស្គាល់នៅក្នុងស្មារតីរបស់ប្រជាពលរដ្ឋខ្មែរទាំងមូល និងឲ្យតម្លៃទៅលើសិល្បករខ្មែរយើង ដែលរក្សាបាននូវខ្នាតមួយរបស់វប្បធម៌ជាតិ ហើយស្នាដៃដ៏ពិសិដ្ឋនេះ យើងត្រូវនាំគ្នាសិក្សាបន្តកុំឲ្យបាត់បង់ និងយកមកប្រើប្រាស់ជាប្រពៃណីជារៀងរហូតដើម្បីឲ្យអ្នកក្រៅគេស្គាល់ថា អ្វីជារបស់ខ្មែរពិតៗ។




ផែនទីបង្ហាញអំពីតំបន់ដែលមានសក្តានុពលនៃផលិតកម្មសូត្រក្នុងឆ្នាំ២០១៧

## ២. ប្រវត្តិ និងបច្ចេកទេសតម្បាញហូល

### ១. ប្រវត្តិតម្បាញហូល

សិប្បកម្មតម្បាញសូត្រជាផ្នែកមួយសំខាន់នៃប្រវត្តិសាស្ត្រនិងជាផ្នែកមួយទៀតនៃវប្បធម៌រស់នៅរបស់ប្រជាជនខ្មែរ។ តម្បាញសូត្រ និងផលិតផលសូត្រ មានសារសំខាន់សម្រាប់ខេត្តប្រាំដែលមានភាពលេចធ្លោជាងខេត្តផ្សេងៗទៀត។ សូត្រដែលមានការច្នៃម៉ូតដ៏ល្បី និងគុណភាពខ្ពស់គឺ ខេត្តតាកែវ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ព្រៃវែង និងខេត្តកំពត។ ពីមុនផលិតផលធ្វើពីសូត្រគេអាចប្រើប្រាស់បានសម្រាប់តែពូជពង្សស្តេច និងអ្នកមានវណ្ណៈខ្ពង់ខ្ពស់ តែមកដល់សព្វថ្ងៃនេះផលិតផលតម្បាញសូត្រដែលជាកេរមរតក ត្រូវគេយកប្រើប្រាស់ជាទូទៅមិនប្រកាន់អ្នកមាន ឬអ្នកក្រឡើយ។

សំពត់ហូលជាវាយន័ណ្ឌជាតិបែបផែនខ្មែរ គឺវៃហ្វ៍អ៊ីកាត់ (Welt iKat) វាមានពីរប្រភេទ គឺមួយជាគ្រឿងស្លៀកពាក់ហៅថា **សំពត់ហូល** និងជារបៀបអ៊ីកាត់ត្បាញចេញជាក្រឡាដែលមានគោមផ្សេងៗទៅតាមការពេញចិត្តរបស់អ្នកប្រើប្រាស់។ សំពត់មានន័យថា សំពត់រុំ និងហូលមានន័យថាអ៊ីកាត់ ដែលឆ្លងកំណើតមកពីសំពត់រុំរបស់ប្រជាជនឥណ្ឌា ហើយអ្នកស្រុកក៏បានកែច្នៃបច្ចេកទេស និងរូបរាងជាច្រើនសតវត្សតាមរយៈសិល្បៈច្នៃដ៏ប្រសប់របស់ខ្មែរ។ អ៊ីកាត់ប្រែជាភាសាខ្មែរមានន័យថា អង្កៀតសម្រាប់ទាញ និងចងខ្សែអំបោះជាមួយនឹងសរសៃសូត្រដើម្បីបង្កើតបានជាខ្សែសូត្រមុននឹងត្បាញ។ ដើម្បីរៀបចំម៉ូត គេមិនដែលគូសវាសលើក្រដាសជាមុនទេប៉ុន្តែគេចងរុំសូត្រទៅតាមការចង់ចាំ។

### ២. ស្ថានភាពត្បាញនាពេលបច្ចុប្បន្ន

អ្នកភូមិមានវប្បធម៌ចែករំលែកឲ្យគ្នាទៅវិញទៅមកតាមរយៈអ្នកតម្បាញហូល។ ពួកគេមានមុខរបរសំខាន់គឺការធ្វើស្រែវស្សាតែពួកគេធ្វើតែមួយដងក្នុងមួយឆ្នាំសម្រាប់តែបរិភោគ។ ប៉ុន្តែអ្នកភូមិមានមុខរបរដែលគាត់តែងធ្វើជាប្រចាំ និងជាមុខរបរបន្តតាំងពីជីដូនជីតា។ វិធីធ្វើសំពត់ហូលនេះមានលក្ខណៈពិបាក និងប្រើរយៈពេលយូរ។ ប្រសិនបើមនុស្សគ្មានការព្យាយាមអត់ធ្មត់ទេ មិនអាចត្បាញសំពត់ហូលបានស្អាតឡើយ។ មុននឹងបានសរសៃសូត្រយកមកត្បាញ

ជាសំពត់ហូល គេត្រូវចិញ្ចឹមដង្កូវនាងដោយផ្ទាល់ប៉ុន្តែដោយសារតំរូវការមិនគ្រប់គ្រាន់ទើបនាំសូត្រចូលពីប្រទេសក្រៅ។ បន្ទាប់មកធ្វើឲ្យអ្នកតម្បាញបង្វិចិត្តទៅទិញសូត្រពីខាងក្រៅដើម្បីត្បាញជាមុខរបររបស់ពួកគាត់។ ដូច្នេះទើបនៅតំបន់មួយចំនួនមានការបាត់បង់វិធីសាស្ត្រចិញ្ចឹមដង្កូវនាងមកដល់ឥឡូវមិនបានយកចិត្តទុកដាក់ទៀតផងនោះ។ មកដល់ពេលបច្ចុប្បន្ននេះមានការបាត់បង់វត្ថុធាតុដើមដែលមានតាំងពីជំនាន់ជីដូនជីតារបស់ឪពុកម្តាយរបស់ពួកគាត់ត្រូវបានបាត់បង់ក្នុងសម័យជឿនលឿន។ ប្រសិនបើមានគេចិញ្ចឹមដង្កូវនាងវិញគឺធ្វើដូចពីមុនអញ្ចឹងដែរ គ្រាន់តែគេចាប់ដង្កូវនាងទៅដាក់ក្នុងចង្អេរដើម្បីឲ្យដង្កូវនាងរុំព័ទ្ធជាសុំបុកក្នុងចង្អេរ ឬដើមត្រាំងដីសរ។

បន្ទាប់មកមុននឹងបានដង្កូវនាងមកស្រាវយកសូត្រ គេត្រូវរៀបចំវិធីចិញ្ចឹមដង្កូវនាងឲ្យបានល្អប្រសើរ ទើបការស្រាវយកសូត្រពីសំបុកដង្កូវនាងបានផលច្រើន។ ដោយសារការដាំដើមមនធ្វើជាចំណីដង្កូវនាង សម្រាប់ឲ្យដង្កូវនាងស៊ី ពីព្រោះដង្កូវនាងវាស៊ីបានតែស្លឹកមនតែម៉្យាងគត់ មុននឹងយកដង្កូវនាងមកចិញ្ចឹមគឺត្រូវការដាំដើមមនសិន ប្រើរយៈពេលប្រហែលជា ៥ទៅ ៦ ខែទើបអាចចិញ្ចឹមដង្កូវនាងបាន។

<u>ដើមមនមាន៤ប្រភេទ ៖</u>

- ប្រភេទដើមមនខ្មែរ (ស្លឹករបស់វាមិនសូវជាធំទេ)
- ប្រភេទដើមមនវៀតណាម (ស្លឹករបស់វាធំ)
- ប្រភេទដើមមនចិន
- ប្រភេទដើមមនថៃ

ដើមមនបានបែងចែកជាពីរប្រភេទគឺ ប្រភេទដើមមនញី និងដើមមនឈ្មោល។ ប្រភេទដើមមនញីមានស្លឹកវារាងមូលដូចជាស្លឹកម្ទូ។ ប៉ុន្តែប្រភេទដើមមនឈ្មោលមានស្លឹករាងឆែកៗហើយជ្រុង។



រូបភាព ការដាក់ស្លឹកមនផ្តល់ចំណីដល់ដង្កូវនាង

វិធីស្រាវយកសូត្រគេយកឆ្នាំងមកដាំទឹកឲ្យក្ដៅល្មមទើបគេយកឈើស្រាវមកដាក់គងលើមាត់ឆ្នាំង។ គេយកដង្កូវនាងទាំងសំបុកមកបង់ក្នុងទឹកក្ដៅឧណ្ហៗចំនួនមួយក្ដាប់ម្ដងៗ។ គេយកឈើមូលរលោងមកកូរសរសៃសូត្របែកចេញពីសំបុកមករុំឈើមូលនោះ។ គេចាប់ស្រាវយកសរសៃសូត្រមកដាក់គងលើភ្ជៅរំអិលទាញបញ្ចូលក្នុងកុង គឺដៃម្ខាងទប់សំបុកដង្កូវនាង ឯដៃម្ខាងទៀតកាន់កុងរវៃឲ្យសរសៃសូត្ររុំព័ទ្ធជុំវិញកុង។ សូត្រដែលស្រាវយកពីដង្កូវនាងមានពណ៌លឿងដូចមាស ពេលខ្លះច្រលក់ជាមួយនឹងល័ក្ខដែលយកចេញពីសំបកឈើធម្មជាតិ មើលទៅល្អហើយសរសៃសូត្រដែលយកចេញពីដង្កូវនាងមានសរសៃធំជាងសូត្រទិញមកពីផ្សារ។ ចំពោះសូត្រដែលទិញមកពីផ្សារវិញមិនដឹងយកមកពីណាទេ ដោយសារតែនាំចូលពីបរទេស។



សរសៃសូត្រលឿង ឬសូត្រមាសជាសូត្រប្រណិត

ពេលជ្រើសរើសសរសៃសូត្រតាមតូច តាមធំតំរៀបក្នុងអ័ក្សក្តី ពេលរវៃសូត្ររុំព័ទ្ធបំពង់ក្តី គេយកសូត្រដែលបានដោះចេញពីកុងមកពាក់នឹងស្ទាបរងើង ទាញចេញបញ្ចូលព័ទ្ធអ័ក្ស ឬរវៃរុំព័ទ្ធបំពង់ ឬខ្នារ។

រងើងជាគ្រឿងតម្បាញមួយប្រភេទធ្វើអំពីឈើ និងឬស្សី។ រងើងនេះមានមេទទឹងដែលមានមុខកាត់បួនជ្រុង ទ្រវែងប្រហែលជា ០.១២ x០.០៨ បណ្តោយប្រហែលជា ០.៥០ម៉ែត្រ ឬ០.៦០ម៉ែត្រ។ មានឈើមេសំដូកសម្រាប់ទប់កុំឲ្យរលំដែលមានមុខកាត់ប្រហែល ០.០៨ x០.៦០ម៉ែត្រ បណ្តោយប្រហែលជា ០.៤០ម៉ែត្រ គេដាប់ដំណាប់សម្រាប់ដាក់មេបញ្ឈរពីរ នៅចុងសងខាង។ នៅចុងខាងលើមេបញ្ឈរ គេខ្សៀល ឬដាក់សម្រាប់ដាក់ក្ងៅគោមរងើង។ នៅចុងក្ងៅទាំងសងខាង គេលាក់បញ្ចូលបន្ទះឬស្សី២ ឬ៣ម្ខាងធ្វើជាស្ទាប។ នៅចុងស្ទាបជាគូរនឹងគ្នា គេចងខ្សែភ្ជាប់គ្នាពីចុងមួយទៅចុងមួយផ្សេងទៀតសម្រាប់ទ្រសូត្រ។ សូត្រដែលស្រាវចេញពីដង្កូវនាងមានពណ៌លឿងដូចសរសៃមាស។ ចំណែកសូត្រដែលទិញពីផ្សារមានពណ៌ស ដែលមានសរសៃទន់ជាងសូត្រដែលស្រាវចេញពីដង្កូវនាង។



ការស្រាវសរសៃសូត្រពីសំបុកដង្កូវនាង



ការត្រៀមវៃសរសៃសូត្រដែលចងគាតដាក់ចូលក្នុងខ្នារ

អក្សគ្រឿងប្រដាប់តម្បាញរបស់ខ្មែរមួយប្រភេទធ្វើអំពីរឈើខ្លឹមដែលមានកាំប្រាំបី ឬកាំប្រាំមួយ។ ប្រវែងកាំនីមួយៗប្រហែលជា០.១៥ម៉ែត្រ មានរបារខាងខ្នងរបារ មានភ្លៅធ្វើអំពីដែកមូលបង្វិលបាន មានជើងទ្រមាំ ជាប្រដាប់សម្រាប់ផាត់សូត្រ រៀបតាមសរសៃតូចធំរបស់ស្ត្រីខ្មែរមានតាំងពីយូរយារមកហើយ។ គេទាញសរសៃសូត្រចេញពីរង្វឹងមករុំព័ទ្ធអក្សតាមសរសៃតូចតាមសរសៃធំ តាមក្រុមដែលគេបានបែងចែកទៅតាមក្រុមនីមួយៗរបស់វា។



អ័ក្ស ៦ជ្រុង

បច្ចុប្បន្នប្រជាជនដែលរស់នៅតំបន់ជុំវិញភ្នំជីសូរ្យមិនបានធ្វើរបៀបដូចពីមុនទេ គឺដោយសារប្រើរយៈពេលយូរទម្រាំតែបានយកមកត្បាញក្លាយជាសំពត់។ ពួកគេបានប្រើប្រភេទសូត្រដែលគេនាំចូលពីបរទេស ដែលមានពណ៌សសុទ្ធហៅថា **សូត្រសអំបោះ** វាពិបាកក្នុងការវៃជាខ្សែណាស់។ កាលពីមុនប្រជាជនដែលជាអ្នកតម្បាញចូលចិត្តប្រើប្រាស់នូវសូត្រឆៅជាងសូត្រឧស្សាហកម្ម ព្រោះសំពត់ដែលត្បាញចេញពីសូត្រឆៅជាប់ជាង ហើយមានលក្ខណៈដូចធម្មជាតិល្អជាងសំពត់សូត្រដែលត្បាញដោយសរសៃសូត្រឧស្សាហកម្ម។ ម៉្យាងទៀតការប្រើប្រាស់ក៏គេនិយមសំពត់សូត្រដែលត្បាញចេញពីសរសៃសូត្រឆៅដែរ។ សូត្រដែលទិញមកពីផ្សារគេមិនចាំបាច់វៃទៀតទេទោះបីជាគុណភាពសំពត់មិនសូវល្អដូចជាសូត្រឆៅពិតមែនតែតម្លៃលក់ថោកគួរសមអាចឲ្យអ្នកត្បាញរកកម្រៃបានសមរម្យ។

តាមរយៈការសាកសួរមនុស្សចាស់ដែលគាត់នៅត្បាញ និងមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងភូមិ នូវចំណុចខ្វះៗនៃស្ថានភាពអ្នកត្បាញហូលនេះ គាត់បានបញ្ជាក់ថាប្រជាជនចេះ

ត្បាញហូលតាំងពីជីដូនជីតារបស់ពួកគេមកម្ល៉េះ។ មិនមានសាលាបណ្ដុះបណ្ដាលជំនាញនេះទេ ប៉ុន្តែគាត់ទទួលចំណេះដឹងទាំងនេះពីជីដូនជីតា ឬឪពុកម្ដាយរបស់ពួកគាត់។ រហូតមកដល់សម័យរបបខ្មែរក្រហមនាឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រជាជនច្រើននាក់ត្រូវខ្មែរក្រហមជម្លៀសចេញពីស្រុកកំណើតរបស់ខ្លួនទៅកាន់តំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា និងមួយផ្នែកទៀតបានរត់ទៅរស់នៅក្រៅប្រទេស។ ដូច្នេះមុខរបរតម្បាញហូលត្រូវបានបោះបង់ចោលមួយរយៈពេលក្នុងសម័យកាលនោះ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យរលត់ទៅ អ្នកស្រុកត្រឡប់មកស្រុកកំណើតវិញពួកគាត់ចាប់ផ្ដើមរាតដីសម្រាប់ធ្វើផ្ទះ និងដីស្រែចម្ការដើម្បីបង្កើតជីវភាពសារជាថ្មី។ ម្យ៉ាងវិញទៀតអ្នកមានចំណេះនិងបទពិសោធន៍ជាយូរឆ្នាំខាងតម្បាញហូលគាត់ក៏ចាប់ផ្ដើមបន្តត្បាញដដែលដោយសារនេះជាជំនាញរបស់គាត់មានតាំងពីជីដូនជីតា។ ដូច្នេះគាត់នៅថែរក្សាឲ្យបានគង់វង្ស។ អ្នកនៅក្នុងភូមិមានទំនៀមទំលាប់មួយដែលគេនិយាយគ្រប់គ្នាថា ប្រសិនបើកូនរៀបការត្រូវបង្កើតគ្រួសារថ្មី ពួកគេត្រូវបែកពីគ្រួសារដើម្បីរស់នៅផ្ទះផ្សេង ឬក៏កន្លែងផ្សេងពីស្រុកកំណើត។ ដូច្នេះឪពុកម្ដាយត្រូវធ្វើកីតម្បាញចែកទៅឲ្យកូនម្នាក់មួយៗ សម្រាប់ជាកេរទុកជាមុខរបរសម្រាប់ឲ្យកូនគ្រប់ៗគ្នា។

អ្នកភូមិខិតខំប្រឹងប្រែងព្យាយាមត្បាញដោយសារតែប្រើរយៈពេលយូរមិនដូចជាត្បាញកន្ទេល ឬផាមួង។ ដោយសារមានការស្មុគស្មាញ និងមានច្រើនដំណាក់កាលធ្វើឲ្យចំណាយពេលយូរ ប្រជាជនរស់នៅក្នុងភូមិ ដែលជាអ្នកតម្បាញហូល ឬក្រមាហូលគ្មានការវិវត្តន៍ និងពង្រីកវិធីសាស្ត្រនៃការត្បាញឲ្យមានភាពទំនើប ឬលឿនបានច្រើននៅឡើយទេ។ គាត់នៅធ្វើតាមតែពីមុនមកដែលបានឃើញយាយតារបស់ពួកគាត់ធ្វើនៅតែថែរក្សាការត្បាញតាមរបៀបរបបប្រពៃណីដដែល។ បើឧបករណ៍គឺនៅដដែលមិនមានការផ្លាស់ប្ដូរអ្វីទេ តែមានឧបករណ៍ខ្លះប្រជាជនបានបោះបង់ចោលដោយមូលហេតុកាលពីមុនមានការចិញ្ចឹមដង្កូវនាង និងទៅស្មោះសំបកឈើធ្វើជាល័ក្ខមានការបុក ចិញ្ច្រាំទៅតាមប្រភេទ។ ក្នុងការប្រកបរបរជាអ្នកតម្បាញទាំងចាស់ ក្មេងអាចធ្វើទៅបានអាស្រ័យការងារដែលអាចធ្វើទៅបាន។ ដូច្នេះមិនសូវខ្វះកំលាំងពល

កម្មទេ ដោយសារតែក្មេងៗពួកគេចេញពីសាលារៀន ពួកគេតែងតែជួយធ្វើការងារដែលពួកគេអាចធ្វើបានមិនថាប្រុស ឬស្រីឡើយ។ នៅភូមិកញ្ចាង ខេត្តតាកែវជាកន្លែងសិប្បកម្មហូលតែមួយមុខ ធ្វើឲ្យហូលនៅទីនោះភាគច្រើនមានគុណភាពល្អ មានភាពល្បីល្បាញលើទីផ្សារសូត្រនៅស្រុកខ្មែរ។ ដូច្នេះផលិតផលហូលនៅភូមិនេះទទួលបានតម្លៃថ្លៃធ្វើឲ្យប្រជាជនជាច្រើន នាំគ្នាត្បាញសឹងតែគ្រប់ក្រុមគ្រួសារនៅក្នុងភូមិ ធ្វើឲ្យសូត្រនៅទីនោះត្បាញសឹងតែមិនទាន់តម្រូវការទីផ្សារក្នុងស្រុក។ មកដល់ឥឡូវនៅសល់អ្នកប្រកបរបរត្បាញហូល ក្រមាហូលនេះនៅប្រហែលជា ៥០%តែប៉ុណ្ណោះ។ អ្នកភូមិគាត់បានទទួលយកហូលលក់ក្នុងភូមិ និងបានមកលក់បោះបន្តនៅក្រុងភ្នំពេញ និងសៀមរាបដែលជាកន្លែងទេសចរណ៍ធ្វើឲ្យហូលមានតម្លៃថ្លៃ។

នាពេលបច្ចុប្បន្ននេះការត្បាញហូលមានការប្រែប្រួលទៅតាមកន្លែង ដោយសារតែមានការជឿនលឿនខាងបច្ចេកវិទ្យាទំនើប។ ធ្វើឲ្យមុខរបរមួយចំនួនដែលមានតាំងពីបុរាណមកមានការធ្លាក់ចុះម្តងបន្តិចៗ។ ការតម្បាញហូលនៅក្នុងភូមិកញ្ចាងកាលពីមុនមានចញ្ចឹមដង្កូវនាង និងមានល័ក្ខធម្មជាតិ ប្រជាជនគាត់ទៅស្ទោះសំបកឈើនៅជិតផ្ទះរបស់ពួកគាត់សម្រាប់យកមកធ្វើល័ក្ខធម្មជាតិ សម្រាប់ជ្រលក់ពណ៌ដើម្បីបង្កើនបានពណ៌ធម្មជាតិ មិនចាំបាច់ទិញសូត្រ ឬល័ក្ខពីផ្សារទេ។ ប៉ុន្តែឥឡូវមិនមានការចិញ្ចឹមដង្កូវនាង ឬទៅស្ទោះសំបកឈើសម្រាប់ធ្វើល័ក្ខជ្រលក់ទេ។ ដូច្នេះការតម្បាញហូលឥឡូវមានភាពងាយស្រួលជាងកាលពីមុន។ សូត្រ ឬល័ក្ខគេអាចទិញពីផ្សារនៅជិតភូមិ ឬអ្នកមានដើមទុនច្រើនគេអាចទៅទិញពីផ្សារ ឬគេមកភ្នំពេញដើម្បីទិញលក់ដោយខ្លួនឯងតែម្តង។ ប៉ុន្តែពុំសូវមានអ្នកមកទិញសូត្រនៅផ្សារទេ ដោយសារគេទៅទិញពីម៉ូយរបស់គេ។ ម្យ៉ាងវិញទៀតពួកគេអាចជំពាក់ ឬខ្ចីលុយពីម៉ូយរបស់ពួកគេក៏បានដែរ។ ផលិតផលទាំងអស់គឺបាននាំមកពីប្រទេសចិន ប្រទេសថៃ និង ប្រទេសវៀតណាម។ ប្រសិនបើគេត្បាញហូលរួចហើយ គេយកហូលនោះទៅឲ្យឈ្មួញកណ្តាល(ម៉ូយ)របស់គេ ឈ្មួញកណ្តាលនឹងកាត់ប្រាក់អ្នកតម្បាញហូលបានខ្ចីពីមុនពេលតម្បាញដើម្បីសងទៅម្ចាស់សូត្ររបស់ពួកគាត់វិញ។ សូត្រទិញពីផ្សារស្អាតស្រាប់ដោយមិនចាំបាច់កេះអាចម៍ក្រម៉ាវាចេញ ហើយសូត្រទាំងនេះច្រើនមកពីប្រទេសវៀតណាមដែលមានសរសៃស្វិត។ គេពុំសូវប្រើសូត្រខ្មែរទេ ព្រោះយើងត្រូវ

ប្រើរយៈពេលយូរទម្រាំតែបានសូត្រមកត្បាញៗ ដូច្នេះអ្នកភូមិគាត់បានទៅទិញសូត្រមកពីផ្សារដែលមានស្រាប់ ដោយវាមានភាពងាយស្រួលជាងការចិញ្ចឹមដង្កូវនាងៗ អ្នកភូមិចូលចិត្តប្រើប្រាស់សូត្រឧស្សាហកម្ម វាមានភាពងាយស្រួលដោយមិនចាំបាច់ត្រូវមើលក្រម៉ និងកេះអាចម៍ជជុះវាចេញទេៗ គាត់គ្រាន់តែរវៃសូត្រចូលទៅហុង ប៉ុន្តែបើសូត្រធៅគេត្រូវចំណាយពេលច្រើនក្នុងការសម្អាតវាមុននឹងគេរវៃសូត្រធៅចូលទៅក្នុងហុង គេត្រូវមើលក្រម៉ និងកេះអាចម៍ជជុះវាឲ្យស្អាតជាមុនសិនទើបយកវាទៅរវៃចូលហុង និងត្រូវការតជាច្រើនកន្លែងទៀតៗ ពិតមែនតែអ្នកភូមិទិញសូត្រមកពីផ្សារក៏ដោយប៉ុន្តែមុននឹងយកទៅត្បាញគេត្រូវស្រាវមើលសិនក្រែងលោមានក្រម៉ក្រើម និងខ្វាចដាច់ ឬចងតឹងពេកៗ ដូច្នេះសិប្បករមានប្រសាសន៍ថា ការត្បាញហូលឥឡូវមិនដូចត្បាញហូលកាលពីសង្គមចាស់ឡើយៗ វាមានភាពងាយស្រួលជាងមុនមិនចាំបាច់ចិញ្ចឹមដង្កូវនាង និងទៅស្ទោះសំបកឈើមកធ្វើជាល័ក្ខទេ គឺគ្រាន់តែទៅទិញនៅឯផ្សារដែលនៅជិតផ្ទះ ឬយកពីឈ្មួញកណ្តាលដែលបានទិញហូលគឺបានត្បាញបាត់ទៅហើយៗ

### ៣. អំពីកីត្បាញ

កីតម្បាញជាប្រភេទសម្ភារម្យ៉ាងដែលធ្វើឡើងអំពីឈើដែលមានបណ្តោយប្រវែង៣ម៉ែត្រទៅ៣,៥០ម៉ែត្រ ទទឹង១,២ម៉ែត្រ ធ្វើពីឈើ មានជើងបួន និងមានរនុកសម្រាប់ទប់កីឲ្យរឹងៗ កីតម្បាញហូលមានតង្កូរ៣ មានធ្មេញឈើធ្វើពីដែក គំរបធ្មេញខាងលើធ្វើពីឈើ និងត្រល់ធ្វើពីស្នែងសត្វ(ក្របី) ហើយមានរាងមូលនៅខាងក្នុងបំពង់ត្រល់ធ្វើពីឬស្សីសម្រាប់រុំសរសៃសូត្រៗ គេត្រូវយកត្រល់នេះខាត់ឲ្យរលោងស្អាតឲ្យ មានភាពងាយស្រួលនៅពេលត្បាញ ដើម្បីឲ្យសរសៃសូត្ររត់និងមានផ្នែកក្នុងនៃត្រល់ដែលគេអាចដាក់ខ្នារហើយវាវិលបានដោយស្រួលៗ

ត្រល់សម្រាប់ត្បាញហូលមាននៅពេលកំពុងត្បាញតែមួយទេ នៅកន្លែងអង្គុយនៃក្បាលកីធ្វើអំពីឈើនិង ឬស្សីៗ ជានិច្ចកាលតែងតែមានគ្រឿងបន្ទាប់បន្សំផ្សេៗ ទៅតាមមុខងាររបស់វាៗ គ្រឿងបន្ទាប់បន្សំសម្រាប់ការត្បាញហូលច្រើនមានរូបរាងតូចៗហើយស្តើងរលោង និងលាតល្អ គេតែងតែយកវត្ថុដែលមានទម្ងន់ស្រាលៗយកមកធ្វើជាឧបករណ៍ទាំងនោះ ដូចជាឈើស្រឡៅ ដើមដូង ដើមថែម ឬដើមឫស្សីៗ



រូបភាពកីតម្បាញមើលពីក្រោយ



កីតម្បាញធម្មតានៅកោះឧកញ៉ាតី



រូបភាពកីតម្បាញបូរាណនៅសារមន្ទីរជាតិ



កីតម្បាញនៅសារមន្ទីជាតិភ្នំពេញ



ការរចនាក្បាច់លម្អលើកីតម្បាញនៅក្នុងព្រះបរមរាជវាំងមើលពីចំហៀង




*រូបភាព គំនូរកីតម្បាញរបស់* Artisans D'Angkor




រូបភាព គំនូរកើតម្បាញរបស់ ភូមិគ្រឹះឈូក (គូរដោយលោក ហោ សុកលាភ)




រូបភាពមើលពីចំហៀង




រូបភាពលម្អិត




រូបភាពលម្អិត




រូបភាពលម្អិត




រូបភាពលម្អិត




រូបភាពលម្អិត




រូបភាពលម្អិត



រូបភាពកីតម្បាញ និងការត្បាញរបស់ជនជាតិអាហ្វ្រិក





រូបភាពកីតម្បាញ និងការត្បាញរបស់ជនជាតិអាហ្វ្រិក





រូបភាពកីតម្បាញ និងការត្បាញរបស់ជនជាតិអាហ្វ្រិក



រូបភាពកីត្បាញនិងការត្បាញរបស់ជនជាតិចិន



រូបភាពកីត្បាញនិងការត្បាញរបស់ជនជាតិចិន



រូបភាពឧបករណ៍តម្បាញរបស់ជនជាតិចាម នៅវៀតណាមកណ្ដាល



រូបភាពឧបករណ៍តម្បាញរបស់ជនជាតិចាម នៅវៀតណាមកណ្ដាល





រូបភាពឧបករណ៍តម្បាញរបស់ជនជាតិចាម នៅវៀតណាមកណ្តាល

## ៤. ឧបករណ៍បន្ទាប់បន្សំនៅក្នុងកី

### ៤.១. គម្របធ្មេញឈើ

គម្របធ្មេញឈើមានបណ្ដោយប្រវែង១.២០ម៉ែត្រ ចែកចេញជាពីរផ្នែកគឺ ផ្នែកខាងលើហៅថាគ្របលើ ធ្វើអំពីឈើនាងនួនដែលនៅសងខាងគេឆ្លាក់ជារាងកន្ទុយនាគ និងមានជន្ទង់សម្រាប់ចាប់កាន់ ហើយផ្នែកខាងក្រោមហៅថា គ្របក្រោម។ នៅតាមបណ្ដោយគែមខាងក្នុងគេលកដើម្បីដាក់ធ្មេញឈើ។



រូបភាពគម្របធ្មេញឈើ

### ៤.២. ធ្មេញឈើ

ធ្មេញឈើមានបណ្ដោយប្រវែង ០.៨០សង់ទីម៉ែត្រ ឬ១ម៉ែត្រ។ បណ្ដោយធ្មេញឈើ និងកំណាត់ទទឹងសំពត់ហៅថា "សម្រុង"។ កាលពីដើមធ្មេញឈើគេធ្វើពីឬស្សី ដោយយកឬស្សីមកពុះរួចបិតឲ្យតូចឆ្មារហើយស្ដើងប្រវែង១តឹករួចហើយយកទៅចងស្រេះជាមួយសូត្រឲ្យមានរាងដូចជាស្និតសិតចៃដោយភ្ជាប់ទៅនឹងអ័ក្សធ្វើពីឈើដាក់ផ្ដេកនៅខាងចុងនៃបន្ទះឬស្សី។ ធ្មេញកោសធ្វើអំពីបន្ទះឬស្សីស្ដើងបំផុតក្រងជាមួយនឹងសូត្រ។ ធ្មេញឈើក៏ប្រើដែរសព្វថ្ងៃ ប៉ុន្តែគេសម្រាប់តែត្បាញក្រមាតែប៉ុណ្ណោះ។ បើត្បាញហូលវិញគេនិយមប្រើធ្មេញឈើធ្វើពីដែក ព្រោះត្បាញសំពត់ហាប់ល្អ និងប្រើប្រាស់បានយូរជាងធ្មេញធ្វើពីឈើ។



រូបភាពបង្ហាញអំពីធ្មេញឈើ



រូបភាពបង្ហាញអំពីធ្មេញឈើ

### ៤.៣. ក្ដារមូរ

ក្ដារមូរមានបណ្ដោយប្រវែង១,៥០ម៉ែត្រ, ទទឹង០,២០ម៉ែត្រគេច្រើនធ្វើពីឈើស្រាលៗដូចជារលួស, ស្រល់ ឬស្រឡៅ។ ក្ដារមូរនេះត្រូវខាត់ឲ្យរលោងហើយលកតាមបណ្ដោយក្ដារទាំងសងខាងឲ្យក្រហូងសម្រាប់ដាក់មូរ។ គេប្រើប្រាស់វាសម្រាប់រុំសរសៃសូត្រក្នុងការត្បាញ។



រូបភាពក្ដារមូរមានក្បាច់លំអ (នៅសារមន្ទីជាតិ)





រូបភាពក្ដារមូរធម្មតាពុំមានការរចនាអ្វីឡើយ

### ៤.៤. ឈើផ្សំ

ឈើផ្សំមានទំហំ៥ធឹង(ហ៊ុន) បួនជ្រុង ឬក៏មានរាងមូល បណ្តោយប្រវែង១.១៣ម៉ែត្រ ធ្វើពីឈើស្រឡៅ។ ឈើផ្សំមានចង្អូរ វែតមួយនៅជ្រុងម្ខាងរបស់វាសម្រាប់ដាក់បន្ទះឫស្សី (ស្នំ) ដើម្បីភ្ជាប់ចុងសរសៃសូត្រនៅពេលត្បាញ។ គេដាក់ឈើផ្សំនៅក្នុងជន្ទងឈើកី។





រូបភាពឈើផ្សំមានក្បាច់លំអនៅចុងសងខាង

## ៤.៥. ចន្ទាល់

ចន្ទាល់មានបណ្ដោយប្រវែងស្មើនឹងធ្មេញឈើដែល គេហៅថាដងចន្ទាល់។ ផ្នែកកណ្ដាលមានពងមូលធំផ្នែកចុងទាំងសងខាងចន្ទាល់មានភ្ជាប់លោហធាតុស្រួចៗហៅថាបន្ទាចន្ទាល់សម្រាប់ខ្នាស់ទាញសំពត់ឲ្យទទឹងសាច់បានស្មើល្អ។ការដាក់ចន្ទាល់ខ្នាស់ទាញសំពត់ហៅថាដោយចន្ទាល់។

## ៤.៦. ត្រល់

ត្រល់មានបណ្ដោយប្រវែង ០.២៥ម៉ែត្រ នៅតាមបណ្ដោយខាងក្នុងនៃត្រល់គេដាក់បញ្ចូលចង្កឹះ ផ្ទៃខាងក្នុងត្រូវខាត់ឲ្យរលោងងាយស្រួល ដល់សរសៃសូត្ររត់នៅពេលត្បាញ។ ផ្នែកខាងក្នុងនៃត្រល់គេហៅថា "រន្ធត្រល់" ដែលក្នុងនោះគេដាក់ខ្នារអាចវិលបានដោយសេរី ត្រល់ប្រភេទនេះមានទម្ងន់ស្រាលសមមាត្រទៅនឹងភាពធ្មារនៃសរសៃសូត្រ។ ត្រល់ធ្វើពីឬស្សីពក ចំណែកក្បាលទាំងសងខាងធ្វើពីឈើ ឬស្នែងសត្វ។



រូបភាពត្រល់មូល និងត្រល់សំប៉ែត ព្រមទាំងប្រអប់ដាក់ត្រល់



រូបភាពត្រល់មូល



រូបភាពត្រល់មានរាងដូចទូក

## ៤.៧. ខ្នារ

ខ្នារសម្រាប់ត្បាញធ្វើពីដើមត្រែងហៅថា ត្រែងខ្នារ។ ខ្នារវែងមានបណ្តោយប្រវែង១តឹក សម្រាប់ត្បាញផ្ទៃសំពត់ ខ្នារខ្លីមានប្រវែង ៨ធឹងសម្រាប់ចាក់ផ្កា  ខ្នារនេះគេប្រើសម្រាប់ខារសូត្រដាក់ត្បាញ។



រូបភាពខ្នារដែលរុំសរសៃសូត្រដែលចងគាត់រួច

## ៤.៨. បន្ទូលតង្កៀរ

បន្ទូលតង្កៀរមានប្រវែងមិនកំណត់ទេ  ជួនកាល១.២០ម៉ែត្រ  ឬ១.៣០ម៉ែត្រ  ចំណែកទំហំរបស់វាមានអង្កត់ផ្ចិត១ហ៊ុន។ បន្ទូលតង្កៀរធ្វើពីដើមឫស្សី ឬដើមត្រែង  តែបច្ចុប្បន្ននេះគេនិយមប្រើប្រាស់បន្ទូលតង្កៀរធ្វើពីឈើ ខាត់ឲ្យរលោងដើម្បីសំអាតសរសៃសូត្រនៅពេលថ្កៀរ។ បន្ទូលតង្កៀរមាន៦ តម្រៀបជា៣ជួរ។



រូបភាពបន្ទួលតង្កៀរ

## ២.៩. បន្ទួលតង្កៀរផ្កា

បន្ទួលតង្កៀរផ្កាមានសណ្ឋានដូចជាតង្កៀរដែរប៉ុន្តែចំនួនរបស់វាយើងមិនអាចកំណត់បានឡើយអាស្រ័យទៅលើក្បាច់ផ្កាដែលគេចង់បានមានចំនួនតិច ឬច្រើន។



### ៤.១០. ឈ្នាន់

ឈ្នាន់គឺធ្វើពីឈើ ឬដើមឫស្សីមានបណ្តោយ ១.៨០ម៉ែត្រ ឬ២ម៉ែត្រទទឹង០.៦០ម៉ែត្រ។ ចំនួនឈ្នាន់ផ្អែកទៅតាមជួរតង្កូរ។ ចំណែកការត្បាញសំពត់ផាមួងដែលមានតង្កូរ៣គឺគេត្រូវប្រើឈ្នាន់៣ដែរ ដាក់នៅខាងក្រោមកន្ទែងអង្គុយត្បាញសម្រាប់ជាន់លើកផ្កា។ នៅក្នុងតម្បាញហូលឈ្នាន់មានលក្ខណៈប្លែកពីផាមួង ដោយគេមិនធ្វើឈ្នាន់ជាប់នឹងកីទេ។ គេគ្រាន់តែយកឫស្សី៣កង់មកចងខ្សែភ្ជាប់ទៅនឹងតង្កូរសំយ៉ុងចុះទៅក្រោមប៉ុណ្ណោះ។

### ៤.១១. រ៉ត

រ៉តជាដុំឈើ ឬលោហៈមានអង្កត់ផ្ចិតប្រហែល ៥សង់ទីម៉ែត្រ។ រ៉តនីមួយៗមានក្រហូងរបស់វាសម្រាប់ដាក់សរសៃសូត្រ រ៉តគេចងជាមួយតង្កូរដើម្បីងាយស្រួលជាន់។ ខ្សែរបស់វាគេចងភ្ជាប់ជាមួយចាងណាង។



រូបភាពរ៉តលំអដោយចម្លាក់ជាសត្វមាន់ ឬរូបភាពផ្សេងៗ



វែតលំអដោយក្បាច់ផ្កាចាន់



រូបភាពត៉ែមានឆ្លាក់ក្បាច់លំអ

## ៤.១២. ដាមកំណើត

ដាមកំណើតធ្វើអំពីបន្ទះឫស្សីស្តើងល្មម ខាត់ឲ្យរលោងមានទំហំ ៣សង់ទីម៉ែត្រ និងបណ្តោយមានប្រវែងវែងជាងធ្មេញឈើបន្តិច។ ដាមកំណើតមានចំនួនពីរសម្រាប់គាស់សរសៃរសូត្រ។



រូបភាពដាមកំណើត (ដកស្រង់ពីសៀវភៅនិក្ខេបបទបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា)

### ៤.១៣. ត្រដោកក្ដារ

ត្រដោកក្ដារជាដុំឈើពីរដុំមានបណ្ដោយ ០.៤១ម៉ែត្រ ហើយមុខកាត់ ៤សង់ទីម៉ែត្រ គេចោះរន្ធមួយនៅតាមបណ្ដោយឈើនោះដែលមានប្រវែងវែងជាងឈើផ្សំៗ គេប្រើប្រាស់វាសំរាប់ថ្ករឈើផ្សំដើម្បីអាចទាញសន្ទឹងសូត្រទៅលើកីៗ ត្រដោកក្ដារអាចធ្វើដោយឫស្សី២កំណាត់ដែលនៅចុងម្ខាងនៃកំណាត់ឫស្សីនោះមានមែករវាជាទំពកៗ



រូបភាពត្រដោកលំអទៅដោយក្បាច់ ឬរូបសត្វនាគ



រូបភាពត្រដោកលំអទៅដោយក្បាច់ ឬរូបសត្វនាគ



រូបភាពត្រដោកលំអទៅដោយក្បាច់ ឬរូបសត្វនាគ



រូបត្រដោកធម្មតាស្រួចចុងសងខាង

### ៤.១៤. រា

រាធ្វើពីឫស្សីមានប្រវែង១.៦ម៉ែត្រដាក់ពីលើធ្នឹម។ រាមានចំនួន៣ មួយសម្រាប់ចងភ្ជាប់នឹងបន្ទូលតង្កូវ មួយសម្រាប់ចងភ្ជាប់ នឹងបន្ទូលតង្កូវផ្កា និងមួយទៀតសម្រាប់ភ្ជាប់ នឹងធ្មេញឈើ។

### ៤.១៥. ឈើរឹត

ឈើរឹតធ្វើពីដើមឫស្សី ឬមកដល់បច្ចុប្បន្នមានធ្វើពីដែកក៏មានដែរមានប្រវែង១.៥០ម៉ែត្រ សម្រាប់ចងភ្ជាប់មេទទឹងគីជាមួយនឹងក្តារមូរនៅពេលត្បាញ។



រូបភាពឈើរឹតជាប់ជាមួយនឹងក្តារមូរកើតម្បាញ (នៅសារមន្ទីរជាតិ)



រូបភាពឈើរឹតភ្ជាប់ជាមួយត្រដោក និងក្តារមូរពុំមានរចនាអ្វីឡើយ

## ៥. ឧបករណ៍បន្ទាប់បន្សំនៅខាងក្រៅកី

### ៥.១. រហាត់

រហាត់ធ្វើពីខ្នងកង់ និងឫស្សី ដែលធ្វើឡើងមានចំនួន៨ដោយដាក់៤ម្ខាង។ វត្ថុនេះ គឺសម្រាប់ខារសូត្រ គេបានយកសូត្រទៅដាក់ និងរហាត់ រួចទើបខារដាក់ចូលក្នុងបំពង់។ បំពង់សូត្រនេះគេធ្វើពីឫស្សីមួយកង់រួចក៏រវៃសូត្រចេញរហាត់មករុំនឹងបំពង់។ លុះគេដាក់បំពង់ហើយគេរវៃបញ្ចូលឲ្យតូចជាមុខ២ទៅ៣រួចយកទៅដាក់ក្នុងកុងឲ្យដឹងចំនួនសរសៃសូត្រ ហើយប្រមោកឲ្យស្អាតទើបយកទៅជ្រលក់ល័ក្ខ។



រហាត់បុរាណធ្វើអំពីឈើទាំងអស់




រហាត់បច្ចុប្បន្នធ្វើអំពីខ្នងកង់ដែក

### ៥.២. រងើ្វង

រងើ្វងធ្វើពីឫស្សីមានស្លាបចំនួន៦ ម្ខាងៗមានស្លាបចំនួន៣។ ជាឧបករណ៍រវៃសូត្រដែលចងចេញជាគោម និងជ្រលក់ពណ៌ដើម្បីរវៃចូលខ្នារយកទៅត្បាញ។



រងើ្វងបូរាណមានលក្ខណៈតុបតែងលម្អសមសួនឥតខ្ចោះ

### ៥.៣. ឡូត

ឡូតគឺជាប្រភេទខ្នារដែលមានបណ្តោយប្រវែង ៨សង់ទីម៉ែត្រទៅ ៩សង់ទីម៉ែត្រ។ ឡូតនេះធ្វើពីមែកឫស្សី (យកឫស្សីពក) គេប្រើនៅពេលរវៃសូត្រ។



រូបភាពខ្នារនៅក្នុងឡូត





រូបភាពខ្នារុំសរសៃសូត្រចងគាតសំរាប់ត្បាញ

## ៩.៤. កូនអន្ទង





រូបភាពកូនអន្ទងដែលលម្អទៅដោយក្បាច់ចម្លាក់ផ្សេងៗ





រូបភាពកូនអន្ទងលម្អដោយក្បាច់ផ្កាចាន់





រូបភាពកូនអន្ទង់ ឬឈើអន្ទង់លម្អដោយក្បាច់ចង្វាយភ្ញីទេស





រូបភាពកូនអន្ទង់លម្អដោយក្បាច់ចម្លាក់ផ្កាយក្ខីទេស

### ៥.៥. បំពង់

បំពង់សម្រាប់ខារសូត្រធ្វើពីឬស្សី ឬដើរមានបណ្ដោយ១តឹកកន្លះទៅ២តឹក ទំហំ៥ហ៊ុន មានរាងមូល។

### ៥.៦. ប្រែង

ប្រែងជាអំបោសម្យ៉ាងធ្វើពីរោមសត្វ ឬធ្វើពីអ្វីដែលទន់ដើម្បីសិតសូត្រ ដោយយកទឹកបាយមកប្រើក្នុងការជ្រលក់។ នៅក្នុងតម្បាញហូលគេឲ្យបាយសូត្រនៅមុនពេលត្បាញដើម្បីឲ្យវាទន់ងាយស្រួលត្បាញ និងមិនស្រួយសូត្រ ហើយការឲ្យទឹកបាយគឺគេមិនឲ្យភ្លាមៗទេទុករយៈពេល២យប់ទើបយើងឲ្យវា។



រូបភាពជក់ ឬប្រែនសំរាប់សំអាតសរសៃផ្ទៃសូត្រ

តម្បាញហូលមានការប្រើប្រាស់ឧបករណ៍ជាច្រើនដើម្បីជំនួយដល់ការត្បាញសំពត់ហូល ឬផាមួង។ ឧបករណ៍ដែលមាននៅក្នុងកីសម្រាប់យកមកប្រើប្រាស់ ដើម្បីផលិតសំពត់ភាគច្រើនធ្វើពីឈើ និងឫស្សី។ ឧបករណ៍ទាំងប៉ុន្មានខាងលើគឺប្រជាជនដែលគាត់រស់នៅក្នុងភូមិជាអ្នកធ្វើ ដើម្បីចែកឲ្យទៅកូនចៅរបស់គាត់សម្រាប់ជារបរចិញ្ចឹមជីវិត។ ចំណែកឯឧបករណ៍មួយចំនួនត្រូវបានអ្នកភូមិលែងប្រើប្រាស់ហើយដោយមូលហេតុថាការប្រើប្រាស់ឧបករណ៍ខាងលើនេះគឺអាស្រ័យទៅលើការប្រើសូត្រខ្មែរ ដែលស្រាវយកសូត្រពីដង្កូវនាង ប៉ុន្តែមកដល់ពេលនេះពុំមានចិញ្ចឹមដង្កូវនាងដូចកាលពីមុនឡើយ។ ឧបករណ៍ដែលអ្នកភូមិលែងយកមកប្រើគឺ **អ័ក្ស** ដែលប្រើសម្រាប់ប្រមោកយកក្រម៉ចេញពីសូត្រ។ ទាំងអស់នេះហើយជាប្រពៃណីចែករំលែកពីមួយជំនាន់ទៅមួយជំនាន់ នេះជាគំរូដ៏ល្អមួយសម្រាប់ទៅក្មេងជំនាន់ក្រោយធ្វើឲ្យពួកគេចេះជួយគ្នាទៅវិញទៅមកនៅក្នុងសហគមន៍របស់ពួកគេរស់នៅ។

## ៦. ក្បាច់លម្អ





ក្បាច់លម្អអប្សរានៅប្រាសាទបាយ័ន និងប្រាសាទអង្គរវត្ត



រូបចម្លាក់អប្សរារាំនៅសសរប្រាសាទបាយ័ន លម្អដោយក្បាច់ផ្កាភ្ញីផ្សេងៗ



ក្បាច់ផ្កាភ្ញីលម្អសសរ និងជញ្ជាំងប្រាសាទបាយ័ន





ក្បាច់លម្អផ្សេងៗនៅតាមជញ្ជាំងប្រាសាទអង្គរវត្ត





ក្បាច់លម្អផ្សេងៗនៅតាមជញ្ជាំងប្រាសាទអង្គរវត្ត



ក្បាច់រំយោលនៅប្រាសាទអង្គរវត្ត អាចដកស្រង់ជាគំរូសំរាប់លម្អជើងសំពត់ហូលផាមួងបាន



ចម្លាក់បង្អួចនៅប្រាសាទតាព្រហ្មទន្លេបាទី លម្អទៅដោយវាំងននផ្កាចាន់



ចម្លាក់វាំងននផ្កាចាន់នៅប្រាសាទតាព្រហ្ម ទន្លេបាទី ខេត្តតាកែវ ស.វ.ទី១៣



ក្បាច់រង្គស្បូវ ឬក្បាច់ជដើងសំរាប់លម្អនៅតាមដើងសសរ





ក្បាច់ក្រឡាហូល បិតមាសសន្ទឹកលម្អលើសសរឈើ



ក្បាច់ផ្កាភ្ញីរចនាលម្អលើសសរឈើ



ក្បាច់ផ្កាចាន់ក្រឡាហូលលម្អលើសសរឈើ



ក្បាច់ផ្កាភ្ញី ផ្សំបង្កើតបានជាទំរង់ក្បាច់ផ្កាចាន់



ក្បាច់រំយោលជដើង ឬក្បាច់រង់ស្បូវសំរាប់លម្អលើក្រណាត់សំពត់ ហូលផាមួង



រូបភាពបង្ហាញអំពីកាផា លម្អដោយក្បាច់ផ្កាចាន់ជាក្រឡាគោមដូចគោមហូល

## ៧. ការចងគៀត

ពាក្យថា "គៀត" គឺជាពិធីធ្វើហូលទីមួយៗ ឲ្យមានក្បាច់ក្រឡាគោម ដែលមានលក្ខណៈទៅជាក្បាច់ប្លែកៗរបស់អ្នករៀបចំត្បាញហូល។ បើអ្នករៀបចំត្បាញហូលស្រលាញ់រូបអ្វី ឬក្បាច់បែបណាត្រូវគូររូបនោះ នឹងរំលេចពណ៌តាមការចូលចិត្តរបស់ខ្លួន។

កាលបើគេគូររូប និងការរំលេចបែងពណ៌បានដូចបំណងហើយ គេត្រូវយករូបដែលគេរំលេចបែងពណ៌ហើយនោះមកធ្វើជាគំរូសម្រាប់ចងយកគៀតដើម និងរៀបចំបែងពណ៌តាមរូបគំនូរនោះ កាលបើគេអន្ទងសូត្របានគ្រប់ចំនួនហើយ គេត្រូវខិតដុំគៀតដើម និងសូត្រចងឲ្យនៅជិតគ្នា។ គេយកចំណងចងសូត្រចុង តាមគំរូគៀតដើម។ បើគេចងបានមួយក្បាលហើយគេដោះចន្ទល់ គេបញ្ចេញសូត្រចុង។ គេទល់ចន្ទល់វិញទើបគេអន្ទងសូត្រចុង និងចងគៀតបែបទីមួយៗ គេត្រូវចងចុងយ៉ាងតិចណាស់ក៏ពីរក្បាលដែរ។ សម្រាប់យកទៅត្បាញហូលគោមផ្សេងៗដែលចងតាមគំរូ។ គេចាប់ទល់ចន្ទល់ និងអន្ទងរុំព័ទ្ធសូត្រចុងរហូតដល់បានគ្រប់ចំនួនទើបគេខិតគៀតដើមដុំទីពីរឲ្យមកកៀបគ្នា ហើយគេចងគៀតថ្មីនេះតាមគំរូគៀតដើមដូចមុនទៀត។ ការធ្វើបែបនេះរហូតដល់អស់ដុំគំរូគៀតដើម។ កាលពីមុនប្រជាជនបានប្រើខ្សែដែលផលិតពីស្រទបចេកជ្វា ដែលពុំទាន់ចេញផ្លែ។ គេច្រៀកស្រទបចេកនោះ រួចហាលថ្ងៃឲ្យស្រពាប់ទើបអាចចងបាន។ សព្វថ្ងៃខ្សែដែលធ្វើពីនីឡុងត្រូវបានគេយកមកជំនួស ព្រោះតែកង្វះខាតដើមចេកប្រភេទនេះ។ មួយវិញទៀតមកពីជំនឿប្រជាជនខ្មែរយើងដែលហាមមិនឲ្យដាំនៅក្បែរផ្ទះ។ នៅកន្លែងខ្លះក៏នៅថែរក្សានូវរបៀបបូរាណនេះនៅឡើយ។

កាលបើគេចងគៀត និងបែងពណ៌តាមគំរូគៀតដើមបានហើយ គេត្រូវយកគៀតនោះទៅជ្រលក់តាមវិធីជ្រលក់គៀត។ បើជ្រលក់គៀតបានស្រេចហើយ គេត្រូវយកសូត្រគៀតនោះទៅខារបញ្ចូលខ្នារ។ គេយកខ្នារទៅដាក់បញ្ចូលក្នុងត្រល់ សម្រាប់ចាក់ត្បាញហូល បើខារគៀតដាក់មិនត្រឹមត្រូវតាមក្បួន ឬពេលត្បាញចាប់ខ្នារដាក់ក្នុងត្រល់មិនត្រឹមត្រូវតាមក្បួន ក៏គៀតដាក់ខ្នារក្នុងពេលចាប់ខ្នារមកដាក់ក្នុងត្រល់ម្ដងៗមិនឲ្យច្រឡំខ្នារ។

សូត្រជាវត្ថុធាតុដើមដ៏ចាំបាច់បំផុតនៅក្នុងសិប្បកម្មតម្បាញ ផាមួង ហូល និងផលិតផលប្រពៃណីផ្សេងទៀត។ បច្ចុប្បន្ននេះអ្នកត្បាញភាគច្រើនប្រើប្រាស់សូត្រដែលលក់នៅផ្សារដោយពុំសូវពិបាកដើររកទិញផលិតផលសូត្រនៅក្នុងស្រុកទេ។

ម្យ៉ាងដោយស្រុកខ្មែរយើងឥឡូវមិនសូវនិយមចិញ្ចឹមដង្កូវនាងស្រាវយកសូត្រផងនោះ ការប្រើសូត្រឧស្សាហកម្មបានក្លាយទៅជាទំលាប់ធម្មតាទៅហើយ។ ផលិតផលសូត្រដែលលក់នៅផ្សារសព្វថ្ងៃ ច្រើនជាសូត្រឧស្សាហកម្មដែលនាំចូលពីប្រទេសវៀតណាម និងចិនដែលបានរៀបចំ និងសំអាតព្រមទាំងបានវេញគួបមុខគ្នារួចជាស្រេច។ បើវេញសរសៃសូត្រដើមពីសរសៃគួបបញ្ចូលគ្នា គេហៅថា "សូត្រមុខពីរ"។ គេច្រើនទិញសូត្រពីផ្សារដោយគិតជាកាលីដែលក្នុង១កាលីមានទំងន់ ២គីឡូក្រាមហើយយើងយកទៅប្រមោកហើយនៅសល់តែ១,៥០គីឡូក្រាមទើបយកទៅជ្រលក់ពណ៌ដែលយើងចង់បាន។



សូត្រដែលត្រៀមបំរុងរៀបចំចងគៀត

គេបែងចែកប្រភេទសូត្រដែលគួបមុខរួចជាស្រេចនេះ ជា២ផ្នែកទៅតាមចំនួនសរសៃសូត្រគឺ៖

សូត្រមុខ១ និងមុខ២ ប្រើសម្រាប់អន្ទងចូលក្នុងកី ឬអន្ទងផ្ទៃដែលមានមុខធ្មេញញឹកៗ សូត្រប្រភេទនេះច្រើនជ្រលក់ផ្ទៃពណ៌ទៅតាមចំណង់ចំណូលចិត្តរបស់ម្ចាស់សូត្រ។ តម្លៃរបស់វាក្នុង១កាលីស្មើ១៦ម៉ឺនរៀលអាចអន្ទងបាន១ក្បិន (១ក្បិនមានប្រវែង៣.៨តឹកទៅ៤ម៉ែត្រស្មើនឹង២សំពត់)។

សូត្រមុខ៨, ១០, ១២ និង១៤ ប៉ុន្តែនៅក្នុងតំបន់ខ្លះគេនិយមយកមុខ១០ ប្រើសម្រាប់ចាក់និងជ្រលក់លើគោម។ សូត្រប្រភេទនេះហើយដែលអ្នកត្បាញយកមកជ្រលក់ពណ៌ ឬគៀតដើម្បីលើកជាគោមផ្កាផ្សេងៗតាមចំណង់ចំណូលចិត្តរបស់គេ។ ក្រោយពេលរៀបចំក្បាច់ផ្សេងៗរួចរាល់ហើយ គេយកវាទៅខារបញ្ចូលក្នុងខ្នារដើម្បីត្បាញ។ **ចងគៀត** គឺជាវិធីធ្វើឲ្យហូលនីមួយៗមានក្រឡាគោម ទៅជាក្បាច់ប្លែកៗ តាមចំណង់ចំណូលចិត្តរបស់អ្នកត្បាញហូលម្នាក់ៗ។ ការធ្វើហូលមានរបៀបប្លែកៗគ្នាទៅតាមតំបន់ផ្សេងៗ ប៉ុន្តែនៅខេត្តតាកែវការធ្វើហូលវាមានលក្ខណៈដូចគ្នាទាំងមូលតែម្តង។



រូបភាពការចងគៀតបង្កើតជាគោមផ្កាផ្សេងៗ



រូបភាពការចងគៀត

## ៨. ការជ្រលក់ពណ៌

ការជ្រលក់ពណ៌មានច្រើនដំណាក់កាលទម្រាំតែបានយកទៅត្បាញ។ យើងត្រូវយកសូត្រដែលទិញពីផ្សារយកមកស្ងោរជាមួយទឹកក្តៅ ឬដាក់ស្ងោរជាមួយទឹកខ្មេះ។ បន្ទាប់មកដាក់ទឹកលាយជាមួយសាច់ដូរ ដើម្បីឲ្យសាច់សូត្រវាមានភាពទន់វាងាយស្រួលជ្រលក់ល័ក្ខ។ ពេលយើងធ្វើចំណុចខាងលើរួចពល់ហើយយើងត្រូវលាយល័ក្ខដែលទិញមកពីផ្សារ។ ជ្រលក់ល័ក្ខលើកទី១វាមិនសូវបានពណ៌ដិតទេ ត្រូវជ្រលក់លើកទី២ ទី៣ និងទី៤ទើបបានពណ៌ដិត ហើយត្រូវយកសូត្រដែលជ្រលក់ទាំង៤លើក នឹងយកទៅស្ងោរមិនកំណត់ពេលទេ។ ការប្រើពេលប្រហែលជា១ ឬ២ដងនោះយើងអាចលើកចេញបានហើយយកទៅលាងជាមួយនឹងសាប៊ូឲ្យវាអស់ជាតិចេញពណ៌ទើបស្រង់យកមកហាលឲ្យវាស្ងួតទឹក។ បន្ទាប់មកទៀតយើងត្រូវឲ្យទឹកបាយវា បើមិនឲ្យទឹកបាយវាទេធ្វើឲ្យទន់ពិបាកនឹងត្បាញ ការឲ្យទឹកបាយគឺយើងត្រូវដាំបាយ ហើយពេលវាពុះយើងត្រូវដាត់យកទឹកទុកសម្រាប់ពេលដែលយើងស្ងោរសូត្រជាមួយល័ក្ខហើយ។ ដាំបាយឲ្យពុះហើយត្រូវដាត់ទឹកបាយឲ្យត្រជាក់ ឬត្រូវទុករយៈពេល១ទៅ២ថ្ងៃទើបយកសូត្រដែលបានជ្រលក់និងស្ងោរហើយយកទៅដាក់ជាមួយទឹកបាយនោះ។ ការជ្រលក់ល័ក្ខនេះគឺជ្រលក់ទៅតាមផ្នែកដែលយើងអន្ទង ផ្នែពណ៌អ្វីត្រូវជ្រលក់ពណ៌នោះ។ នេះជារបៀបជ្រលក់ពណ៌នៅសម័យនេះដោយសារតែនៅតំបន់ជិតភ្នំជីសូរពួកគាត់ធ្វើទៅតាមរបៀបដូចៗគ្នា។



ពាងត្រាំមរ (ត្រុំ) នៅអង្គការស្ត្រី

សូត្រដែលចងបានក្បាច់គោមហើយ ហៅថា "គៀត"។ ក្រោយពីស្រាវសរសៃសូត្រពីដង្កូវនាងរួចហើយ គេយកសូត្រឆៅនេះទៅប្រមោក ដើម្បីលាងសម្អាតសម្រាប់ជ្រលក់ពណ៌ ផ្សេងៗទៅតាមការចង់បាន។ ក្រោយពីការប្រមោកលាងសម្អាតសូត្ររួចហើយគេយកសូត្រនោះទៅខារដាក់បំពង់រួចហើយយកទៅកុងបន្តដើម្បីចងគៀតឡើងគោម។ ក្រោយពេលឡើងគោមហើយគេយកទៅជ្រលក់ពណ៌តាមការចង់បាន។ ក្រោយពីជ្រលក់ពណ៌គៀតរួចហើយគេចាប់ផ្តើមកុងដាក់ខ្នារដើម្បីយកទៅត្បាញ។ ប៉ុន្តែបច្ចុប្បន្នក្នុងប្រទេសកម្ពុជាស្ទើរតែគ្រប់ទីកន្លែងច្រើនតែប្រើល័ក្ខគីមីដែលមានលក់នៅទីផ្សារដោយមូលហេតុថា វាមានភាពងាយស្រួលមិនចាំបាច់ចូលទៅក្នុងព្រៃដើម្បីស្វែងរកសំបកឈើមកធ្វើជាល័ក្ខ។ ទោះជាយ៉ាងណាក៏ដោយនៅមានបញ្ហាចំពោះភាពមិនឋិតថេរដោយសារផលិតផលសូត្រខ្មែរជាច្រើនឥឡូវមិនសូវជ្រលក់ពណ៌ធម្មជាតិទេ។ ច្រើនតែប្រើល័ក្ខគីមីដែលជាផលិតផលសម្រេចនាំចូលពីបរទេស។ ដូច្នេះការប្រើប្រាស់ល័ក្ខធម្មជាតិរបស់ខ្មែរវាមិនសូវជាសម្បូរដោយសារតែមានការបាត់បង់ព្រៃឈើ ដែលសម្រាប់មកធ្វើជាល័ក្ខដើម្បីជ្រលក់ពណ៌ត្បាញហូល។ ល័ក្ខកញ្ចប់មានគ្រប់ពណ៌ហើយមានតម្លៃថោកជាងល័ក្ខធម្មជាតិវាមានភាពងាយស្រួល ក្នុងការត្បាញដោយមិនប្រើរយៈពេលយូរ។



ការជ្រលក់ពណ៌ធម្មជាតិ (មរ)



ការប្រើប្រាស់លក្ខ័គីមីនាពេលបច្ចុប្បន្ន

បច្ចុប្បន្នជ្រលក់តែម្តងក៏អាចត្បាញបានដែរ គឺមិនសូវជាចំណាយពេលយូរដូចពីមុនទេប៉ុន្តែមិនសូវមានអ្នកត្បាញដោយសារតែមិនសូវឲ្យតម្លៃទៅលើរបរនេះ។ ជាពិសេសក្មេងៗជំនាន់ក្រោយគឺមិនចូលចិត្តទេ មានតែមនុស្សចាស់ទេដែលគាត់នៅព្យាយាមត្បាញព្រោះវាជាមុខរបរប្រចាំថ្ងៃរបស់គាត់។

ដូចជាការធ្វើល័ក្ខធម្មជាតិ ដោយសារតែថាទម្រាំតែបានយកមកធ្វើជាល័ក្ខគឺ ត្រូវចូលក្នុងព្រៃដើម្បីទៅស្ទោះសំបកឈើមកធ្វើជាល័ក្ខមានច្រើនដំណាក់កាលទៀត។ ប៉ុន្តែហូលដែលជ្រលក់ល័ក្ខធម្មជាតិវាមិនសូវជាឆើតទេតែមើលទៅស្រស់មានភាពភ្លឺរលោងជាងហូលដែលជ្រលក់ល័ក្ខគីមី។ ប្រភេទសំពត់ដែលជ្រលក់ពណ៌កញ្ចប់ ងាយនឹងចេញពណ៌ណាស់។ ពេលយកមកប្រើប្រាស់ ត្រូវការពារមិនឲ្យប៉ះសារជាតុសើមទេ ព្រោះវាងាយនឹងចេញពណ៌។ ផ្ទុយទៅវិញល័ក្ខធម្មជាតិ ទោះបីជាប៉ះសាជាតុសើមក៏វាមិនងាយនឹងចេញពណ៌ដែរ។

ស្ត្រីខ្មែរចូលចិត្តប្រើប្រាស់សំពត់ហូលផាមួងនិង ចរបាប់ ប្រហែលជា៨០%ដែលពួកគាត់បានប្រើសម្លៀកបំពាក់ដែលធ្វើពីសរសៃសូត្ររបស់ខ្មែរដើម្បីចូលរួមនៅក្នុងកម្មវិធីផ្សេងៗដែលទាក់ទងទៅនឹងប្រពៃណីខ្មែរ និងចូលរួមក្នុងកម្មវិធីបែបជាអន្តរជាតិ។ ប្រភេទល័ក្ខអាឡឺម៉ង់ ដែលពេញនិយមនៅទ្វីបអឺរ៉ុប ហើយប្រភេទល័ក្ខមួយបែបទៀតគឺ ជាល័ក្ខរបស់ថៃ ដែលមានពណ៌ល្អឆើត ប៉ុន្តែពួកអឺរ៉ុបមិនសូវជាចូលចិត្តប្រើប្រាស់វាទេ ដោយមូលហេតុវាប៉ះពាល់ដល់ស្បែក។

ការជ្រលក់ល័ក្ខគៀតមិនមែនជ្រលក់តែមួយពណ៌ ហើយធ្វើតែម្តងដូចជាការជ្រលក់ល័ក្ខសូត្រផ្ទៃនោះទេ។ ជ្រលក់ល័ក្ខគៀតត្រូវធ្វើឡើងច្រើនដងទៅតាមចំនួនពណ៌ដែលមាននៅលើផ្ទៃសំពត់ហូល។ បន្ទាប់ពីជ្រលក់ពណ៌លើកទីមួយហើយត្រូវយកគៀតនោះទៅផ្តាច់ចំណងគៀតនិងរុំគៀតសារថ្មីនៅត្រង់ចំណុចដែលមិនត្រូវការឲ្យពណ៌លើកទីពីរនោះជ្រាបសរសៃសូត្រ។

ល័ក្ខដែលប្រជាជនប្រើប្រាស់ពេញនិយមបំផុតសព្វថ្ងៃសម្រាប់ការជ្រលក់ពណ៌សូត្រគឺប្រភេទល័ក្ខថៃ ព្រោះវាមានតម្លៃថោកជាងល័ក្ខខ្មែរ និងល័ក្ខអាឡឺម៉ង់។ ល័ក្ខថៃមានពណ៌ច្រើននិងមានពណ៌ដិតធ្វើឲ្យហូលមានពណ៌ឆើត និងភ្លឺរលោងជាងហូលដែលប្រើល័ក្ខធម្មជាតិ។

សូត្រដែលស្រាវចេញពីដង្កូវនាងបានជ្រលក់ពណ៌ដែលផ្សំចេញពីធម្មជាតិដែលមានដូចកាលពីបូរាណដែរ។ ល័ក្ខធម្មជាតិដែលផ្សំចេញពី សំបកឈើ ផ្លែ ផ្កា ស្លឹកធ្វើឲ្យចេញជាល័ក្ខធម្មជាតិបានដែលមានឈ្មោះជាច្រើនដូចជា សំបកសង្កែ ត្រាំទឹកបានពណ៌ធម្មជាតិដែលបានពណ៌

ត្នោត។ ស្លឹកចេក ស្លឹកប្រម៉ាត់មនុស្ស ស្លឹកស្ដៅ ស្លឹកឫស្សីត្រាំងទឹកបានពណ៌បៃតងស្រាល និង ស្លឹកចេក ស្លឹកប្រម៉ាត់មនុស្ស ស្លឹកស្ដៅ ស្លឹកឫស្សីត្រាំទឹកច្រេះបានពណ៌ខៀវស្រាល។

ពេលបច្ចុប្បន្នការជ្រលក់ពណ៌មានភាពងាយស្រួលជាង ការជ្រលក់ពណ៌នៅពេលមុនៗ ដោយពេលឥឡូវគេទិញសូត្រ និងល័ក្ខគីមីមកពីផ្សារដោយមិនចាំបាច់ធ្វើបែបបូរាណ មានដូច ជាការចិញ្ចឹមដង្កូវនាង ឬស្វែងរកសំបកឈើក្នុងព្រៃទេ។ គ្រាន់តែចង់បានពណ៌អ្វីគឺបានភ្លាមមិន បាច់ទៅរកសំបកឈើយកមកបុក ឬចិញ្ច្រាំ ស្ងោរ និងចម្រោះទេ សូម្បីតែប្រើក្មេងៗឲ្យទៅទិញក៏ បានល័ក្ខយកមកលាយជ្រលក់បានដែរ។ ការជ្រលក់ពណ៌មានច្រើនដំណាក់កាលទៅតាមផ្នែក របស់វាមុនដំបូងយើងត្រូវយកសូត្រដែលទិញមកពីផ្សារទៅស្ងោរលាយជាមួយទឹកខ្មេះរួចហើយ ស្រង់ចេញឲ្យស្ងួតទឹក យកទឹកត្រជាក់ធម្មតាលាយជាមួយសាច់ដូរដើម្បីឲ្យវាមានភាពភ្លឺរលោង និងជ្រាបពណ៌បានល្អ បន្ទាប់មកទៀតលាយល័ក្ខកញ្ចប់ចំនួនមួយកញ្ចប់ ឬពីរកញ្ចប់។ បើជ្រ លក់ហើយនៅមានពណ៌ភ្លាវទៀតយើងត្រូវថែមល័ក្ខទៀតរហូតមានពណ៌ជិតប្រហែលជាបួន ដងក្នុងការជ្រលក់ពណ៌មួយលើក។ ហើយមិនត្រូវចាក់ទឹកល័ក្ខដែលលាយជ្រលក់ពណ៌នោះទេ គឺយើងត្រូវទុកស្ងោរជាមួយសូត្រដែលជ្រលក់នោះ យើងត្រូវទុកវាឲ្យពុះទើបស្រង់ចេញឲ្យស្ងួត ទឹកហើយត្រូវឲ្យទឹកបាយវាដើម្បីស្រួលត្បាញ។

ការធ្វើរបៀបនេះសុទ្ធតែដូចគ្នាទាំងអស់សម្រាប់ប្រជាជនដែលប្រកបរបរត្បាញហូលនៅ តំបន់ជុំវិញភ្នំជីសូរ្យ។ ការជ្រលក់ពណ៌នេះមានភាពងាយស្រួលយ៉ាងខ្លាំងដល់អ្នកដែលប្រកប របរនេះ គឺពួកគាត់មិនចាំបាច់ចិញ្ចឹមដង្កូវនាងសម្រាប់ស្រាវយកសូត្រ និងទៅព្រៃដើម្បីស្វែងរក សំបកឈើមកធ្វើល័ក្តទេ។ ធ្វើដូច្នេះការត្បាញហូលទើបបំពេញតំរូវការរបស់អ្នកប្រើប្រាស់ទាន់ ពេល។ ការជ្រលក់ពណ៌សូត្រនេះគឺធ្វើទៅតាមសូត្រដែលយើងអន្ទងផ្ទៃពណ៌អ្វីយើងត្រូវជ្រលក់ ពណ៌នឹងដើម្បីឲ្យដូចមានពណ៌ដូចសូត្រផ្ទៃ។

## ៩. បច្ចេកទេសត្បាញ

ក្នុងការរៀបចំកីតម្បាញ មុនដំបូងគេត្រូវយកសូត្រធៅទៅប្រមោករួចទើបយកទៅអន្ទង ទៅតាមចំនួនដែលចង់បាន។ ក្រោយពេលដែលអន្ទងរួចទើបគេយកទៅជ្រលក់ពណ៌ដែលបាន រៀបរាប់ខាងលើ។ រួចហើយទើបយកទៅមូរចូលក្តារ ក្រោយមកគេចាប់ផ្តើមចាក់ធ្មេញ រួចហើយ

ទើបផ្គរ(បន្តឬភ្ជាប់) សម្រាប់ត្បាញៗ ក្នុងក្តារមូរផ្ទៃនេះគេត្រូវប្រើមនុស្ស២ទៅ៣នាក់សំរាប់ជួយ បន្ទាប់មកគេចាក់ធ្មេញឈើ ដោយធ្មេញមួយមានពីរសរសៃ រួចទើបគេតំឡើងលើកីហើយទើប គេតផ្គរៗ តផ្គរគឺចូលប្រទាក់គ្នាគេដាក់សរសៃផ្ទៃ១សរសៃ បន្ទូលតផ្គររួចគេយកសរសៃដែលចាក់ ចេញពីធ្មេញចង និងឈើទ្រវែងមួយប៉ុនកូនដៃ ហើយដងឈើទៅនឹងសំរួចទើបគេត្បាញយក ដើមសំពត់ៗ ពេលត្បាញបានប្រវែង ៥សង់ទីម៉ែត្រ ទើបគេកាត់ព្រុយដែលគេយកផ្ទាំងសំពត់៥ សង់ទីម៉ែត្រទៅដាក់ជាមួយកូនគោលតូចៗដែលនៅក្នុងសំរួចទើបគេចាប់ផ្តើមត្បាញជាផ្លូវការៗ គេក៏ចាប់ប្រើឈើជាចន្ទាល់ដើម្បីឲ្យសំពត់សន្ធឹងបានល្អ និងប្រើម្ជុលដែរ ដើម្បីកុំឲ្យសាច់សំពត់ ជ្រួញៗ ក្នុងការត្បាញមានធ្មេញមួយគឺគេដាក់សូត្រពីរសរសៃទៅក្នុងប្រហោងធ្មេញតែមួយទើប យើងឃើញនៅពេលគេជាន់ឈ្នាន់មានសូត្រពីរសរសៃខាងលើ(ខាងខុសនៃសំពត់) និង១សរសៃ នៅផ្នែកខាងក្រោម(ខាងត្រូវនៃសំពត់)ៗ

ក្នុងការត្បាញដំបូងគេជាន់ឈ្នាន់ទី១ រួចគេបោះត្រល់ហើយគេវាយសរសៃគាតឲ្យចូល ក្នុងសរសៃសំពត់បន្ទាប់មកគេជាន់ឈ្នាន់ទី២ រួចឈ្នាន់ទី៣រួចមកជាន់ឈ្នាន់ទី១វិញៗ មានន័យ ថាឈ្នាន់ទី១ និងឈ្នាន់ទី៣ គឺលក្ខណៈសរសៃផ្ទៃមានលក្ខណៈដូចគ្នា គឺពីរសរសៃនៅលើ និង មួយសរសៃនៅក្រោមដូចនេះបរិមាណសរសៃពីរនៅខាងលើមានច្រើនជាង២សរសៃនៅខាង ក្រោម នាំឲ្យគេកំណត់ផ្នែកខាងក្រោមគឺជាខាងត្រូវៗ ពេលគេត្បាញត្រូវកំណត់ចំណាំគាតដើម្បី កុំឲ្យច្រឡំ(នាំឲ្យខុសក្បាច់)ៗ បើមាននរណាមករើគាតលេង នាំឲ្យគេមានការលំបាកក្នុងការរក លេខរៀងរបស់គាតៗ ក្នុងការប្រើគាតមួយ គេត្រូវរាប់ចំនួនសរសៃវាកុំឲ្យលើស ឬខ្វះៗ

កាលណាគេត្បាញបានសំពត់ទាំងនោះចូលក្នុងសំពត់ ដូចនេះយើងក៏ត្រូវពន្លាក្តារមូរ និងរឹតឈើរឹតជាថ្មីៗ នៅពេលដែលមានការដាច់សរសៃផ្ទៃគេត្រូវរើករកមុខរបស់វា រួចតវាឡើង វិញៗ នៅពេលដែលគេប្រើផ្ទៃ ជិតអស់គេត្រូវបន្ធូរខ្សែរឹត ហើយប្រើរឹត និងត្រដោកក្តារចុង ទៅឯ ជិតបន្ទូលតផ្គរវិញៗ ចំពោះសរសៃសូត្រផ្ទៃដែលគេចោលគឺសល់តែ០,៥ម៉ែត្រនៃក្តារមូរៗ

ចំពោះពេលគេចង់កាត់សំពត់ក្បិនណាមួយគេត្រូវត្បាញដើមសំពត់ ដើម្បីឲ្យងាយស្រួល ក្នុងពេលតំឡើងវាឡើងវិញ យើងត្រូវយកវាទៅទាក់ជាមួយដែកគោលរបស់សំពត់ សារជាថ្មីរួច ត្បាញជាបន្តទៀតរហូតទាល់តែដល់ម៉ែត្រ(៤ម៉ែត្រស្មើ២សំពត់) ទើបកាត់ចេញម្តងដើម្បីទៅលក់ ឬឈ្នួញកណ្តាលមកយកៗ

ការធ្វើរបៀបនេះទាល់តែអស់សូត្រនៅក្នុងកីទើបអ្នកត្បាញចាប់ផ្ដើមទៅអន្ទងទៀតដើម្បីយកមកបន្តរបររបស់គាត់។ ការយកទៅអន្ទងមានរយៈពេលប្រហែលមួយសប្ដាហ៍ ឬពីរសប្ដាហ៍ទើបរួច ហើយយកមកដំឡើងដាក់ក្នុងកីសម្រាប់ត្បាញបន្តទៀតឡើងវិញ។



អ្នកតម្បាញនៅភូមិក្ដាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ



ស្ត្រីតម្បាញនៅភូមិក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ

## ១០. ប្រភេទហូល និងការប្រើប្រាស់

រាល់ការត្បាញ គឺធ្វើដោយស្ត្រី សំពត់ហូលចែកចេញជា២ប្រភេទគឺ:

១. ហូលដែលមានលក្ខណៈបែបបុរាណៈ មានរូបប្រាសាទ និងរូបបែបជាសាសនាដែលជាឈុតឆាកក្នុងរឿងដែលទាក់ទងទៅនឹងព្រះពុទ្ធ។

២. ហូលដែលពេញនិយមនៅសម័យបច្ចុប្បន្នដែលមានរូប ផ្កាម្ទេស ផ្កាថ្កុល ផ្កាយព្រឹ ផ្កាម្ទិះ ផ្កាម្រេច ផ្កាពាំង ផ្កាសណ្ដាន់ រូបសត្វពីងពាង។ ក្នុងប្រពៃណីខ្មែរមានក្បាច់គោមហូលច្រើនណាស់ ដែលកើតឡើងពីគំនិតច្នៃប្រឌិតផ្សេងៗ ពីក្បាច់គោមបុរាណរបស់សិប្បករយើងពីមួយជំនាន់ទៅមួយជំនាន់។ តាមការឲ្យដឹងពីអ្នកតម្បាញចាស់ៗបានឲ្យដឹងថា ក្នុងការធ្វើហូលមួយក្បិន គេត្រូវការរយៈពេលយូរណាស់ គឺយ៉ាងតិចបីខែ ព្រោះពួកគាត់ត្រូវចិញ្ចឹមដង្កូវនាងដើម្បីផលិតសូត្រជ្រលក់ពណ៌ និងត្បាញដោយខ្លួនឯង។ ការត្បាញហូលទាមទារឲ្យមានការព្យាយាមខ្ពស់។ អ្នកត្បាញត្រូវចេះតម្រឹមសរសៃសូត្រដើម្បីឲ្យលេចចេញជារូបគោមត្រង់ និងស្អាតល្អ។ គោមហូលមកដល់បច្ចុប្បន្នមានរូបក្ងោកនៅផ្នែកខាងក្រោមដែលកំពុងតែឈរលើមែកឈើសម្លឹងទៅមុខត្រង់ ហើយនៅផ្នែកខាងលើមានសត្វចាបកំពុងរកមើលចំណី មើលទៅដូចជារូបធម្មជាតិ ហើយហូលប្រភេទនេះមានការពេញនិយមណាស់សម្រាប់អ្នកមានដែលរស់នៅទីក្រុង ដោយសារតែវាមានតម្លៃថ្លៃជាងហូលដែលមានរូបផ្កាធម្មតា។ មួយប្រភេទទៀតមានរូបសត្វចាបពីរនៅទន្ទឹមគ្នានៅខាងលើដើមដូង ហើយនៅខាងក្រោមដើមដូងមានសត្វខ្លាពីរនៅចន្លោះដើមដូង មួយបែរទៅមុខ និងមួយទៀតបែរទៅក្រោយជាមួយ។ វាមានភាពលំបាកក្នុងការត្បាញ និងប្រើរយៈពេលយូរហើយហូលប្រភេទនេះមានអ្នកបញ្ជាទិញទើបមានអ្នកត្បាញ ដោយសារតែវាមានតម្លៃថ្លៃ។ ប្រភេទហូលដែលមានច្នៃជាគ្រាប់កន្ទួតក៏មានការពេញនិយមនៅក្នុងទីផ្សារសូត្រផងដែរ។ ដូច្នេះហូលមានគោមគ្រាប់កន្ទួតមាននៅគ្រប់ទីកន្លែងដោយសារតែវាមានភាពងាយស្រួលក្នុងការចង និងត្បាញវាមិនមានដូចជារូបសត្វនិងរូបប្រាសាទធ្វើឲ្យមានការស្មុគស្មាញក្នុងការចងគោម។ ដោយមូលហេតុវាមិនប្រកាន់ថាមនុស្សចាស់ ឬក្មេងទេអាចប្រើប្រាស់បានដូចគ្នា និងសម្រាប់ចូលរួមក្នុងពិធីផ្សេងៗ។

ហូលប្រើប្រាស់ល័ក្ខធម្មជាតិមានពណ៌មិនសូវឆើតទេ តែវាមានការពេញនិយមសម្រាប់អ្នកទីក្រុង និងជនបរទេសដែលចូលចិត្តប្រើប្រាស់វា ដោយវាមិនប៉ះពាល់ដល់ស្បែក និងមើល

ទៅមានភាពស្រស់ស្អាត។ ប៉ុន្តែសម្រាប់ក្មេងៗវិញគឺចូលចិត្តពណ៌ឆើតៗដោយមើលទៅវាស្រស់ស្អាត មានតែល័ក្ខកញ្ចប់ទេដែលមានពណ៌ឆើត និងពណ៌ច្រើនឲ្យយើងជ្រើសរើសតាមចិត្តដែលយើងស្រលាញ់។



សំពត់ហូលរូបមេអំបៅ និងរូបផ្កា



សំពត់ហូលក្បាច់ផ្កាចាន់បន្តក់



ហូលក្រឡាសំណាញ់ជជើង

ហូលដែលបានរៀបរាប់ខាងលើ មានការពេញនិយមសម្រាប់ប្រើប្រាស់នៅក្នុងពិធីបុណ្យជាតិ និងមង្គលការ។ ហូលពិតានមានលក្ខណៈពិសេសជាងហូលធម្មតាត្បិតហូលនេះមានលើកគោមជារូបផ្សេងៗដែលទាក់ទងនឹងជំនឿសាសនា។  ដោយហេតុថាហូលពិតានមានលើកគោមជាសាច់រឿង  និងមានក្បាច់ពិសិដ្ឋអ្នកស្រុកមានតំណមមិនឲ្យយកហូលពិតានមកប្រើ  ឬស្លៀកដូចហូលធម្មតាទេទោះជាហូលនោះថ្មីមិនទាន់អភិសេកក្តីងក៏ដោយ។ មិនតែប៉ុណ្ណោះគោមដែលប្រើនៅលើហូលពិតានខ្លះក៏មិនត្រូវយកមកត្បាញលើហូលសម្រាប់ស្លៀកដែរ។



សំពត់ហូលរូបនាគពាជ និងចេកមាស

ហូលពិតានមានឈ្មោះផ្សេងៗដូចជា៖ ពិតានរូបព្រះ ពិតានរូបប្រាសាទ ពិតានរូបទង់ ពិតានរូបទូក។ ឈ្មោះនេះអាស្រ័យលើរូបនៅលើហូល និងការហៅទៅតាមតំបន់ផ្សេងៗ។ នៅក្នុងនិក្ខេបទបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាដែលសិក្សាអំពីប្រពៃណីតម្បាញហូលខ្មែរ (LeTisssge Traditionnel des Hol Cambodgrens) អ្នកស្រី សេក យូអួន រាប់បញ្ចូលគោមទាំងនោះ រួមមាន រូបព្រះ រូបវិហារ រូបទង់ រូបហង្ស រូបទូក និងរូបផ្កាបិណ្ឌ។

វិធីសាស្ត្រក្នុងការត្បាញហូលពិតានស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការត្បាញហូលសំពត់ ព្រោះគេត្រូវយកសូត្រមកចងគាត និងជ្រលក់ពណ៌ដូចគ្នា ទៅនឹងដំណាក់កាលទាំងឡាយនៃការធ្វើហូល។ ប៉ុន្តែអ្នកត្បាញ មានប្រសាសន៍ថាពិតានពុំសូវមានអ្នកត្បាញទេ។ លុះត្រាតែមានអ្នកបញ្ជាទិញ។ គាត់មានប្រសាសន៍បន្តទៀតថា ការត្បាញពិតានហូលវាមានការពិបាកត្បាញ ដោយសារតែវាស្មុគស្មាញមានក្បាច់លំអនៅតាមពិតានមានជាសាច់រឿង ហើយឥឡូវនៅភូមិកញ្ចាងគឺ មិនមានអ្នកត្បាញទេ។ មានតែនៅភូមិផ្សេងៗទើបគេនៅបន្តមួយៗ។ ការតុបតែងលំអហូលនៅក្នុងភូមិកញ្ចាងមានលក្ខណៈសាំញ៉ាំខ្លាំងណាស់។ ការច្នៃក្បាច់លំអក៏មិនខុសពីស្រុក និងខេត្តផ្សេងៗទេ ពួកគេច្រើនច្នៃក្បាច់ទៅតាមទីផ្សារ។ ពេលខ្លះគេច្នៃក្បាច់ផ្សេងៗដើម្បីប្រជែងគ្នាដើម្បីលក់យកតម្លៃឲ្យខ្ពស់ជាងគេ។ ប្រជាជនភាគច្រើនធ្វើការច្នៃប្រឌិតក្បាច់បែបប្រពៃណីបុរាណខ្លះលាយជាមួយក្បាច់ថ្មីដើម្បីឲ្យប្លែក។ ក្បាច់លំអសំពត់ហូលមានការប្លែកពីគ្នាបន្តិចបន្តួចៗក្នុងការស្លៀកពាក់តាមមនុស្សប្រុស មនុស្សស្រី និងមានក្បាច់ផ្កាខ្លះ ផ្សេងៗទៀតអាចប្រើបានចូលរួមក្នុងពិធីផ្សេងៗ។ ប្រជាជននៅក្នុងភូមិកញ្ចាងប្រកបរបរត្បាញហូលតាំងពីជីដូនជីតារបស់គាត់មកម្ល៉េះ។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គេ គឺពឹងផ្អែកទាំងស្រុងទៅលើការត្បាញហូល។ ដោយសារតែមានអ្នកភូមិគាត់មានប្រសាសន៍ថា គាត់ចេះត្បាញតាំងពីអាយុ១៣ឆ្នាំទៅ១៥ឆ្នាំ។ ដោយមូលហេតុនេះហើយទើបមានប្រជាជនមានបទពិសោធន៍ជាមួយនឹងការតម្បាញហូលនៅក្នុងភូមិរបស់គាត់។ ជាក់ស្តែងតាមការធ្វើបទសម្ភាសន៍លោកយាយ សាន ដែលគាត់មានអាយុ៧៨ឆ្នាំ។ គាត់មានប្រសាសន៍ថាហូលមានច្រើនប្រភេទណាស់ ប៉ុន្តែហូលដែលសំខាន់ជាងគេ និងពេញនិយមនៅក្នុងភូមិកញ្ចាងនេះ គឺហូលដែលមានរូបសត្វផ្សេងៗដូចជា ហូលរូបសត្វក្ងោក ទន្សាយ ត្រី កូនគោ និងមានជាច្រើនទៀត។ ក្រៅពីរូបសត្វនៅមានរូបគោមផ្កាយព្រឹក គ្រាប់កន្ទួត កុលាប ស្មៅមួយដើម និងមានគោមផ្សេងៗទៀត។ ប៉ុន្តែក្បាច់ហូលដែលបានរៀបរាប់

ខាងលើនេះមានតែប៉ុន្មានក្បាច់ប៉ុណ្ណោះដែលអ្នកភូមិគាត់នៅត្បាញបែបជាលក្ខណៈគ្រួសារ។

ប្រភេទគោមហូលដែលបានរៀបរាប់ខាងលើនេះគឺ ពេញនិយមនៅក្នុងភូមិកញ្ចាងដែលមានប្រជាជនត្បាញច្រើនសម្រាប់ឈ្មួញកណ្ដាល។ គោមហូលដែលប្រជាជននៅតែត្បាញនិងនៅតែពេញនិយមនោះគឺគោមគ្រាប់កន្ទួតដែលឈ្មួញកណ្ដាលបានបញ្ជាទិញប្រភេទគោមហូលនេះ។ ដូច្នេះអ្នកត្បាញភាគច្រើនត្បាញតាមគ្នាដោយមូលហេតុវាទើបតែមានថ្មី។ ឈ្មួញកណ្ដាលត្រូវការប្រភេទហូលពេញនិយម ដូច្នេះអ្នកត្បាញមានការច្នៃម៉ូតតាមឈ្មួញប្រាប់ដើម្បីទទួលបានតម្លៃថ្លៃ ប៉ុន្តែមិនទាំងអស់ទេគឺមើលទៅលើសាច់សំពត់ និងប្រភេទគោមទៀត។ សំពត់ហូលលក់បានតម្លៃថោកដោយសារតែមានអ្នកត្បាញប្រភេទគោមនេះមានច្រើនសាច់សំពត់គ្រាស់ ឬស្ដើង និងមានស្នាមដាច់ច្រើន។

នៅក្នុងភូមិនេះមានគ្រួសារមួយចំនួនបានធ្វើគោមហូលដោយខ្លួនឯង។ ប៉ុន្តែគេមិនចង់ឲ្យមានអ្នកមកចំលងទេ ដូច្នេះពួកគេមានការលាក់លៀមមិនឲ្យអ្នកណាដឹងក្រៅពីអ្នកដែលរស់នៅជាមួយគ្នា ឬសាច់ញាតិរបស់ខ្លួនទេ។ ដោយសារតែដូច្នេះទើបនៅក្នុងភូមិមានតម្លៃហូលមិនស្មើគ្នាមានហេតុផលជាច្រើនដូចជា អ្នកខ្លះមានការត្បាញបានស្អាត មានការច្នៃប្រឌិតខ្ពស់ហើយសាច់សំពត់ហាប់ និងជាប្រភេទហូលដែលគេពេញនិយម បែបបុរាណ ឬទាន់សម័យនាពេលបច្ចុប្បន្ននេះវាធ្វើឲ្យទទួលបានតម្លៃខ្ពស់។ ប្រសិនបើបង្កើតគោមហូល ឬក្រមាឲ្យកាន់តែមានច្រើនប្រភេទនោះធ្វើឲ្យកាន់តែពេញនិយមទៅតាមសម័យកាល។



រូបភាពហូលពិតាន

## គ. ទំនាក់ទំនងរវាងសិប្បករ

## ១. ប្រព័ន្ធតម្បាញក្នុងភូមិ

### ១.១. ទំនាក់ទំនងនៅក្នុងគ្រួសារ

អ្នកប្រកបរបរតម្បាញ ភាគច្រើនមានជីវភាពមធ្យម ពុំសូវឃើញមានទ្រព្យសម្បត្តិច្រើនដូចអ្នកជួញដូរធំៗនៅតាមទីផ្សារទេ។ ផលកម្រៃដែលបានពីការត្បាញហូលគឺអាចបំពេញជីវភាពប្រចាំថ្ងៃ។ ដោយឡែកអ្នកត្បាញហូលនៅភូមិកញ្ចាងពុំត្បាញជាប់ឬមានតែមួយមុខឡើយ។ ពេលទំនេរពីធ្វើស្រែទើបគាត់ធ្មៀតមកចងគាត ឬត្បាញដើម្បីឲ្យទាន់ពេលឈ្មួញកណ្ដាលត្រូវការ។ ប្រជាជនដែលរស់នៅក្នុងភូមិជាកសិករដែលក្នុងមួយឆ្នាំៗពួកគាត់ធ្វើស្រូវវស្សាតែម្ដង។ ម្ល៉ោះហើយទើបគ្រួសារមួយចំនួនមានកីច្រើនដោយសារមានស្វាមី បងប្អូន ជួយក្នុងត្បាញ និងមានមុខរបរបន្ទាប់បន្សំសម្រាប់ប្រចាំជីវភាពគ្រួសារ។ អ្វីដែលគួរឲ្យកត់សម្គាល់ គឺអ្នកចេះត្បាញហូលមិនកំណត់ថាស្រី ឬប្រុសនោះទេ។ កន្លងមកឲ្យតែឮពាក្យថា តម្បាញយើងគ្រប់គ្នាគិតថាសុទ្ធតែស្ត្រី ដូចជាការត្បាញ ហូល ផាមួង និងក្រមានៅតំបន់ផ្សេងៗ។

ជាទូទៅបុរសមានតួនាទីទៅធ្វើការនៅខាងក្រៅផ្ទះដើម្បីរកស៊ី ឬធ្វើចម្ការស្រែនៅទីផ្សេងៗ ហើយពួកគេតែងតែធ្មៀតពេលជួយស្ត្រីជាប្រពន្ធ ម្ដាយ និងបងប្អូនស្រីក្នុងកិច្ចការត្បាញហូល តែបើវិភាគឲ្យល្អិតល្អន់ទៅបុរស និងស្ត្រី ត្រូវចេះជួយចែករំលែកការងារគ្នាទៅវិញទៅមក ដើម្បីបង្កើត និងរក្សាសុភមង្គលនៅក្នុងគ្រួសារ។ កិច្ចការដែលបុរសជួយស្ត្រីមានដូចជាការរៀបចំកីសម្រាប់ត្បាញ ជួយអន្ទង ជ្រលក់ពណ៌ និងត្បាញៗ។ នៅរដូវវស្សាប្ដីប្រពន្ធគេនាំគ្នាទៅស្រែប្រសិនបើផ្ទះណាមានមនុស្សចាស់នៅជាមួយនោះផ្ទះនោះនៅតែត្បាញៗ។

ប៉ុន្តែប្រសិនបើផ្ទះណាគ្មានមនុស្សចាស់រស់នៅជាមួយទេ គឺផ្ទះនោះត្រូវតែបិទទ្វាផ្ទះដើម្បីទៅធ្វើស្រែចម្ការ ឯការងារតម្បាញត្រូវទុកមួយឡែកសិនហើយសមាជិកទាំងអស់ត្រូវជួយគ្នាក្នុងការងារស្រែសិន ឬក៏ជួយការងារផ្សេងក្រៅពីធ្វើស្រែ។ លុះចប់កិច្ចការនេះហើយទើបចាប់ផ្ដើមត្បាញទៀត ប៉ុន្តែមកដល់ពេលនេះមិនដូចកាលពីមុនឡើយ ដោយសារតែឥឡូវស្ត្រីជាម្ដាយ ឬកូនស្រីមិនសូវទៅស្រែចម្ការទេ។ ពួកគេនៅផ្ទះនៅថែរក្សាទ្រព្យសម្បត្តិ និងមើលថែកូនចៅដែលនៅតូចៗ និងនៅប្រកបរបរប្រចាំថ្ងៃរបស់ពួកគេ។ មិនចាំបាច់បិទទ្វារផ្ទះចោលដើម្បីទៅស្រែនិងចម្ការដូចពីមុនទេ។ ដោយសារតែឥឡូវមានប្រើបច្ចេកវិទ្យាទំនើបខាងធ្វើស្រែ និងចម្ការមិនប្រើ

រយៈពេលយូរទេ ហើយផលដែលទទួលបានពីការធ្វើក៏បានផលច្រើនជាងមុនដែរ។

គេទុកពេលសម្រាប់ទៅរកស៊ីផ្សេងៗទៀតមិនចាំតែធ្វើស្រែតែមួយមុខប៉ុណ្ណោះទេ។ ម្យ៉ាងវិញទៀតនៅក្នុងគ្រួសារចេះជួយគ្នាមិនប្រកាន់ថា វាមិនមែនជាកម្មសិទ្ធរបស់អ្នកណាឡើយ។ ធ្វើឲ្យគេចូលរួចនៅក្នុងសមាជិកគ្រួសាររបស់ពួកគេ ដោយសារតែដូច្នេះហើយទើបមានគ្រួសារខ្លះមានកីត្បាញពីរ ទៅបីនៅក្នុងមួយគ្រួសាររបស់ពួកគេ។ ទោះជាមានសមាជិកណាម្នាក់ទៅធ្វើការផ្សេងក្រៅពីត្បាញហូលក៏នៅមានម្នាក់នៅត្បាញដែរ។ វាមានចំនួនតិចក៏ដោយប៉ុន្តែវានៅមានអ្នកដែលស្រលាញ់មរតកពីជីដូនជីតាបន្សល់ទុកឲ្យសម្រាប់ជាមុខរបរប្រចាំគ្រួសារ។

### ១.២. ទំនាក់ទំនងពីគ្រួសារមួយទៅគ្រួសារមួយ

នៅក្នុងលោកនេះមនុស្សយើងម្នាក់ៗតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមក មិនអាចកាត់ថ្លៃបានឡើយ។ ទោះជាអ្នកមានក្តី អ្នកក្រក្តីឲ្យតែមានសណ្តានចិត្ត និងមានភាពជិតស្និតទុកចិត្តគ្នាទៅវិញទៅមក។ ប្រជាជនពេលដែលគាត់រស់នៅកន្លែងណាស្រួលហើយគាត់មិនចង់ធ្វើការផ្លាស់ប្តូរទេ។ ដោយសារតែពួកគាត់មានទំនាក់ទំនងជាមួយគ្នា និងស្រលាញ់គ្នាដូចជាសាច់ញាតិរបស់គាត់។ ពេលខ្លះមានអ្នកជិតខាងពេលដែលគាត់មានម្ហូប ឬនំចំណីអ្វីគាត់តែងតែចែករំលែកឲ្យគ្នាទៅវិញទៅមក។ ម្យ៉ាងវិញទៀតមានគ្រួសារមួយចំនួនបានប្រវាស់ដៃគ្នាដើម្បីធ្វើស្រែជាការកាត់បន្ថការចាយវាយនៅក្នុងគ្រួសារ។ ចំណែកឯអ្នកតម្បាញវិញ កាលណាមានការត្រូវពឹងគ្នា ហើយពួកគេអាចធ្វើបានទៅតាមលទ្ធភាពដែលពួកគេអាចធ្វើបាន។ ទាំងនេះជាចរិកលក្ខណៈរបស់ប្រជាជនដែលប្រកបរបរតម្បាញហូលនៅភូមិកញ្ចាងនេះ។ ប្រសិនបើបានស្គាល់ពីដើមភូមិរហូតដល់ចុងភូមិ ឬក៏មានភូមិដែលនៅក្បែរៗគ្នាទៀតដែលបង្កើឲ្យមានទំនាក់ទំនងគ្នាកាន់តែជិតស្និតមួយកម្រិតទៀត។

បន្ថែមពីលើនេះទៀតពេលត្បាញតែងតែជួបនឹងបញ្ហាផ្សេងៗដោយមិនអាចជៀសផុតដូចជា ការខ្វះសូត្រ ល័ក្ខ និងឧបករណ៍ផ្សេងៗទៀតដើម្បីដោះស្រាយបញ្ហាចំពោះមុខបានភ្លាមៗគឺមានតែខ្ចីអ្នកជិតខាងយកមកប្រើប្រាស់សិន ពេលចប់កិច្ចការហើយទើបទិញសងវិញ។ នេះបញ្ជាក់ឲ្យឃើញថា ការប្រាស្រ័យទាក់ទងគ្នានៃជីវិតអ្នកត្បាញមានភាពជិតស្និត និងសេចក្តីទុកចិត្តហ៊ានលះបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដើម្បីជួយដោះទុក្ខធុរៈគ្នាទៅវិញទៅមក។ ប្រជាជនដែលគាត់រស់នៅក្នុងភូមិនេះបាននិយាយថាពួកគាត់មិនដែលប្រកាន់ថាគាត់ជាអ្នកត្បាញហូលហើយ

មានអ្នកដែលត្បាញហូលនៅភូមិផ្សេងមិនមានទំនាក់ទំនងគ្នានោះទេ ពួកគាត់នៅតែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតមិនប្រកាន់គ្នាឡើយ។

## ១.៣. ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ

មនុស្សយើងម្នាក់ៗមានទំនាក់ទំនងគ្នាយ៉ាងទូលំទូលាយមិនប្រកាន់ និងមានសារសំខាន់ណាស់ សម្រាប់ការរស់នៅប្រចាំថ្ងៃ។ ដោយសារតែនៅស្រុកស្រែចម្ការ ចម្ងាយពីភូមិមួយទៅភូមិមួយពុំសូវឆ្ងាយពីគ្នាធ្វើឲ្យអ្នកភូមិមានទំនាក់ទំនងគ្នាជាហូរហែ។ ប្រជាជនដែលរស់នៅភូមិផ្សេងគ្នាមានការពឹងពាក់គ្នាទៅវិញទៅមកដោយបន្តតាមរយៈជីដូនជីតារបស់ពួកគាត់មកម្ល៉េះ។ ប្រជាជនរស់នៅតាមស្រុកស្រែចម្ការរាប់អានគ្នាស្មោះស្ម័គ្រណាស់ មានគ្រួសារខ្លះអាចភ្ជាប់សាច់ឈាមគ្នាក៏មានដែរ ដោយសារតែពួកគាត់គិតថាមិនចង់ឲ្យកូនចៅទៅឆ្ងាយពីខ្លួន។ ដូច្នេះហើយទំនាក់ទំនងធ្វើឲ្យមានការរៀបចំទុកដាក់ពីចាស់ទុំនៅក្នុងគ្រួសារ។

ចំពោះទំនាក់ទំនងរវាងអ្នកត្បាញ និងអ្នកត្បាញវិញធ្វើឲ្យពួកគេអាចពឹងគ្នាទៅវិញទៅមកតាមរយៈការជួយគ្នាពេលដល់រដូវធ្វើស្រែ ដោយមានការប្រវាស់ដៃគ្នា និងមកដល់សម័យនេះស្ត្រីពុំសូវទៅស្រែដូចកាលពីមុនឡើយ។ ដូច្នេះហើយការត្បាញភាគច្រើនជាស្ត្រីគាត់ជាអ្នកធ្វើហើយពេលតម្លើងកីត្បាញម្តងៗគាត់មិនអាចធ្វើតែឯងបានទេ ដូច្នេះហើយគាត់បានទៅពឹងអ្នកជិតខាងដែលរស់នៅក្នុងភូមិ ឬទៅពឹងអ្នកដែលគាត់រស់នៅភូមិផ្សេងក៏មានដែរ។ ការពឹងពាក់គ្នាពួកគេមិនដែលគិតថាចង់បានប្រាក់ពីអ្នកដែលគាត់មកពឹងនោះទេ។ ព្រោះគាត់គិតថាការជួយគ្នាគឺវាម្តងម្នាក់ទេមិនប្រកាន់ថាឲ្យតែបានលុយទើបគាត់ទៅជួយនោះទេ។ ចំពោះអ្នកដែលទើបនឹងតម្លើងកីត្បាញដំបូងនៅខ្វះខាតឧបករណ៍ដូច្នេះហើយអ្នកដែលមានបទពិសោធន៍ជាច្រើនឆ្នាំអាចដឹងថាខ្វះអ្វី ហើយគាត់ក៏ឲ្យខ្ចីឧបករណ៍ទាំងនោះបាន។

ការងារត្បាញនេះត្រូវតែប្រព្រឹត្តទៅរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងសង្គមមួយទៅសង្គមមួយផ្សេងទៀត។ ការទាក់ទងគ្នាអាចលេចចេញជារូបរាងផ្សេងៗទៅតាមសង្គមដែលពួកគេកំពុងតែរស់នៅ។ ទំនាក់ទំនងកើតឡើងរវាងអ្នកលក់ជាមួយអ្នកទិញដែលអាចពិភាក្សាគ្នារវាងទំនិញរបស់ពួកគេដែលត្បាញ និងតម្លៃអ្នកដែលមកទិញ។ ចំពោះសកម្មភាពរបស់អង្គការវិញអត់មានការចុះមកបណ្តុះបណ្តាលនៅក្នុងភូមិនេះទេ។ ប៉ុន្តែមានអង្គការសូត្រពណ៌បានមកទិញហូលរបស់អ្នកភូមិនេះដែរ។ អង្គការនេះមិនបានទិញសូត្រ ឬល័ក្ខឲ្យទៅអ្នកតម្បាញហូល

ដែលរស់នៅក្នុងភូមិនោះទេ ដោយសារតែគ្មានការសហការជាមួយអង្គការសម្រាប់ធ្វើការបង្កើតជាសិប្បកម្មខ្នាតតូចសម្រាប់ការងារតម្បាញក្នុងភូមិរបស់ខ្លួនដើម្បីជួយឲ្យងាយស្រួលក្នុងការស្វែងរកឈ្មួញកណ្តាលជួយទិញហូលដែលបានត្បាញលក់ក្នុងតម្លៃសមរម្យទៅនឹងការចំណាយពេលវេលា និងកម្លាំងដែលខិតខំបង្កើតគំនិតថ្មីៗទាក់ទងទៅនឹងប្រភេទគោមហូល។

ជាពិសេសក៏គ្មានស្ថាប័នដែលពាក់ព័ន្ធទៅនឹងគម្រោងនេះមកបើកវគ្គបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋដែលមានមុខរបរនេះទេ អ្នកណាធ្វើក៏ធ្វើទៅមិនខ្វល់ហើយពួកគេមិនមាន ការស្មោះត្រង់ទេចំពោះការបង្កើតគោមថ្មីសម្រាប់ត្បាញទុកឲ្យឈ្មួញ។ ការច្នៃប្រឌិតនេះគឺពួកគាត់ជាអ្នកច្នៃដោយខ្លួនឯង ឬក៏ឈ្មួញកណ្តាលពួកគេបញ្ជាទិញក៏មានដែរ។ ទាំងអស់នេះហើយធ្វើឲ្យមានការប្រកួតប្រជែងគ្នាក្នុងការបង្កើតគំនិតថ្មីដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់។ ហើយអាចជួយថែរក្សាមរតកវប្បធម៌របស់ខ្មែរឲ្យនៅគង់វង្សយូរអង្វែងតទៅមុខសម្រាប់ឲ្យក្មេងជំនាន់ក្រោយស្គាល់ពីបច្ចេកទេសត្បាញហូល និងនៅសល់ឧបករណ៍ទុកបង្ហាញឲ្យដឹងពីតម្លៃនៃវប្បធម៌របស់ខ្មែរយើង។



រូបភាពការចងគាត និងការរវៃសូត្រ (Images D'Asie Cambodge)



ការស្ងោរសំបុកដង្កូវនាងដើម្បីយកសរសៃសូត្រ (Images D'Asie Cambodge)

Images d'Asie / Cambodge



**Peigne et cadres d'armure d'un métier à tisser**

Loom comb and weave frames

សកម្មភាពតម្បាញរបស់ស្ត្រីខ្មែរ

## ឃ. ការផ្ទេរចំនេះដឹងតម្បាញដល់ក្មេងជំនាន់ក្រោយ

### ១. ផ្នត់គំនិតអ្នកតម្បាញពេលបច្ចុប្បន្ន

ប្រជាជនក្នុងភូមិជាទូទៅបានរក្សាការគោរពបូជាព្រះពុទ្ធសាសនា និងភ្ជាប់នូវប្រពៃណីទំនៀមទំលាប់ខ្មែរ។ ប្រជាពលរដ្ឋបានប្រកបរបរកសិកម្ម និងសិប្បកម្មដែលមានដូចជា តម្បាញហូល ក្រមា និងលក់ដូរបន្តិចបន្តួចសម្រាប់ជីវភាពប្រចាំថ្ងៃរបស់គាត់។ ដោយនៅទីនោះមានប្រជាជនត្បាញហូលច្រើន ដែលបានបន្តពីឪពុកម្តាយរបស់ពួកគាត់ទើបធ្វើឲ្យអ្នកតម្បាញពឹងផ្អែកទាំងស្រុងទៅលើការត្បាញហូល ឬក្រមា។ ប្រជាជនដែលជាអ្នកប្រកបរបរត្បាញហូលនៅក្នុងភូមិកញ្ចាងគាត់មានប្រសាសន៍ថា ការត្បាញនៅពេលបច្ចុប្បន្នវាមិនដូចកាលពីត្បាញហូលកាលពីមុនទេ ព្រោះវាមានភាពងាយស្រួលជាងកាលពីជំនាន់មុនៗ។ ដោយសារតែសម័យមុនមានការពេញនិយមទើបធ្វើឲ្យអ្នកតម្បាញមានភាពមមាញឹកប៉ុន្តែត្រូវប្រើរយៈពេលយូរទម្រាំតែបានសំពត់មួយក្បិន។ នៅក្នុងភូមិនេះប្រុសៗក៏ចេះត្បាញដូចស្ត្រីដែរ ពួកគាត់មិនប្រកាន់ថាជាការងាររបស់ស្ត្រីទេ ឲ្យតែពួកគាត់ចង់ធ្វើវា ឬបញ្ចប់ពីការងារធ្វើស្រែ និងកិច្ចការផ្សេងៗដែលជាការងារធ្ងន់។

ប៉ុន្តែមកដល់ពេលបច្ចុប្បន្ន អ្នកត្បាញមានភាពងាយស្រួលដោយមានបច្ចេកទេសជឿនលឿនខាងបច្ចេកវិទ្យាគ្រប់ផ្នែក។ សព្វថ្ងៃមានការខុសប្លែកគ្នាពីមុនឆ្ងាយណាស់ធ្វើឲ្យនៅក្នុងភូមិមានភាពស្ងប់ស្ងាត់មិនសូវជាមានឮសម្លេងគោះកីតម្បាញដែលប្រជាពលរដ្ឋចូលត្បាញដូចកាលពីមុនទេ។

ម្យ៉ាងទៀតអ្នកដែលចេះត្បាញមានអាយុកាន់តែច្រើន ហើយម្យ៉ាងគាត់បានបាត់បង់ជីវិតមិនមានកូនចៅណាចង់បន្តរបរនេះទេ ធ្វើឲ្យកីតម្បាញទុកចោលហាលថ្ងៃត្រូវភ្លៀងពុកផុយមិនអាចប្រើប្រាស់បានទៀត។ បើមានអ្នកត្បាញវិញ គឺមានគិតចាប់ពីអាយុ៣៥ឆ្នាំទៅ៦៥ឆ្នាំដែលគាត់នៅបន្តត្បាញ។ ប៉ុន្តែមានតិចគ្រួសារណាស់ដែលនៅត្បាញ ដោយមូលហេតុគាត់គិតថាការតម្បាញឥឡូវវាមានភាពងាយស្រួលមែន ដោយមិនចាំបាច់ទៅចិញ្ចឹមដង្កូវនាង ទៅស្មោះសំបកឈើ បេះស្លឹកឈើ យកមកបុក ចិញ្ច្រាំវាជាដើម ដើម្បីបង្កើតបានជាល័ក្តធម្មជាតិសម្រាប់ជ្រលក់សូត្រដែលស្រាវយកសូត្រចេញពីដង្កូវនាង។ តម្បាញឥឡូវមានភាពខុសគ្នាត្រង់ថាមិនចាំបាច់ចិញ្ចឹមដង្កូវនាងក៏មានសូត្រសម្រាប់ត្បាញដែរ។ ចំណែកល័ក្ខវិញក៏ដូចគ្នាជាមួយសូត្រដែលគឺ

គ្រាន់តែទៅផ្សារដែលនៅជិតភូមិរបស់គាត់ក៏បានសូត្រ ឬល័ក្ខយកមកត្បាញភ្វាម ឬម្យ៉ាងទៀត គាត់គ្រាន់តែប្រាប់ម៉ូយរបស់គាត់ ដែលចាំទទួលយកហូលពីគាត់ឲ្យដាក់សូត្រ ឬល័ក្ខមកឲ្យគាត់ក៏បានដែរ។ ប្រជាជនដែលជាអ្នកតម្បាញអាចជំពាក់ម៉ូយគាត់ក៏បានដែរ។ គ្រាន់តែយើងត្បាញរួចប្រជាជនបានកាត់ហូលដែលគាត់ត្បាញហើយយកទៅឲ្យម៉ូយដើម្បីកាត់ថ្លៃទិញសូត្រ ឬល័ក្ខនោះ។ ទោះបីអ្នកដែលអត់មានដើមទុនសម្រាប់ទិញសម្ភារៈត្បាញក៏គាត់អាចជំពាក់ពីម៉ូយរបស់គាត់បានដែរ។ ការធ្វើបែបនេះវាមានភាពងាយស្រួលដល់អ្នកត្បាញ ប៉ុន្តែកម្រៃដែលទទួលបានវាមានចំនួនតិច និងថោក។ ប្រសិនបើគាត់យកផលិតផលទាំងនោះទៅលក់ដោយខ្លួនឯងនោះគឺទាល់តែខិតខំត្បាញឲ្យបានច្រើនទើបចេញទៅលក់ម្តង។

តែការទៅលក់ដោយខ្លួនបែបនេះធ្វើឲ្យចំណាយពេលច្រើនសម្រាប់ការចេញទៅលក់ម្តងៗហើយជួនកាលលក់ពុំសូវដាច់ផង ព្រោះគាត់ពុំមានឈ្មួញចាំទទួលយក។ ការធ្វើបែបនេះសម្រាប់តែអ្នកដែលមានដើមទុនច្រើនសម្រាប់ប្រមូលឲ្យបានច្រើនចេញទៅលក់ម្តងធ្វើបែបនេះអ្នកតម្បាញអាចទទួលផលកម្រៃខ្ពស់ដែលចំណេញពីការលក់ហូលដោយខ្លួនឯងមិនចាំបាច់ទុកឲ្យម៉ូយ។ ប៉ុន្តែនៅតាមស្រុកស្រែចម្ការមិនបានធ្វើបែបនេះទេដោយសារគាត់ខ្វះដើមទុន ឲ្យតែដល់ក្បិនគាត់ប្រញាប់កាត់យកទៅម៉ូយដើម្បីទទួលប្រាក់មកផ្គត់ផ្គង់គ្រួសារ និងទិញសម្ភារៈមកត្បាញវិញ។

ទាំងនេះហើយទើបធ្វើឲ្យអ្នកធ្លាប់ត្បាញពីមុន ត្រូវបានបោះបង់ចោលមួយភាគធំដោយមិនសូវចំណេញ និងមិនសូវមានឈ្មួញមកបញ្ជាទិញប៉ុន្តែបើមាន គឺលក់បានថោក។ ដូច្នេះបានធ្វើឲ្យហូលមានតម្លៃធ្លាក់ចុះ អ្នកតម្បាញក៏បែរទៅរករបរផ្សេងក្រៅពីរបរនេះដែលធ្លាប់តែមានតម្លៃ និងមានឈ្មួញជាច្រើនបានបញ្ជាឲ្យពួកគាត់ត្បាញ។ មកដល់ឥឡូវក្មេងៗជំនាន់ក្រោយរឹតតែមិនចង់ធ្វើវាថែមទៀត ដោយសារមកដល់ឥឡូវសម្បូរការងារធ្វើជាងពេលមុន មានការបង្កើតរោងចក្រនៅតាមបណ្តាខេត្ត មិនចាំបាច់មកក្រុង។ ក្មេងៗក៏មានការយល់ដឹងច្រើនពួកគេចង់បន្តការសិក្សា ឬទៅធ្វើការនៅក្រៅប្រទេសដោយទទួលបានប្រាក់កម្រៃខ្ពស់ជាងនៅក្នុងស្រុក។

## ២. គំនិតក្មេងជំនាន់ក្រោយលើការតម្បាញ

នាពេលបច្ចុប្បន្ននេះតម្បាញហូលនៅក្នុងភូមិកញ្ចាងមានការប្រែប្រួលជាខ្លាំងមិនដូចកាលពីឆ្នាំ២០០៥ទេ។ មនុស្សចាស់ដែលមានជំនាញតាំងពីសង្គមចាស់ក៏បានបាត់បង់ជីវិតមួយចំនួនធំ។ ការតម្បាញហូលនៅភូមិនេះ គឺជាការតម្បាញតាមបែបពាក់កណ្ដាលសម័យ ប៉ុន្តែឧបករណ៍មានលក្ខណៈជាប្រពៃណីនៅដដែល។ ពីមួយជំនាន់ទៅមួយជំនាន់វិជ្ជាតម្បាញហូលនេះត្រូវបានបន្តពីម្ដាយទៅកូនស្រីប៉ុន្តែឥឡូវមានការធ្លាក់ចុះមិនដូចកាលពីមុនឡើយ ដោយសារតែមានភាពជឿនលឿនខាងបច្ចេកវិទ្យា។ ជារៀងរាល់ថ្ងៃសកម្មភាពទាំងឡាយដែលនៅក្នុងសហគមន៍ជាពិសេសការងារតម្បាញហូលដែលជាមុខរបរមួយ និងជាកន្លែងមួយយ៉ាងមានអំណោយផលសម្រាប់កុមារ។ នៅក្នុងភូមិកញ្ចាងជាពិសេសក្មេងស្រីៗបានទទួលយកចំណេះវិជ្ជាដោយមិនដឹងខ្លួននូវទេពកោសល្យក្នុងការងារតម្បាញ។

ទោះបីជាពួកគេបានចូលរួមធ្វើការងារខ្លះដូចជាៈ ចងគាត ចូលត្បាញ ជាដើម ឬក៏មិនបានចូលរួមធ្វើការងារតូចតាចខាងតម្បាញក៏ដោយ។ ប៉ុន្តែមានន័យថាមជ្ឈដ្ឋាននៅជុំវិញផ្ទះនិងក្នុងភូមិដែលពួកគេរស់នៅ វាប្រៀបបានទៅនឹងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ពួកគេតាំងពីតូចៗមកម្ល៉េះ។ លុះដល់ពួកគេមានអាយុប្រហែលជា១២ឆ្នាំ ម្ដាយ ឬជីដូនបានបង្ហាត់បង្រៀនបន្ថែមដល់កូនចៅស្រីឲ្យចេះត្បាញ ចេះរៀបចំចាត់ចែងក្នុងការងារតម្បាញ។ មកដល់ពេលពួកគេមានអាយុ១៤ទៅ១៥ឆ្នាំពួកគេចាប់ផ្ដើមជួយត្បាញបានរួចជាស្រេចទៅហើយ។ ដោយសារតែពួកគេឆាប់ចាប់បានព្រោះពួកគេមានទេពកោសល្យ និងបានឃើញសកម្មភាពបែបនេះជារៀងរាល់ថ្ងៃ។

ដូច្នេះពួកគេអាចធ្វើបាននៅជំនាញបែបនេះ សម្រាប់ជាមុខរបរមួយទៅថ្ងៃក្រោយ។ ពួកគេបានកើតមកក្នុងភូមិដែលមានការត្បាញ និងផលិតផលដែលធ្វើដោយដៃ ដែលបន្សល់ទុកឲ្យពួកគេបន្តទៅថ្ងៃក្រោយសម្រាប់ប្រកបរបរចិញ្ចឹមជីវិត។ ក្មេងៗមានជំនាញស្រាប់ក្នុងការរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារបានដោយមិនចាំបាច់ចំណាយពេលវេលា និងប្រាក់កាក់ក្នុងការរៀនដើម្បីចាប់យកជំនាញវិជ្ជាជីវៈ សម្រាប់ចិញ្ចឹមជីវិតណាមួយឡើយ។ នៅក្នុងភូមិក្មេងប្រុសនិងក្មេងស្រីអាចមានលទ្ធភាពស្វែងរកប្រាក់បានមិនចាំបាច់នៅក្នុងភូមិនៅត្បាញហូលនោះទេ។ ប៉ុន្តែមានក្មេងៗមួយចំនួនពួកគេអាចស្វែងរកប្រាក់បានដោយសារការចងគាត ត្បាញហូលនៅ

ពេលពួកគេទំនេរពីការសិក្សារបស់ពួកគេ។ ពួកគេមានភារកិច្ចយ៉ាងសំខាន់នៅក្នុងការជួយថែរក្សាមរតកវប្បធម៌ខាងសិប្បកម្មសូត្រខ្មែរ។ មានជម្រើសច្រើនក្នុងការប្រកបរបរអាជីវកម្មក៏ដូចជារបៀបរស់នៅរបស់ពួកគេនៅថ្ងៃអនាគត។ មនុស្សចាស់ និងក្មេងៗដែលគាត់បានជួយថែរក្សាមរតកវប្បធម៌ ដោយសារការងារនេះអាចឲ្យគាត់រកប្រាក់ចំណូលបានរហូតមក។

ទាំងអស់នេះវាជាគុណសម្បត្តិមួយសំខាន់ដែលរស់នៅក្នុងផ្ទះដែលមានអ្នកចេះត្បាញនិងមានមនុស្សចាស់ៗចាំជួយបង្រៀនដែលពួកគាត់មានបទពិសោធន៍យូរឆ្នាំក្នុងការត្បាញហូលនិងមានជំនាញបន្តតាំងពីជំនាន់ជីដូនជីតារបស់គាត់ ក្នុងការចូលរួមចំណែកជួយថែរក្សាមរតកវប្បធម៌ខ្មែរ វិស័យតម្បាញហូលខ្មែរ ជួយដល់តម្លៃវប្បធម៌ដែលបន្សល់ទុកមកដល់សព្វថ្ងៃ។ អ្នកភូមិបានផ្ទេរចំណេះដឹងខាងតម្បាញដែលគាត់ចេះទៅឲ្យមនុស្សជំនាន់ក្រោយ តាមរយៈការងារតម្បាញជាលក្ខណៈគ្រួសារដែលមាននៅតាមភូមិបែបនេះគឺជាការងារមួយតំរូវឲ្យគាត់ធ្វើនៅផ្ទះហើយធ្វើនៅពេលដែលគាត់ទំនេរពីការងារផ្ទះសម្បែង។ ដូចនេះវាជាគុណសម្បត្តិដែលរស់នៅក្នុងផ្ទះ។ ជាងនេះទៅទៀតអ្នកភូមិកញ្ចាងបានចូលរួមចំណែកមួយក្នុងការថែរក្សានូវលក្ខណៈនៃការរស់នៅរបស់ពួកគាត់ដែលមាននៅក្នុងភូមិ តាមរបៀបរស់នៅជាអ្នកតម្បាញហូលតាំងពីបុរាណកាលមកម្ល៉េះមិនឲ្យផុតរលត់ឡើយ។ ពួកគាត់គឺជាគ្រូបង្រៀនយ៉ាងមានជំនាញនិងមានបទពិសោធន៍ដែលបានផ្ទេរទៅឲ្យមនុស្សជំនាន់ក្រោយជាបន្តបន្ទាប់ទៀតសម្រាប់បន្តការងារតម្បាញពីរូបគាត់។

អ្នកនៅត្បាញមានតែមនុស្សចាស់ ដែលគាត់ទៅណាមិនរួចហើយជាប់កូនតូចៗ។ គាត់និយាយថានៅត្បាញបាននៅចាំផ្ទះ និងបាននៅមើលថែរក្សាទ្រព្យសម្បត្តិនៅផ្ទះរបស់គាត់។ ពីមុនក្មេងស្រីៗ ម្ដាយឪពុកមិនសូវឲ្យចេញពីផ្ទះទេដោយសារតែខ្លាចនៅឆ្ងាយពីផ្ទះត្រូវចាញ់បោកគេ។ ប៉ុន្តែមកដល់សម័យនេះវាខុសពីមុនដោយសារតែម្ដាយឪពុកអាចផ្ដល់ឱកាសដល់កូនស្រីចេញពីផ្ទះទៅរកការងារធ្វើដោយខ្លួនគេពេញចិត្ត និងធ្វើដូចជាមនុស្សប្រុសដទៃទៀតគេបានធ្វើហើយមកដល់ឥឡូវនៅទីក្រុងក៏មានការងារច្រើន និងទទួលបានប្រាក់ខែក៏គួរសមរម្យ។ ពីមុនមានកីតម្បាញជាច្រើន ប៉ុន្តែមកដល់ពេលនេះឃើញមានកីតម្បាញនៅខាងក្រោម និងខាងលើផ្ទះនៅមានចំនួនតិចតួច។ កីដែលពួកគាត់បានទុកចោល និងកីខូចខាតមួយចំនួនដោយសារតែគ្មានមនុស្សប្រើប្រាស់វាធ្វើឲ្យពុកផុយ។ គ្រួសារខ្លះទៀតយកកីដែលទុកចោលនោះទៅធ្វើជាមេ

គ្រែក៏មានដែរ។ ទាំងអស់នេះហើយទើបបានជាធ្វើឲ្យក្មេងៗជំនាន់ក្រោយនៅក្នុងភូមិពួកគេមិនបានស្គាល់នូវឧបករណ៍តម្បាញបែបបុរាណដែលមានលក្ខណៈជាប្រពៃណី។ អ្វីដែលមានការច្នៃប្រឌិតខ្ពស់នៃក្បាច់របស់ឧបករណ៍ដូនតាខ្មែរយើងសូម្បីតែឈើដែលនិយមធ្វើក៏មានតម្លៃថ្លៃ។ ប៉ុន្តែឧបករណ៍តម្បាញឥឡូវមិនមានក្បាច់អ្វីគួរឲ្យចាប់អារម្មណ៍ទេពោលគឺធ្វើឲ្យតែបានសម្រាប់ប្រើ។ មកដល់សម័យទំនើបទៀតក្មេងៗមិនបានយកចិត្តទុកដាក់នូវរបស់របរចាស់ៗដែលបន្តពីជីដូនជីតាបានបន្សល់ទុកឲ្យសម្រាប់ជាមរតកទៅថ្ងៃក្រោយនោះទេ។

ចំណុចខុសគ្នាម្យ៉ាងទៀតគឺ ចំពោះក្មេងប្រុស និងក្មេងស្រីដែលរស់នៅក្នុងភូមិ ដែលមិនមែនអ្នកប្រកបរបរតម្បាញហូលពួកគេក៏មិនសូវដឹងអំពីតម្លៃនៃមរតកវប្បធម៌ ដែលផ្ទេរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយមិនចាំបាច់ចូលសាលារៀនដូចជំនាញផ្សេងៗទៀត។ ប៉ុន្តែគួរឲ្យសោកស្ដាយយ៉ាងខ្លាំងនូវរបរបែបប្រពៃណីមួយនេះដែលមិនបានធ្វើឲ្យក្មេងៗជំនាន់ក្រោយមិនចាប់អារម្មណ៍ទៅលើរបរនេះ។ ពួកគេបាននិយាយថាប្រសិនបើរៀនចប់ថ្នាក់ទី១២ ឬមិនបានរៀនបន្តពួកគេនឹងស្វែងរកការងារផ្សេងក្រៅពីការងារតម្បាញហូល។ ដោយតែការម្បាញឥឡូវមានភាពងាយស្រួលមែនចំពោះមនុស្សចាស់ តែវាមានភាពស្មុគស្មាញចំពោះក្មេងឥឡូវ និងមិនសូវចំណេញ និងគ្មានអ្នកត្បាញច្រើនដូចកាលពីមុន ទើបឈ្នួញកណ្ដាលនៅមានតិចធ្វើឲ្យហូលមានការធ្លាក់ថ្លៃ។ ដូច្នេះហើយទើបទទួលបានកម្រៃតិចជាងផលិតផលសម្រេច។ បើពួកគេជួយគឺធ្វើបានតែបន្តិចបន្តួចតែប៉ុណ្ណោះខណៈពេលដែលពួកគេចេញពីរៀន ឬទំនេរពីធ្វើស្រែចម្ការតែមិនបានជាប់លាប់ទេ។

ប្រជាជនដែលរស់នៅក្នុងភូមិកញ្ចាង មានចំនួនស្រីច្រើនជាងប្រុស។ ដូច្នេះទើបមានការប្រកបរបរតម្បាញហូលនៅក្នុងភូមិនេះជារបរទីពីរបន្ទាប់ពីការធ្វើស្រែ។ ដោយសារតែស្រីមានភាពទន់ខ្សោយមិនអាចប្រើកម្លាំងដូចមនុស្សប្រុសបាន ដូច្នេះហើយទើបឪពុកម្ដាយបានធ្វើកីតម្បាញសម្រាប់ចែកឲ្យកូនរបស់ពួកគាត់ ពេលដែលកូនរបស់គាត់ម្នាក់ៗមានគ្រួសារឪពុកម្ដាយបានចែកកីតម្បាញឲ្យកូនគ្រប់ៗគ្នា។ ទាំងអស់នេះហើយទើបមានកីតម្បាញហូល ឬតម្បាញក្រមានៅខាងក្រោមផ្ទះរៀងៗខ្លួន ប្រសិនបើគ្រួសារណាមានសមាជិកច្រើន ចំនួនកីក៏ច្រើនទៅតាមសមាជិកនៅក្នុងផ្ទះដែរ។ រហូតមកដល់ពេលនេះនៅក្នុងភូមិកញ្ចាងមានការប្រែប្រួលដោយសារតែមានការបាត់បង់នូវអ្នកដែលមានបទពិសោធន៍យូរឆ្នាំ ចំពោះក្មេងៗជំនាន់ក្រោយពួកគេ

មិនសូវជាចាប់អារម្មណ៍លើការតម្បាញហូល ឬក្រមាទេ។ ដោយសារមានកត្តាជាច្រើនជំរុញឲ្យពួកគេមិនមានចំណាប់អារម្មណ៍លើការត្បាញដូចកាលពីជំនាន់ម្ដាយឪពុករបស់ពួកគេឡើយ។

ផ្ទុយទៅវិញពួកគេមានទំនោរទៅលើខាងបច្ចេកវិទ្យាទំនើប អ្នកខ្លះចង់បន្តការសិក្សារនៅសាកលវិទ្យាល័យនៅឯភ្នំពេញ ចំណែកអ្នកខ្លះទៀតក៏មានទំនោរទៅខាងរោងចក្រកាត់ដេរ និងទៅធ្វើការនៅកន្លែងកម្សាន្ត ដូចជាភោជនីយដ្ឋាន ក្លឹបរាត្រី និងកន្លែងលក់សម្លៀកបំពាក់នៅតាមហាងផ្សេងៗ។ ប្រជាជនមួយចំនួនធំបានធ្វើចំណាកស្រុកទៅប្រទេសថៃ និងទៅប្រទេសកូរ៉េ។ ដោយសារតែនៅទីនោះពួកគេទទួលបានប្រាក់ខែខ្ពស់ជាងនៅក្នុងប្រទេស។ ចំពោះអ្នកធ្វើការនៅរោងចក្រងាយស្រួលជាងមុន ដោយសារតែមានឡានចាំទទួលទាំងទៅទាំងមក មិនចាំបាច់មកទីក្រុង និងមិនបាច់ចំណាយលុយទៅលើការជួលផ្ទះ។ ដោយមានការធ្លាក់ចុះនៃការតម្បាញហូលទើបពួកគេមានការចង់ផ្លាស់ប្ដូរពីរបរនេះទៅធ្វើការ និងរស់នៅកន្លែងផ្សេង និងចង់ស្គាល់អ្វីផ្សេងដែលខុសពីសហគមន៍ដែលពួកគេរស់នៅ។

មកដល់សម័យឥឡូវយុវវ័យចង់រៀន ឬធ្វើអ្វីដែលខ្លួនគេចង់ធ្វើ ខុសពីសម័យមុនដែលឲ្យកូននៅតែផ្ទះ ជាពិសេសកូនស្រីមិនឲ្យទៅធ្វើនៅឆ្ងាយទេ។ ដោយគាត់ខ្លាចពីសុវត្ថិភាពកូនរបស់គាត់ ហើយមានគ្រួសារខ្លះទៀតមិនឲ្យចេញពីគ្រួសារ ទោះបីជាមានគ្រួសារថ្មីក៏ដោយទើបមានការធ្វើកីតម្បាញឲ្យទៅកូន។ ប៉ុន្ដែមកដល់ឥឡូវការតម្បាញហូលក៏មិនសូវចំណេញដោយសារតែពេលត្បាញរួចហើយយកទៅលក់ទទួលបានតម្លៃថោក ចំណែកឯការទិញផលិតផលសូត្រវាមានតម្លៃថ្លៃ ម្ល៉ោះហើយទើបមានការបោះបង់ចោលមួយចំនួនធំដោយសារមានបញ្ហាដូចខាងលើនេះឯង។ ក្មេងៗក៏មិនសូវជាចូលចិត្តត្បាញទេដោយសារតែវាមានច្រើនដំណាក់កាលពិបាកដោយប្រើរយៈពេលយូរទម្រាំតែបានមួយក្បិនៗយកមកលក់ ហើយទិញសម្ភារមកត្បាញវិញក៏ចំណេញបានបន្ដិចបន្តួច។ ដូច្នេះហើយទើបពួកគេមិនសូវជាចូលចិត្តត្បាញពីព្រោះវាមិនសូវចំណេញ។



រូបភាពហូលក្បាច់ផ្កាចាន់



*ហូលលំអដោយក្បាច់ផ្កាចាន់តូចនិងធំ*



រូបភាពហូលស្រកានាគ



រូបភាពហូលផ្កាចាន់បែបបូរាណ



រូបភាពក្រមាធ្វើអំពីសរសៃសូត្រ





រូបភាពហូលគោមផ្កាយព្រឹកមានជរជើង



រូបភាពហូលពិតាន



រូបភាពក្រមាសូត្រគ្រប់ពណ៌



ផលិតផលសូត្របែបសម័យ






រូបភាពពិព័រណ៍ផលិតផលសូត្រ



រូបភាពពិព័រណ៍ផលិតផលសូត្រ



ការតុបតែងលម្អលើសូត្រ



ការតុបតែងលំអលើសូត្រ



រូបភាពក្រឡាហូលគ្រប់ប្រភេទ



រូបភាពផលិតផលសូត្រ



រូបភាពផលិតផលសូត្រ





រូបភាពផលិតផលសូត្រ ហូលផាមួង



រូបភាពផលិតផលសូត្រគ្រប់ប្រភេទ






រូបភាពការដាក់តាំងបង្ហាញផលិតផលសូត្រតាមហាងនានា




ក្រដាសប្រាក់១០០រៀលសម័យសាធារណៈរដ្ឋខ្មែរបានផ្សព្វផ្សាយដល់ស្រទាប់មហាជន ស្តីអំពីសិល្បៈតម្បាញសូត្រ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត**
ការិយាល័យសិល្បៈសូនរូប និងសិប្បកម្ម

## តារាងស្ថិតិសិប្បកម្មតម្បាញសូត្រ

| ល.រ | ឈ្មោះក្រុង/ស្រុក | ទីតាំង | | សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| | | ភូមិ | ឃុំ/សង្កាត់ | | |
| ១ | ក្រុងកំពត | ១ឧសភា | កំពង់កណ្ដាល | ០១ កន្លែង | |
| ២ | ស្រុកជុំគីរី | ខ្លី | ជុំពូវ័ន្ត | ០១ កន្លែង | |
| **សរុបរួម:** | | | | ០២ កន្លែង | |

កំពត ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៧
**ប្រធានការិយាល័យ**

**ខៀវ ប៉ាមុន្នី**

*តារាងស្ថិតិសិប្បកម្មតម្បាញសូត្រខេត្តកំពត*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
**ខេត្ត បន្ទាយមានជ័យ**
ការិ. សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

**តារាងស្ថិតិសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ឆ្នាំ២០១៧**

| លរ | រាយមុខជំនាញ | ឯកតា | ឆ្នាំ២០១៧ | សហគមន៍ | ក្រុម | លក្ខណៈគ្រួសារ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | ជាងចម្លាក់ ថ្ម | កន្លែង | ២៨ | | | លក្ខណៈគ្រួសារ | |
| ២ | ជងចម្លាក់ ឈើ | កន្លែង | ១១ | | | លក្ខណៈគ្រួសារ | |
| ៣ | ជាងចម្លាក់ ស្បែក | កន្លែង | ០១ | អង្គការគ្រួសារថ្មី | ០១ | គ្រួសារថ្មី | |
| ៤ | សូនរូបចាក់ពុម្ពស៊ីម៉ងត៍ | កន្លែង | ៤៥ | | | លក្ខណៈគ្រួសារ | |
| ៥ | ជាងពុម្ព ម្ភាំងសិលា | កន្លែង | ១០ | | | លក្ខណៈគ្រួសារ | |
| ៦ | ផ្ទះលក់វត្ថុសិល្បៈ | កន្លែង | ០៦ | | | លក្ខណៈគ្រួសារ | |
| ៧ | ផ្ទះលក់វត្ថុអនុស្សាវរីយ៍ | កន្លែង | ០៧ | | | លក្ខណៈគ្រួសារ | |
| ៨ | ជាងគំនូរសម័យ | កន្លែង | ០៨ | | | លក្ខណៈគ្រួសារ | |
| ៩ | ជាងគំនូរបុរាណ | កន្លែង | ០៤ | | | លក្ខណៈគ្រួសារ | |
| ១០ | តម្បាញក្រមាសារុងសូត្របុរាណ | កន្លែង | ២៥ | | | លក្ខណៈគ្រួសារ | |
| ១១ | តម្បាញក្រមាសូត្រ ពាក់កណ្តាលសៀវប្រាថ្មី | កន្លែង | ១៥ | | | លក្ខណៈគ្រួសារ | |
| ១២ | តម្បាញ អំពោះ | កន្លែង | ៨៤ | | | លក្ខណៈគ្រួសារ | |
| ១៣ | តម្បាញ កន្ទេលកក់ | កន្លែង | ៥៤ | | | លក្ខណៈគ្រួសារ | |
| ១៤ | តម្បាញ ឬស្សី | កន្លែង | ៣៨៨ | | | លក្ខណៈគ្រួសារ | |
| ១៥ | តម្បាញ រពាក់ | កន្លែង | ០១ | | | លក្ខណៈគ្រួសារ | |
| ១៦ | តម្បាញ ផ្តៅ | កន្លែង | ០ | | | លក្ខណៈគ្រួសារ | |
| ១៧ | ដេរម្ជុក ក្រណាត់ | កន្លែង | ០៤ | | | លក្ខណៈគ្រួសារ | |
| ១៨ | ដេរម្ជុក ស្លឹកត្នោត | កន្លែង | ៣៧ | | | លក្ខណៈគ្រួសារ | |
| ១៩ | ជាងទង | កន្លែង | ៦៦ | | | លក្ខណៈគ្រួសារ | |
| ២០ | សិប្បកម្មគ្រឿងសង្ហារឹម | កន្លែង | ២២ | | | លក្ខណៈគ្រួសារ | |
| **សរុប** | | | ៨៥៦ ក | | | លក្ខណៈគ្រួសារ | |

បន្ទាយមានជ័យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧
**ការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម**

**គីម សុភាព**

បានឃើញ និងឯកភាព
បន្ទាយមានជ័យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧
**ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត**

**យស់ តាំងកួយ**

*តារាងស្ថិតិសិប្បកម្មតម្បាញសូត្រខេត្តបន្ទាយមានជ័យ*

+តម្បាញសូត្រស្រុកភ្នំស្រុក បន្ទាយមានជ័យ

-លក្ខណៈសហគមន៍មាន ១កន្លែង

-លក្ខណៈគ្រួសារមាន ២៥កន្លែង

-លក្ខណៈស្វាយប្រវត្តិ ១៤កន្លែង

+ការដាំម៉ន់មានការថយចុះ

-អ្នកដាំម៉ន់និងអ្នកចិញ្ចឹមកូននាងមាន ៣គ្រួសារ

-មូលហេតុនៃការថយចុះអ្នកតម្បាញនាំសរសៃសូត្រពីប្រទេសថៃ

-ការដាំម៉ន់មិនល្អធ្វើឲ្យរួញស្វិតបាញ់ថ្នាំគីមីប៉ះពាល់។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
ខេត្ត បន្ទាយមានជ័យ
ការិ.សិល្បៈសូនរូបនិងសិល្បៈសិប្បកម្ម

**តារាងស្ថិតិ សិល្បៈសូនរូប និង សិប្បកម្ម ក្រុង / ស្រុក ឆ្នាំ២០១៧**

| ល.រ | ឈ្មោះ ក្រុង / ស្រុក | ចម្លាក់ ថ្ម | ចម្លាក់ ឈើ | ចម្លាក់ ស្បែក | ជាងពុម្ព ស៊ីម៉ង់ត៍ | ជាងពុម្ព ម្នាងសិលា | ផ្ទះលក់វត្ថុ សិល្បៈ | ផ្ទះលក់វត្ថុ អនុស្សាវរីយ៍ | តម្បាញសូត្រ បុរាណ | តម្បាញសូត្រ ស្វយ័ប្រវត្តិ | តម្បាញ ក្រមា | តម្បាញ កន្ទេលកក់ | តម្បាញ ឬស្សី | តម្បាញ រពាក់ | តម្បាញ ផ្តៅ | ដេរម្ជុល ក្រណាត់ | ដេរម្ជុល ស្មឹកញ្ចក់ | គំនូរ សម័យ | គំនូរ បុរាណ | ជាង ទង | សន្លា រ៉ៃ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ក្រុងសិរីសោភ័ណ | 6 | 1 | 1 | 7 | 6 | | 3 | | | | | | | | | | 3 | | 10 | 9 | |
| ២ | ក្រុងប៉ោយប៉ែត | | 1 | | 3 | 3 | | 3 | | | | | | | | | | 3 | | 5 | 2 | |
| ៣ | ព្រះនេត្រព្រះ | 18 | | | 1 | | 6 | | | | | 2 | 5 | | | | 2 | | | 3 | | |
| ៤ | ស្រុកភ្នំស្រុក | | 3 | | 4 | | | | 25 | 15 | 33 | 10 | 3 | | | | | | 2 | 12 | 3 | |
| ៥ | ស្រុកស្វាយចេក | 3 | 1 | | 5 | | | | | | 30 | 16 | 175 | | | 4 | 18 | | 2 | 2 | | |
| ៦ | ស្រុកថ្មពួក | | | | | | | | | | 21 | 10 | 158 | | | | | | | 8 | | |
| ៧ | ស្រុកមង្គលបូរី | 1 | 1 | | 19 | | | 1 | | | | 53 | 39 | 1 | | | 15 | 2 | | 23 | 6 | |
| ៨ | ស្រុកអូរជ្រៅ | | | | 5 | | | | | | | 3 | 10 | | | | 2 | | | 1 | | |
| ៩ | ស្រុកម៉ាឡៃ | | 4 | | 2 | 1 | | | | | | | | | | | | | | 4 | 2 | |
| | សរុប | 28 | 11 | 1 | 45 | 10 | 6 | 7 | 25 | 15 | 84 | 94 | 388 | 1 | | 4 | 37 | 8 | 4 | 66 | 22 | 856 |

បន្ទាយមានជ័យ ថ្ងៃទី........ខែ........ឆ្នាំ២០១៧
ប្រធានការិយាល័យ សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

គឹម សុភាព

បានឃើញ និងឯកភាព
បន្ទាយមានជ័យ ថ្ងៃទី........ខែ........ឆ្នាំ២០១៧
ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត

យស់ តាំងភួយ

តារាងស្ថិតិសិប្បកម្មតម្បាញសូត្រខេត្តបន្ទាយមានជ័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៙៚៙

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប
ការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

## តារាងស្ថិតិលំអិតផ្នែកសិប្បកម្មតម្បាញសូត្រ ឆ្នាំ២០១៦ ក្នុងខេត្តសៀមរាប

| ល.រ | នាម គោត្តនាម | ភេទ | អាយុ | ជនជាតិ | ចំនួនបុគ្គលិក | ទីតាំងសិប្បកម្ម | | ក្រុង/ស្រុក | ឈ្មោះអាជីវកម្ម | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ភូមិ | ឃុំ | | | |
| ១. សិប្បកម្មខ្នាត ធំ | | | | | | | | | | |
| ១ | ម៉ូរី ម៉ូតូគីគុយអូ | ប្រុស | ៦៣ | ជប៉ុន | ៥០ | ជប់សោម | ពាក់ស្នែង | អង្គរធំ | ឡៅស្ថានវាយនភ័ណ្ឌប្រពៃណីខ្មែរ | |
| ២ | អ៊ី សោភា | ស្រី | ៤៦ | ខ្មែរ | ៩៣ | ប្រីយ៍ | ខ្នារសណ្ដាយ | បន្ទាយស្រី | សិប្បកម្មសូត្រមាស | |
| ៣ | ន្គុយយ៉ា ប៊ីងសង់ | ប្រុស | ៥២ | បារាំង | ៤៧២ | ប្រយុទ្ធ | ពួក | ពួក | មជ្ឈមណ្ឌលជាតិកោសេយ្យវប្បកម្ម | |
| ៤ | ខាន់ តា | ប្រុស | ៤៥ | ជប៉ុន | ៩៥ | ខ្វាស់ | ខ្វាស់ | សូទ្រនិគម | កាមោនោហាស៊ិក | |
| ២. សិប្បកម្មខ្នាត មធ្យម | | | | | | | | | | |
| ៥ | សុខ សុខា | ស្រី | ៣៨ | ខ្មែរ | ២៨ | រហាល | ដូនកែវ | ពួក | | |
| ៦ | ពៅ វង្ឃា | ស្រី | ៣៨ | ខ្មែរ | ២២ | ព្រៃក្មេង | ខ្នាត | ពួក | | |
| ៧ | សុខ សំអាត | ស្រី | ៣៨ | ខ្មែរ | ២២ | គំរូ | ល្វា | ពួក | | |
| ៨ | ម៉ន មុន្នី | ស្រី | ២៩ | ខ្មែរ | ២២ | គំរូ | ល្វា | ពួក | | |
| ៩ | ពេជ្រ សុភ័ក្រ | ស្រី | ៣៧ | ខ្មែរ | ២៥ | ពួកចាស់ | ពួក | ពួក | | |
| ១០ | សារី កល្យាណ | ស្រី | ៣១ | ខ្មែរ | ៥ | សាលាកន្សែង | ស្វាយដង្គំ | សៀមរាប | សូត្រស្នាដៃខ្មែរ | |

តារាងស្ថិតិសិប្បកម្មតម្បាញសូត្រខេត្តសៀមរាប

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១១ | សំណាង បុរីរ័ត្ន | ស្រី | ២៤ | ខ្មែរ | ៥ | សាលាកន្សែង | ស្វាយដង្គំ | សៀមរាប | ខ្មែរសូត្រ | |
| ១២ | មូរីមូតុ គីគុយអូ | ប្រុស | ៥៧ | ជប៉ុន | ៥០ | ហៃ‌របេន | ស្វាយដង្គំ | សៀមរាប | វិទ្យាស្ថានវាយនភ័ណ្ឌប្រពៃណីខ្មែរ | |
| ៣. សិប្បកម្មខ្នាត តូច | | | | | | | | | | |
| ១៣ | ខ្មុយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | ហោល | ដូនកែវ | ពួក | សិប្បកអង្គរហោល | |
| ១៤ | ខ្មុយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | គោកត្រាច | ខ្នាត | ពួក | សិប្បកអង្គរគោកត្រាច | |
| ១៥ | ស៊ុន ឡាម | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ១៦ | ទិត្យ ស៊ីនីវ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ១៧ | យួន ឈាន់ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ១៨ | សៅ សុកាន់ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ១៩ | ញិប ហ៊ាំង | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២០ | ធិរ សាមេត | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២១ | សំសេក ពិសិដ្ឋ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២២ | ក្រូច វីណាត | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៣ | ឡោក សារួត | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៤ | ចាន់ សុភាព | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៥ | ហល់ សំរិទ្ធ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៦ | បេង មាលា | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៧ | យួន ចិន | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៨ | ឡុក កុត | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ២៩ | ចេត្រ ផាវី | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ៣០ | គី សាគុណ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |

តារាងស្ថិតិសិប្បកម្មតម្បាញសូត្រខេត្តសៀមរាប

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣១ | ហ៊ិន សុកក្រ | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ៣២ | ង៉ិន ស៊ីណា | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ៣៣ | ហម ហ៊ាន | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ៣៤ | ណុប សារី | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ៣៥ | ហ៊ុក រិទ្ធី | ស្រី | | ខ្មែរ | | ព្រៃក្មេង | ខ្នាត | ពួក | | លក្ខណៈគ្រួសារ |
| ៣៦ | ឡេយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | ព្រៃក្មេង | ខ្នាត | ពួក | សិប្បករអង្គរព្រៃក្មេង | |
| ៣៧ | ឡេយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | គិរូ | ល្វា | ពួក | សិប្បករអង្គរគិរូ | |
| ៣៨ | ឡេយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | ពួកចាស់ | ពួក | ពួក | សិប្បករអង្គរពួកចាស់ | |
| ៣៩ | ឡេយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | តាទក | ពួក | ពួក | សិប្បករអង្គរល្បើក | |
| ៤០ | ឡេយយ៉ា វ៉ាំងសង់ | ប្រុស | ៥២ | បារាំង | | ព្រៃវែង | សំរោងយារ | ពួក | សិប្បករអង្គរសំរោងយារ | |

* សិប្បកម្មខ្នាត ធំ មានចំនួនៈ ៤ កន្លែង

* សិប្បកម្មខ្នាត មធ្យម មានចំនួនៈ ៨ កន្លែង

* សិប្បកម្មខ្នាត តូច មានចំនួនៈ ២៨ កន្លែង

សៀមរាប,ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧

**ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត**

**មួន សុភាព**

សៀមរាប,ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧

**អនុប្រធានការិយាល័យសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម**

**សុខ ស៊ីន**

តារាងស្ថិតិសិប្បកម្មតម្បាញសូត្រខេត្តសៀមរាប

## *សូមថ្លែងអំណរគុណ*

*ក្រុមការងារសិក្សាស្រាវជ្រាវសៀវភៅ " សិល្បៈតម្បាញសូត្រខ្មែរ " នៃនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី សិល្បៈករ សិប្បករតម្បាញ អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានចូលរួមជួយសហការផ្តល់ឯកសារនិងបទសម្ភាសន៍ដល់ក្រុមការងាររបស់នាយកដ្ឋានដើម្បីធ្វើឲ្យសម្រេចបានជាសៀវភៅនេះឡើង ដើម្បីជាមូលដ្ឋានសំរាប់ដល់អ្នកសិក្សាស្រាវជ្រាវគ្រប់វ័យ និងគ្រប់ជំនាន់។*

*ក្នុងនោះរួមមានៈ*

*១. ថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ*

| | | |
|---|---|---|
| *លោកជំទាវ* | ***ភឿង សកុណា*** | *រដ្ឋមន្ត្រី* |
| *ឯកឧត្តម* | ***អ៊ុក សុជាតិ*** | *រដ្ឋលេខាធិការ* |
| *លោកជំទាវ* | ***នេត្រ ភូម៉ារី*** | *អនុរដ្ឋលេខាធិការ* |
| *ឯកឧត្តម* | ***ហាប់ ទូច*** | *អគ្គនាយកបច្ចេកទេសវប្បធម៌* |
| *លោក* | ***ឈឹម សុធី*** | *ប្រធាននាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម* |

*២. មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល។ល។*

*៣. ហនុមានសម្បត្តិខ្មែរ លោកស្រី តាន់ សុទ្ធោ។*

*៤. លោក ទ្រឹម សុភា ក្រុមតម្បាញកោះឧកញ៉ាតី។*

*៥. ពិតានខ្មែរ CFYK.។*

*៦. សមាគមន៍សិប្បករកម្ពុជា។*

# ឯកសារពិគ្រោះ

-ទំព័រ. 2. 27. 28. 29. 30. 31. 32. 33. ឯកសារគំនូរប្លង់របស់ Lotus Pond ឆ្នាំ 1999 គូរដោយលោក ហោ សុខលាភ។

-ទំព័រ. 54. 55. 56. 57. រូបភាពរបស់លោកស្រី តាន់ សូទ្ធោ (ហនុមានសម្បត្តិខ្មែរ)។

-ទំព័រ. 58 រូបភាព Cambodian Traditional Textile Book.

-ទំព័រ. 74 ពិតានខ្មែរ អង្គរទ្រទ្រង់កុមារខ្មែរ។

-ទំព័រ. 94. 95. 96 រូបភាពដកស្រង់ចេញពីសៀវភៅ (Images d'Asie Cambodge)។

-គំរបគ្របមុខសៀវភៅរូបភាពបានមកពី ពិតានខ្មែរ (ការចង់គាត)។

